ក. $f(x)=(3x+5)^2=(3x+5)(3x+5)$

តាមដេរីវេនៃផលគុណ $y=uv \Rightarrow y'=u'v+v'u$ គេបាន :

$f'(x)=3(3x+5)+3(3x+5)=6(3x+5) \quad (1)$

តាមដេរីវេនៃស្វ័យគុណ $y=u^n=n.u'.u^{n-1}$ នោះយើងបាន :

$y'=2\times3\times(3x+5)=6(3x+5) \quad (2)$

តាម (1) និង (2) រូបមន្តទាំងពីរនេះ លទ្ធផលមានចម្លើយដូចគ្នា ។

ខ. $y=(7-4x)^2=(7-4x)(7-4x)$

តាមដេរីវេនៃផលគុណ យើងបាន :

$f'(x)=-4(7-4x)-4(7-4x)=-8(7-4x) \quad (1)$

តាមដេរីវេនៃស្វ័យគុណ យើងបាន :

$y'=2(7-4x)\times(7-4x)=-8(7-4x) \quad (2)$

តាម (1) និង (2) រូបមន្តទាំងពីរលទ្ធផលមានចម្លើយដូចគ្នា :

**4-** គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $\text{in}^2 x + \cos^2 x$ ខ. $y = 5x^3 - 2\sin x\cos x$

គ. $y = (\ \ \ \text{in}\, x)^3$ ឃ. $y = \sin x - x^2\cos x$

ង. $y = x^2 - \tan^2 x$ ច. $y = 3x\cot^2 x$ ។

## សំរាយបញ្ជាក់ :

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

យើងមាន :

ក. $y = \sin^2 x + \cos^2 x$ នោះយើងបាន :

$y' = 2\times(\sin x)'\times\sin x + 2\times(\cos x)'\times\cos x$

$= 2\cos x\sin x - 2\sin x\cos x = 0$

ដូចនេះ $\boxed{y' = 0}$

ខ. $y = 5x^3 - 2\sin x\cos x$ នោះយើងបាន :

$y' = 15x^2 - 2[(\sin x)'\cos x + (\cos x)'\sin x]$

$= 15x^2 - 2(\cos^2 x - \sin^2 x)$

$= 15x^2 - 2\cos 2x$

ដូចនេះ $\boxed{y' = 15x^2 - 2\cos 2x}$

គ. $y = (2x - \sin x)^3$ នោះយើងបាន :

$$y' = 3\times(2x-\sin x)'(2x-\sin x)^2$$

$$= 3(2-\cos x)(2x-\sin x)^2$$

ដូចនេះ $\boxed{y' = 3(2-\cos x)(2x-\sin x)^2}$

**ឃ.** $y = \sin x - x^2\cos x$ នោះយើងបាន :

$$y' = (\sin x)' - \left[(x^2)'\cos x + (\cos x)'x^2\right]$$

$$= \cos x - \left(2x\cos x - x^2\sin x\right)$$

$$= \cos x - 2x\cos x + x^2\sin x$$

ដូចនេះ $\boxed{y' = \cos x - 2x\cos x + x^2\sin x}$

**ង.** $y = x^2 - \tan^2 x$ នោះយើងបាន :

$$y' = (x^2)' - 2\times(\tan x)'\tan x$$

$$= 2x - 2\tan x\left(1+\tan^2 x\right)$$

ដូចនេះ $\boxed{y' = 2x - 2\tan x\left(1+\tan^2 x\right)}$

**ច.** $y = 3x\cot^2 x$ នោះយើងបាន :

$$y' = 3\left[(x)'\cot^2 x + (\cot^2 x)'x\right]$$

$$= 3\left[\cot^2 x - 2x\cot x\left(1+\cot^2 x\right)\right]$$

ដូចនេះ $\boxed{y' = 3\left[\cot^2 x - 2x\cot x\left(1+\cot^2 x\right)\right]}$

5- គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $f(x)=\sin^2 x^2$ ខ. $f(x)=x^3-\cos^2 5x$

គ. $f(x)=\dfrac{\tan 2x}{1-\cos x}$ ឃ. $f(x)=x^3-\sin\left(x^2-5x\right)$

ង. $f(x)=\sin 3x+\cos\left(x^3-1\right)$

ច. $f(x)=\tan\left(2x^3-5x\right)$

## សំរាយបញ្ជាក់ :

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

យើងមាន :

ក. $f(x)=\sin^2 x^2$

$f'(x)=2\times\left(\sin x^2\right)'\left(\sin x^2\right)=2\times\left(x^2\right)\cos x^2\times\sin x^2$

$=4x\cos x^2\sin x^2$

ដូចនេះ $\boxed{f'(x)=4x\cos x^2\sin x^2}$

ខ. $f(x)=x^3-\cos^2 5x$ នោះយើងបាន :

$f'(x)=3x^2-2\times(\cos 5x)'\cos 5x$

$=3x^2+10\sin 5x.\cos 5x$

$=3x^2+5\sin 10x$

ព្រោះ $\sin 10x = 2\sin 5x.\cos 5x$

ដូចនេះ $\boxed{f'(x) = 3x^2 + 5\sin 10x}$

គ. $f(x) = \dfrac{\tan 2x}{1-\cos x}$ នោះយើងបាន :

$$f'(x) = \frac{(\tan 2x)'(1-\cos x) - (1-\cos x)'\tan 2x}{(1-\cos x)^2}$$

$$= \frac{2\left(1+\tan^2 2x\right)(1-\cos x) - \sin x \tan 2x}{(1-\cos x)^2}$$

ដូចនេះ $\boxed{f'(x) = \dfrac{2\left(1+\tan^2 2x\right)(1-\cos x) - \sin x \tan 2x}{(1-\cos x)^2}}$

ឃ. $f(x) = x^3 - \sin\left(x^2 - 5x\right)$ នោះយើងបាន :

$$f'(x) = 3x^2 - \left(x^2 - 5x\right)'\cos\left(x^2 - 5x\right)$$

$$= 3x^2 - (2x-5)\cos\left(x^2 - 5x\right)$$

ដូចនេះ $\boxed{f'(x) = 3x^2 - (2x-5)\cos\left(x^2 - 5x\right)}$

ង. $f(x) = \sin 3x + \cos\left(x^3 - 1\right)$ នោះយើងបាន :

$$f'(x) = 3\cos 3x - \left(x^3 - 1\right)'\sin\left(x^3 - 1\right)$$

$$= 3\cos 3x - 3x^2 \sin\left(x^3 - 1\right)$$

ដូចនេះ $f'(x)=3\cos 3x-3x^2\sin\left(x^3-1\right)$

ច. $f(x)=\tan\left(2x^3-5x\right)$ នោះយើងបាន :

$$f'(x)=\left(2x^3-5x\right)'\left[1+\tan^2\left(2x^3-5x\right)\right]$$

$$=\left(6x^2-5\right)\left[1+\tan^2\left(2x^3-5x\right)\right]$$

ដូចនេះ $f'(x)=\left(6x^2-5\right)\left[1+\tan^2\left(2x^3-5x\right)\right]$

6- គណនាដេរីវេទី 2 នៃអនុគមន៍:

ក. $y=3x^2-\sin 2x$ ខ. $y=-3x^4+2x^2$

គ. $y=x+\dfrac{1}{x}$ ឃ. $g(x)=\dfrac{x^2}{x+1}$

ង. $g(x)=\left(x^2+4\right)^3$ ច. $g(x)=\left(x^3-1\right)^4$ ។

**សំរាយបញ្ជាក់ :**

គណនាដេរីវេទី 2 នៃអនុគមន៍:

យើងមាន :

ក. $y=3x^2-\sin 2x$

$$y'=6x-2\cos 2x\Rightarrow y''=6+4\sin 2x$$

ដូចនេះ $y''=6+4\sin 2x$

ខ. $y=-3x^4+2x^2 \Rightarrow y'=-12x^3+4x \Rightarrow y''=-36x^3+4$

ដូចនេះ $\boxed{y''=-36x^3+4}$

គ. $y=x+\dfrac{1}{x} \Rightarrow y'=1-\dfrac{1}{x^2} \Rightarrow y''=\dfrac{2}{x^3}$

ដូចនេះ $\boxed{y''=\dfrac{2}{x^3}}$

ឃ. $g(x)=\dfrac{x^2}{x+1}$ នោះយើងបាន :

$$g'(x)=\frac{2x(x+1)-x^2}{(x+1)^2}=\frac{x^2+2x}{(x+1)^2}$$

$$\Rightarrow g''(x)=\frac{(2x+2)(x+1)^2-2(x+1)(x^2+2x)}{(x+1)^4}$$

$$=\frac{(2x+2)(x+1)-2(x^2+2x)}{(x+1)^3}$$

$$=\frac{2x^2+2x+2x+2-2x^2-4x}{(x+1)^3}$$

$$=\frac{2}{(x+1)^3}$$

ដូចនេះ $\boxed{g''(x)=\dfrac{2}{(x+1)^3}}$

ង. $g(x)=\left(x^2+4\right)^3$ នោះយើងបាន :

$$g'(x)=3\times\left(x^2+4\right)'\left(x^2+4\right)^2=6x\left(x^2+4\right)^2$$

$$g''(x)=(6x)'\left(x^2+4\right)^2+\left[\left(x^2+4\right)^2\right]'\times 6x$$

$$=6\left(x^2+4\right)^2+24x^2\left(x^2+4\right)$$

$$=\left(x^2+4\right)\left(30x^2+24\right)$$

ដូចនេះ $\boxed{g''(x)=\left(x^2+4\right)\left(30x^2+24\right)}$

ច. $g(x)=\left(x^3-1\right)^4$ នោះយើងបាន :

$$g'(x)=12x^2\left(x^3-1\right)^3$$

$$\Rightarrow g''(x)=24x\left(x^3-1\right)^3+12x^2\times 9x^2\left(x^3-1\right)^2$$

$$=24x\left(x^3-1\right)^3+108x^4\left(x^3-1\right)^2$$

ដូចនេះ $\boxed{g''(x)=24x\left(x^3-1\right)^3+108x^4\left(x^3-1\right)^2}$

7- រក $y'$ជាអនុគមន៍នៃ $x$ និង $y$ :

ក. $x=\tan y$

ខ. $x=\sin y$

គ. $xy+\sin y=0$

ឃ. $x+\sin y=xy$

ង. $x+\tan(xy)=0$

ច. $y^2=\sin^4 2x+\cos^4 2x$ ។

## សំរាយបញ្ជាក់ :

រក $y'$ ជាអនុគមន៍នៃ $x$ និង $y$ :

ក. $x = \tan y$ យើងបាន :

ដោយធ្វើដេរីវេលើអង្គទាំងពីរនោះ យើងបាន :

$$(x)' = (\tan y)' \Rightarrow 1 = y'(1+\tan^2 y) \Rightarrow y' = \frac{1}{1+\tan^2 y}$$

ដូចនេះ $\boxed{y' = \frac{1}{1+\tan^2 y}}$

ខ. $x = \sin y$ យើងបាន :

$$(x)' = (\sin y)' \Rightarrow 1 = y'\cos y \Rightarrow y' = \frac{1}{\cos y}$$

ដូចនេះ $\boxed{y' = \frac{1}{\cos y}}$

គ. $xy + \sin y = 0 \Rightarrow xy = -\sin y$ យើងបាន :

$$(xy)' = -(\sin y)' \Rightarrow y + xy' = -y'\cos y$$

$$\Rightarrow y'(x+\cos y) = -y \Rightarrow y' = \frac{-y}{x+\cos y}$$

ដូចនេះ $\boxed{y' = \frac{-y}{x+\cos y}}$

ឃ. $x + \sin y = xy$ យើងបាន :

$$(x+\sin y)'=(xy)'\Rightarrow 1+y'\cos y=y+xy'$$

$$\Rightarrow y'(\cos y-x)=y-1\Rightarrow y'=\frac{y-1}{\cos y-x}$$

ដូចនេះ $\boxed{y'=\frac{y-1}{\cos y-x}}$

**ង.** $x+\tan(xy)=0\Rightarrow x=-\tan(xy)$ យើងបាន :

$$(x)'=[-\tan(xy)]'\Rightarrow 1=-(xy)'\left[1+\tan^2(xy)\right]$$

$$\Rightarrow 1=-(y+y'x)\left[1+\tan^2(xy)\right]$$

$$\Rightarrow y+y'x=\frac{-1}{1+\tan^2(xy)}\Rightarrow y'=\frac{-1}{x\left[1+\tan^2(xy)\right]}-\frac{y}{x}$$

ដូចនេះ $\boxed{y'=\frac{-1}{x\left[1+\tan^2(xy)\right]}-\frac{y}{x}}$

**ច.** $y^2=\sin^4 2x+\cos^4 2x$ យើងបាន :

$$(y^2)'=\left(\sin^4 2x+\cos^4 2x\right)'$$

$$2yy'=4\times(2\cos 2x)\times\sin^3 2x+4\times(-2\sin 2x)\times\cos^3 2x$$

$$=8\cos 2x\sin^3 2x-8\sin 2x\cos^3 2x$$

$$\Rightarrow y'=\frac{4\cos 2x\sin^3 2x-4\sin 2x\cos^3 2x}{y}$$

ដូចនេះ $\boxed{y'=\frac{4\cos 2x\sin^3 2x-4\sin 2x\cos^3 2x}{y}}$

8- រក $y'$ និង $y''$ ជាអនុគមន៍នៃ $x$ និង $y$:

ក. $2x^2+y^2=4$　　　　ខ. $2x^3+y^3=8$

គ. $x^2+xy+y^2=-1$　　　　ឃ. $x^3+2xy-y^2=3$

ង. $x^3+y^3=3xy$　　　　ច. $x^3y+xy^3=3x^2$

## សំរាយបញ្ជាក់ :

រក $y'$ និង $y''$ ជាអនុគមន៍នៃ $x$ និង $y$:

ក. $2x^2+y^2=4$ យើងបាន :

$$\left(2x^2+y^2\right)'=(4)'\Rightarrow 4x+2yy'=0\Rightarrow y'=-\frac{2x}{y}$$

ហើយ គេបាន $4+2y'y'+2yy''=0\Rightarrow y''=\frac{-2-(y')^2}{y}$

$$=\frac{-2-\left(-\frac{2x}{y}\right)^2}{y}=\frac{-2y^2-4x^2}{y^3}$$

ដូចនេះ $\boxed{y'=-\frac{2x}{y};\ y''=\frac{-4x^2-2y^2}{y^3}}$

ខ. $2x^3+y^3=8$ យើងបាន :

$$\left(2x^3+y^3\right)'=(8)'\Rightarrow 6x^2+3y^2y'=0\Rightarrow y'=-\frac{2x^2}{y^2}$$

$$12x+6yy'y'+3y^2y''=0 \Rightarrow y''=\frac{-4x-2y(y')^2}{y^2}$$

$$=\frac{-4x-2y\left(\frac{-2x^2}{y^2}\right)^2}{y^2}=\frac{-4xy^4-8yx^4}{y^6}=\frac{-4x\left(y^3+2x^3\right)}{y^5}$$

ដូចនេះ $\boxed{y'=-\frac{2x^2}{y^2};\, y''=\frac{-4x\left(y^3+2x^3\right)}{y^5}}$

គ. $x^2+xy+y^2=-1$ យើងបាន :

$$\left(x^2+xy+y^2\right)'=(-1)' \Rightarrow 2x+y+xy'+2yy'=0$$

$$\Rightarrow y'=-\frac{2x+y}{x+2y}$$

គេបាន $2+y'+y'+xy''+2y'y'+2yy''=0$

$$\Rightarrow y''=\frac{-2-2y'-2(y')^2}{x+2y}$$

$$=\frac{-2-2\left(-\frac{2x+y}{x+2y}\right)-2\left(-\frac{2x+y}{x+2y}\right)^2}{x+2y}$$

$$=\frac{-y^2-6x^2-6xy}{(x+2y)^3}$$

ដូចនេះ $y' = -\dfrac{2x+y}{x+2y}; y'' = \dfrac{-6y^2-6x^2-6xy}{(x+2y)^3}$

**ឃ.** $x^3+2xy-y^2=3$ យើងបាន :

$$(x^3+2xy-y^2)' = (3)' \Rightarrow 3x^2+2y+2xy'-2yy'=0$$

$$\Rightarrow y' = \frac{-3x^2-2y}{2x-2y}$$

ហើយ $6x+2y'+2y'+2xy''-2y'y'-2yy''=0$

$$\Rightarrow y'' = \frac{-3x-2y'+(y')^2}{x-y}$$

$$= \frac{-3x-2\left(\dfrac{-3x^2-2y}{2x-2y}\right)+\left(\dfrac{-3x^2-2y}{2x-2y}\right)^2}{x-y}$$

$$= \frac{18x^4+48x^2y-8y^2-24xy^2+16xy}{8(x-y)^3}$$

ដូចនេះ $y' = \dfrac{-3x^2-2y}{2x-2y}$

និង $y'' = \dfrac{18x^4+48x^2y-8y^2-24xy^2+16xy}{8(x-y)^3}$

ង. $x^3 + y^3 = 3xy$ នោះយើងបាន ៖

$$\left(x^3 + y^3\right)' = (3xy)' \Rightarrow 3x^2 + 3y'y^2 = 3y + 3xy'$$

$$\Rightarrow y' = \frac{y - x^2}{y^2 - x}$$

ហើយយើងបាន $2x + 2yy'y' + y^2y'' = y' + y' + xy''$

$$\Rightarrow y'' = \frac{-2x - 2y\left(\frac{y - x^2}{y^2 - x}\right)^2 + 2\left(\frac{y - x^2}{y^2 - x}\right)}{y^2 - x}$$

$$= \frac{6x^2y^2 - 2xy^4 - 2yx^4 - 2xy}{\left(y^2 - x\right)^3}$$

ដូចនេះ $\boxed{y' = \frac{y - x^2}{y^2 - x};\ y'' = \frac{6x^2y^2 - 2xy^4 - 2yx^4 - 2xy}{\left(y^2 - x\right)^3}}$

ច. $x^3y + xy^3 = 3x^2$ យើងបាន ៖

$$\left(x^3y + xy^3\right)' = (3x)^2 \Rightarrow 3x^2y + x^3y' + y^3 + 3xy^2y' = 6x$$

$$\Rightarrow y' = \frac{6x - 3x^2y - y^3}{x^3 + 3xy^2}$$

គេបាន ៖

$$6xy+3x^2y'+3x^2y'+x^3y''+3y^2y'+3y^2y'$$
$$+6xy(y')^2+3xy^2y''=6$$
$$\Rightarrow y''=\frac{6-6xy-6x^2y'-6y^2y'-6xy(y')^2}{x^3+3xy^2}$$
$$=\frac{12x^3y\left(x^4-18\right)+x^2y^2\left(234y^2+108x^2\right)}{\left(x^3+3xy^2\right)^3}$$
$$+\frac{-12x^3y^3\left(x^2+y^2\right)+6xy^2(3-y)-30x^6}{\left(x^3+3xy^2\right)^3}$$

9- គណនា:

ក. $f^{(4)}(x)$ បើ $f(x)=x^3-3x^2+2x$

ខ. $f^{(6)}(x)$ បើ $f(x)=\frac{1}{7}x^7-\sin 2x$

គ. $f^{(8)}(x)$ បើ $f(x)=x^8-5x^2+\cos x$

ឃ. $f^{(10)}(x)$ បើ $f(x)=\frac{120}{x^6}$ ។

## សំរាយបញ្ជាក់ :

ក. $f^{(4)}(x)$ បើ $f(x)=x^3-3x^2+2x$ នោះយើងបាន :

$f'(x)=3x^2-6x+2; f''(x)=6x-6$

$; f'''(x)=6; f^{(4)}(x)=0$

ដូចនេះ $\boxed{f^{(4)}(x)=0}$

ខ. $f^{(6)}(x)$ បើ $f(x)=\frac{1}{7}x^7-\sin 2x$ នោះយើងបាន :

$f'(x)=x^6-2\cos 2x; f''(x)=6x^5+4\sin 2x$

$f'''(x)=30x^4+8\cos 2x; f^{(4)}(x)=120x^3-16\sin 2x$

$f^{(5)}(x)=360x^2-32\cos 2x; f^6(x)=720x+64\sin 2x$

ដូចនេះ $\boxed{f^6(x)=720x+64\sin 2x}$

គ. $f^{(8)}(x)$ បើ $f(x)=x^8-5x^2+\cos x$ នោះយើងបាន :

$f'(x)=8x^7-10x-\sin x; f''(x)=7\times 8x^6-10-\cos x$

$f'''(x)=6\times 7\times 8x^5+\sin x; f^{(4)}(x)=5\times 6\times 7\times 8x^4+\cos x$

$f^{(5)}(x)=4\times 5\times 6\times 7\times 8x^3-\sin x$

$f^{(6)}(x)=3\times 4\times 5\times 6\times 7\times 8x^2-\cos x$

$f^{(7)}(x)=2\times 3\times 4\times 5\times 6\times 7\times 8x+\sin x$

$f^{(8)}(x)=2\times 3\times 4\times 5\times 6\times 7\times 8+\cos x=8!+\cos x$

ដូចនេះ $\boxed{f^{(8)}(x)=8!+\cos x}$

**សំគាល់:** $n!=n\times(n-1)\times(n-2)...\times 2\times 1$

**ឃ.** $f^{(10)}(x)$ បើ $f(x)=\frac{120}{x^6}$

យើងមាន $f(x)=\frac{120}{x^6}=120.x^{-6}$ នោះយើងបាន :

$$f'(x) = 120\times(-6)x^{-7}$$

$$f''(x) = 120\times(-6)\times(-7)x^{-8} = (-1)^2\times120\times6\times7x^{-8}$$

$$f^{(3)}(x) = 120\times(-6)\times(-7)\times(-8)x^{-9}$$

$$= (-1)^3\times120\times6\times7\times8x^{-9}$$

......... ..........................................................................

.................................................................................

$$f^{(10)}(x) = (-1)^{10}\times120\times6\times7\times8\times\ldots\times15x^{-16}$$

ដោយ $120 = 1\times2\times3\times4\times5$ យើងបាន :

$$f^{(10)}(x) = 1\times2\times3\times4\times5\times6\times7\times\ldots\times15x^{-16} = \frac{15!}{x^{16}}$$

ដូចនេះ $\boxed{f^{(10)}(x) = \frac{15!}{x^{16}}}$

មេរៀនទី២ : **អនុវត្តន៍ដេរីវេ**

**លំហាត់ :**




1-ពីរ៉ាមីតចតុមុខនិយ័ត $SABCD$ មានផ្ទៃក្រឡាខាង$S_l$ ។ គណនាផលធៀបរង្វាស់កម្ពស់ $SO$ និងជ្រុងមួយនៃបាតដើម្បីឱ្យមានពីរ៉ាមីតចតុមុខនិយ័តមានតម្លៃអតិបរមា ។

**សំរាយបញ្ជាក់ :**




គណនាផលធៀបរង្វាស់កម្ពស់ $SO$ និងជ្រុងមួយនៃបាតដើម្បីឱ្យមានពីរ៉ាមីតចតុមុខនិយ័តមានតម្លៃអតិបរមា :

តាង $|AB| = x \;; x > 0$ រង្វាស់ជ្រុងបាត

យក $I$ ជាចំណុចកណ្ដាល $[AB]$ នាំឱ្យ $[SI]$ ជាអាប៉ូតែម :

គេបាន $S_l = \frac{1}{2} \times 4x \times SI \Rightarrow SI = \frac{S_l}{2x}$

ត្រីកោណ $SOI$ កែងត្រង់ $O$ យើងបាន :

$$SO^2 = SI^2 - OI^2 = \left(\frac{S_l}{2x}\right)^2 - \left(\frac{x}{2}\right)^2 = \frac{S_l^2 - x^4}{4x^2}$$

តែ $S_l^2 - x^4 > 0 \Rightarrow x^4 < S_l^2 \Rightarrow x^2 < S_l$

$\Rightarrow x < \sqrt{S_l} \Rightarrow 0 < x < \sqrt{S_l}$

យើងបាន $SO = \dfrac{\sqrt{S_l^2 - x^4}}{2x}$

តាង $V(x)$ ជាមាឌនៃពីរ៉ាមីត :

នោះ $V(x) = \dfrac{1}{3}x^2\dfrac{\sqrt{S_l^2 - x^4}}{2x} = \dfrac{x}{6}\sqrt{S_l^2 - x^4}$

$\Rightarrow V'(x) = \dfrac{S_l^2 - 3x^4}{6\sqrt{S_l^2 - x^4}}$

ដោយ $V'(x) = 0 \Rightarrow 3x^4 = S_l^2 \Rightarrow x = \sqrt[4]{\dfrac{S_l^2}{3}}$

| $x$ | $0$ | | $\sqrt[4]{\dfrac{S_l^2}{3}}$ | | $\sqrt{S_l}$ |
|---|---|---|---|---|---|
| $V'(x)$ | | $+$ | $0$ | $-$ | |
| $V(x)$ | | $\nearrow$ | អតិបរមា | $\searrow$ | |

តាមតារាង យើងបាន :

$$\frac{SO}{x} = \frac{\sqrt{S_l^2 - x^4}}{2x^2} = \frac{\sqrt{S_l^2 - \frac{S_l^2}{3}}}{2\sqrt{\frac{S_l^2}{3}}} = \frac{\sqrt{\frac{2S_l^2}{3}}}{2\sqrt{\frac{S_l^2}{3}}} = \frac{\sqrt{2}\times\sqrt{\frac{S_l^2}{3}}}{2\sqrt{\frac{S_l^2}{3}}} = \frac{\sqrt{2}}{2}$$

ដូចនេះ ផលធៀបរង្វាស់កម្ពស់និងជ្រុងបាតនៃពីរ៉ាមីតគឺ $\boxed{\dfrac{\sqrt{2}}{2}}$

**2-** ផលបូកបរិមាត្រការេមួយ និងរង្វង់មួយមានប្រវែង $l$ ។

គណនាផលធៀបរង្វាស់កាំរង្វង់និងជ្រុងការេ ដើម្បីឱ្យផលបូកផ្ទៃក្រឡាការេនិងរង្វង់មាន តម្លៃអប្បបរមា។

**សំរាយបញ្ជាក់ :**

គណនាផលធៀបរង្វាស់កាំរង្វង់និងជ្រុងការេ ដើម្បីឱ្យផលបូកផ្ទៃក្រឡាការេនិងរង្វង់មាន តម្លៃអប្បបរមា :

តាង $x$ ជាជ្រុងការេ និង $r$ ជាកាំនៃរង្វង់

ផលបូកបរិមាត្រ $l = 4x + 2\pi r \Rightarrow r = \dfrac{l - 4x}{2\pi}$

ក្រឡាផ្ទៃ: $S = x^2 + \pi r^2 = x^2 + \pi \times \dfrac{(l - 4x)^2}{4\pi^2}$

$= x^2 + \dfrac{16x^2 - 8lx + l^2}{4\pi}$

$\Rightarrow S' = 2x + \dfrac{8x}{\pi} - \dfrac{2l}{\pi} = x\left(2 + \dfrac{8}{\pi}\right) - \dfrac{2l}{\pi}$

ដោយ $S'(x) = 0 \Rightarrow x = \dfrac{2l}{\pi} \times \dfrac{\pi}{2\pi + 8} = \dfrac{l}{\pi + 4}$

តាងអថេរភាព :

$x=\dfrac{l}{\pi+4}$

| $x$ | $0$ | | $\dfrac{l}{\pi+4}$ | | $+\infty$ |
|---|---|---|---|---|---|
| $S'$ | | $-$ | $0$ | $+$ | |
| $S$ | | $\searrow$ | | $\nearrow$ | |

$$\Rightarrow r=\frac{l-\dfrac{4l}{\pi+4}}{2\pi}=\frac{l(\pi+4)-4l}{2\pi(\pi+4)}=\frac{l}{2(\pi+4)}$$

យើងបាន $\dfrac{r}{x}=\dfrac{l}{2(\pi+4)}\times\dfrac{(\pi+4)}{l}=\dfrac{1}{2}$

ដូចនេះ ផលធៀបជ្រុងការេនិងកាំរង្វង់ស្មើនឹង $\boxed{\dfrac{1}{2}}$

3- ប្រអប់ត្រង់មួយមានគម្របលើនិងបាតក្រោមជាការេ ហើយមាន មាឌ$250cm^3$ ។សម្ភារៈសម្រាប់ធ្វើគម្របលើនិងបាតក្រោមតម្លៃ $2000$៛$/cm^2$ ហើយសម្ភារៈសម្រាប់ធ្វើផ្ទៃខាងតម្លៃ$1000$៛$/cm^2$ កំណត់រង្វាស់ទ្រនុងនៃប្រអប់ដើម្បីឱ្យប្រាក់ចំណាយលើសម្ភារៈ មានតម្លៃអប្បបរមា រួចគណនាប្រាក់ចំណាយអប្បបរមានោះ ។

**សំរាយបញ្ជាក់ :**




តាង $x; y$ ជាវិមាត្រនៃប្រអប់ :

យើងមាន មាឌនៃប្រអប់កំណត់ដោយ :

$$V = x^2 y = 250 \Rightarrow y = \frac{250}{x^2}$$

តាង $S$ ជាផ្ទៃសរុប យើងបាន :

$$S = 2x^2 + 4xy = 2x^2 + 4x\left(\frac{250}{x^2}\right) = 2x^2 + \frac{1000}{x}$$

$$\Rightarrow S' = 4x - \frac{1000}{x^2} = \frac{4\left(x^3 - 250\right)}{x^2}$$

ដោយ $S' = 0 \Rightarrow x^3 - 250 = 0 \Rightarrow x = \sqrt[3]{250} = 6.3$

តារាងអថេរភាព :

| $x$ | 0 | | 6.3 | |
|---|---|---|---|---|
| $S'$ | | $-$ | 0 | $+$ |
| $S$ | | ↘ | | ↗ |

ផ្ទៃក្រឡាមានតម្លៃ

អប្បបរមាត្រង់ $x = 6.3$ ហើយ $\Rightarrow y = \frac{250}{(6.3)^2} = 6.3$

យើងបាន ប្រាក់ចំណាយសរុប :

$$C = 2(6.3)^2 \times 2000 + 4(6.3)^2 \times 1000 = 317520 \text{ ៛}$$

ដូចនេះ ប្រាក់ចំណាយសរុប $\boxed{317520}$ ៛

ទូកមួយចាប់ផ្ដើមចេញដំណើរពីចំណុចត្រួតពិនិត្យ ដែលរយៈពេល $t$ នាទីក្រោយមក ទូកនោះមានចម្ងាយពីចំណុចត្រួតពិនិត្យដែល គាងដោយអនុគមន៍ $S(t) = t^3 + 60t$ គិតជាម៉ែត្រ ។

ក. រកល្បឿននៃទូកត្រង់ចំណុចចាប់ផ្ដើម

ខ. កំណត់ល្បឿននៃទូកខណៈ $t = 3mn$ ។

**សំរាយបញ្ជាក់ :**

ក. រកល្បឿននៃទូកត្រង់ចំណុចចាប់ផ្ដើម

ដោយ $S(t) = t^3 + 60t$ នោះយើងបាន :

$$V(x) = \frac{ds}{dt} = 3t^2 + 60$$

ល្បឿននៃទូកត្រង់ចំណុចចាប់ផ្ដើមត្រូវនឹងខណៈ $t = 0$

$$\Rightarrow V(0) = 60m/mn$$

ខ. កំណត់ល្បឿននៃទូកខណៈ $t = 3mn$

ដោយ $V(x) = \frac{ds}{dt} = 3t^2 + 60$ នោះចំពោះ $t = 3mn$ គេបាន :

$$V(3) = 3(3)^2 + 60 = 87m/mn$$

ដូចនេះ ល្បឿននៃទូកខណៈ $t = 3mn$ គឺ $\boxed{V(3) = 87m/mn}$

5-រថយន្តមួយ ចាប់ផ្ដើមចេញដំណើរដោយល្បឿនដែលតាងដោយអនុគមន៍ $V(t) = \frac{100t}{t+15}\ m/s$ ។ កំណត់សំទុះនៃរថយន្តខណៈពេលៈ

ក. $t=5s$ ខ. $t=10s$ គ. $t=20s$ ។

## សំរាយបញ្ជាក់ :

កំណត់សំទុះនៃរថយន្តនៅខណៈនីមួយៗ :

យើងមាន : $V(t)=\dfrac{100t}{t+15}\,m/s$

$$\Rightarrow a(t)=\frac{dv}{dt}=\frac{100(t+15)-100t}{(t+15)^2}=\frac{1500}{(t+15)^2}$$

កំណត់សំទុះនៃរថយន្តខណៈពេល:

ក. ចំពោះ $t=5s$ នោះយើងបាន :

$$a(5)=\frac{1500}{20^2}=3.75m/s^2$$

ខ. ចំពោះ $t=10s$

$$a(10)=\frac{1500}{25^2}=2.4m/s^2$$

គ. ចំពោះ $t=20s$ នោះ $a(20)=\dfrac{1500}{35^2}=1.22m/s^2$

6-រថយន្តមួយផ្តើមចេញដំណើរដោយល្បឿនដែល $t$ វិនាទីតាងដោយអនុគមន៍ $V(t)=\dfrac{22t}{0.44t+3.3}$ ម៉ែត្រក្នុងមួយវិនាទី ។

កំណត់សំទុះ របស់រថយន្តនៅខណៈពេល:

ក. 5វិនាទី ខ. 10វិនាទី គ. 20វិនាទី ឃ. 30វិនាទី ។

## ដំណោះស្រាយ :

កំណត់សំទុះ របស់រថយន្តនៅខណៈពេលនីមួយៗ :

យើងមាន : $V(t)=\dfrac{22t}{0.44t+3.3}$ យើងបាន សំទុះកំណត់ដោយ

$$a(t)=\frac{22(0.44t+3.3)-22t\times 0.44}{(0.44t+3.3)^2}=\frac{72.6}{(0.44t+3.3)^2}$$

ក. ចំពោះ t= 5វិនាទី យើងបាន :

$$a(5)=\frac{72.6}{(0.44\times 5+3.3)^2}=2.4m/s^2$$

ខ. ចំពោះ t=10វិនាទី :

$$a(10)=\frac{72.6}{(0.44\times 10+3.3)^2}=1.22m/s^2$$

គ. ចំពោះ t= 20វិនាទី :

$$a(20)=\frac{72.6}{(0.44\times 20+3.3)^2}=0.49m/s^2$$

ឃ.ចំពោះ t=30វិនាទី :

$$a(30)=\frac{72.6}{(0.44\times 30+3.3)^2}=0.26m/s^2$$

# លំហាត់ជំពូក២

**1-** គណនាដេរីវេនៃអនុគមន៍:

ក. $f(x)=(7x+2)^2$ ខ. $g(x)=\left(x^2-8\right)^{-1}$

គ. $y=\left(4x^2+9x-3\right)^3$ ឃ. $f(x)=\sqrt[3]{5x^3-4}$

ង. $g(x)=x\left(4-3x^2\right)^2$ ច. $y=\dfrac{\sqrt{5x-2}}{x^3}$ ។

## សំរាយបញ្ជាក់ :

ក. $f(x)=(7x+2)^2 \Rightarrow f'(x)=14(7x+2)$

ខ. $g(x)=\left(x^2-8\right)^{-1} \Rightarrow g'(x)=-2x\left(x^2-8\right)^{-2}$

គ. $y=\left(4x^2+9x-3\right)^3 \Rightarrow y'=3(8x+9)\left(4x^2+9x-3\right)^2$

ឃ. $f(x)=\sqrt[3]{5x^3-4}=\left(5x^3-4\right)^{\frac{1}{3}}$

$$\Rightarrow f'(x)=\frac{1}{3}\times 15x^2\times\left(5x^3-4\right)^{-\frac{2}{3}}=5x^2\left(5x^3-4\right)^{-\frac{2}{3}}$$

ង: $g(x)=x\left(4-3x^2\right)^2$

$$\Rightarrow g'(x)=\left(4-3x^2\right)^2+2x\times(-6x)\times\left(4-3x^2\right)$$

$$=\left(4-3x^2\right)\left(4-3x^2-12x^2\right)$$

$$=\left(4-3x^2\right)\left(4-15x^2\right)$$

ច. $y=\frac{\sqrt{5x-2}}{x^3}$ នោះយើងបាន :

$$\Rightarrow y'=\frac{\left(\sqrt{5x-2}\right)'x^3-3x^2\left(\sqrt{5x-2}\right)}{x^6}$$

$$=\frac{\frac{5}{2\sqrt{5x-2}}\times x^3-3x^2\left(\sqrt{5x-2}\right)}{x^6}$$

$$=\frac{5x-6(5x-2)}{2x^4\sqrt{5x-2}}=\frac{-25x+12}{2x^4\sqrt{5x-2}}$$

ដូចនេះ $\boxed{y'=\frac{-25x+12}{2x^4\sqrt{5x-2}}}$

2- គណនាដេរីវេនៃអនុគមន៍:

ក. $y=x^3\sin 2x$

ខ. $y=3x^3-x\cos 3x$

គ. $y=-x\cos\left(4-3x^2\right)$

ឃ. $f(x)=\frac{\sin^2 3x}{x^2}$

ង. $f(x)=\frac{\tan 2x}{x^2-1}$

ច. $f(x)=\cos\left(\sin^2 3x\right)$

**សំរាយបញ្ជាក់ :**

គណនាដេរីវេនៃអនុគមន៍:

យើងមាន :

ក. $y = x^3 \sin 2x \Rightarrow y' = 3x^2 \sin 2x + 2x^3 \cos 2x$

ខ. $y = 3x^3 - x\cos 3x \Rightarrow y' = 9x^2 - \cos 3x + 3x\sin 3x$

គ. $y = -x\cos\left(4-3x^2\right)$

$\Rightarrow y' = -\cos\left(4-3x^2\right) - 6x^2 \sin\left(4-3x^2\right)$

ឃ. $f(x) = \dfrac{\sin^2 3x}{x^2}$ នោះយើងបាន :

$$\Rightarrow f'(x) = \frac{2.3.x^2.\cos 3x \sin 3x - 2x.\sin^2 3x}{x^4}$$

$$= \frac{2.3.x.\cos 3x \sin 3x - 2\sin^2 3x}{x^3}$$

$$= \frac{2\sin 3x(3\cos 3x - \sin 3x)}{x^3}$$

ង. $f(x) = \dfrac{\tan 2x}{x^2-1}$ នោះយើងបាន :

$$\Rightarrow f'(x) = \frac{2\left(1+\tan^2 2x\right)\left(x^2-1\right) - 2x\tan 2x}{\left(x^2-1\right)^2}$$

ច. $f(x) = \cos\left(\sin^2 3x\right)$

$\Rightarrow y' = -6\cos 3x \sin 3x \sin\left(\sin^2 3x\right)$

3- គណនាដេរីវេទី 2 នៃអនុគមន៍ :

ក. $f(x)=x^3-4x^2-x+8$

ខ. $f(x)=x^4+6x^{\frac{3}{2}}-9$

គ. $f(x)=\left(2x^2+7\right)^{\frac{2}{3}}$

ឃ. $f(x)=5x+\dfrac{2}{x+1}$

ង. $f(x)=x^2-\dfrac{14}{x-2}$

ច. $f(x)=\dfrac{7x+2}{x^3}$

## សំរាយបញ្ជាក់ :

គណនាដេរីវេទី 2 នៃអនុគមន៍ :

យើងមាន :

ក. $f(x)=x^3-4x^2-x+8 \Rightarrow f'(x)=3x^2-8x$

នោះ $f''(x)=6x-8$

ដូចនេះ $\boxed{f''(x)=6x-8}$

ខ. $f(x)=x^4+6x^{\frac{3}{2}}-9 \Rightarrow f'(x)=4x^3+9x^{\frac{1}{2}}$

នោះ $f''(x)=12x^2+\dfrac{9}{2}x^{-\frac{1}{2}}$

ដូចនេះ $\boxed{f''(x)=12x^2+\dfrac{9}{2}x^{-\frac{1}{2}}}$

គ. $f(x)=\left(2x^2+7\right)^{\frac{2}{3}} \Rightarrow f'(x)=\dfrac{8}{3}x\left(2x^2+7\right)^{-\frac{1}{3}}$

នោះ យើងបាន :

$$f''(x)=\frac{8}{3}\left[\left(2x^2+7\right)^{-\frac{1}{3}}-\frac{4}{3}x^2\left(2x^2+7\right)^{-\frac{4}{3}}\right]$$

ដូចនេះ $\boxed{f''(x)=\frac{8\left(2x^2+7\right)^{-\frac{1}{3}}}{3}-\frac{32\left(2x^2+7\right)^{-\frac{4}{3}}}{9}}$

ឃ. $f(x)=5x+\frac{2}{x+1}\Rightarrow f'(x)=5-\frac{2}{(x+1)^2}$

នោះយើងបាន : $\boxed{f''(x)=\frac{4}{(x+1)^3}}$

ង. $f(x)=x^2-\frac{14}{x-2}\Rightarrow f'(x)=2x+\frac{14}{(x-2)^2}$

នោះ យើងបាន : $\boxed{f''(x)=2-\frac{28}{(x-2)^3}}$

ច. $f(x)=\frac{7x+2}{x^3}=\frac{7}{x^2}+\frac{2}{x^3}\Rightarrow f'(x)=-\frac{14}{x^3}-\frac{6}{x^4}$

នោះយើងបាន : $\boxed{f''(x)=\frac{42}{x^4}+\frac{24}{x^5}}$

4- រក $y'$ជាអនុគមន៍នៃ $x$ និង $y$:

ក. $x^3+y^3=5$ ខ. $xy^2=-1$

គ. $x-\sqrt{y}=2$ ឃ. $2y+\sqrt{xy}=5x^2$

ង. $x^2+4(y+3)^2=9$ ច. $x^3y+xy^3=3x^3$

## សំរាយបញ្ជាក់ :

រក $y'$ ជាអនុគមន៍នៃ $x$ និង $y$:

**ក.** $x^3+y^3=5 \Leftrightarrow 3x^2+3y'y^2=0 \Rightarrow y'=\dfrac{-3x^2}{y^2}$

**ខ.** $xy^2=-1 \Leftrightarrow y^2+2xy'y=0 \Rightarrow y'=\dfrac{-y}{2x}$

**គ.** $x-\sqrt{y}=2 \Leftrightarrow 1-\dfrac{y'}{2\sqrt{y}}=0 \Rightarrow y'=2\sqrt{y}=2(x-2)$

ព្រោះ $x-\sqrt{y}=2 \Rightarrow \sqrt{y}=x-2$

**ឃ.** $2y+\sqrt{xy}=5x^2$ នោះយើងបាន :

$$2y'+\frac{(xy)'}{2\sqrt{xy}}=10x$$

$$2y'+\frac{y+y'x}{2\sqrt{xy}}=10 \Leftrightarrow \frac{4y'\sqrt{xy}+y+y'x}{2\sqrt{xy}}=10$$

$$y'(4\sqrt{xy}+x)=20\sqrt{xy}-y \Rightarrow y'=\frac{20x\sqrt{xy}-y}{4\sqrt{xy}+x}$$

**ង.** $x^2+4(y+3)^2=9 \Rightarrow y'=\dfrac{-x}{4y+12}$

**ច.** $x^3y+xy^3=3x^3 \Rightarrow y'=\dfrac{9x^2-y^3-3x^2y}{x^3+3y^2x}$

5- រក $y'$ និង $y''$ជាអនុគមន៍ $x$និង $y$:

ក. $x^2+xy=5$ ខ. $x^2y^2-2x=3$

គ. $x^2-y^2=16$ ឃ. $1-xy=x-y$

ង. $y^2=x^3$ ច. $y^2=4x$

**សំរាយបញ្ជាក់ :**

ក. $x^2+xy=5 \Rightarrow y'=\dfrac{-2x-y}{x}; y''=\dfrac{2x+2y}{x^2}$

ខ. $x^2y^2-2x=3$

$\Rightarrow y'=\dfrac{1-xy^2}{x^2y}; y''=-\dfrac{2x^4y^4-2x^3y^2-x^2}{\left(x^2y\right)^3}$

គ. $x^2-y^2=16 \quad \Rightarrow y'=\dfrac{x}{y}; y''=\dfrac{y^2-x^2}{y^3}$

ឃ. $1-xy=x-y \Rightarrow y'=\dfrac{1+y}{1-x}; y''=\dfrac{2+2y}{(1-x)^2}$

ង. $y^2=x^3 \Rightarrow y'=\dfrac{3x^2}{2y}; y''=\dfrac{12xy^2-9x^4}{4y^3}$

ច. $y^2=4x \Rightarrow y'=\dfrac{2}{y}; y''=\dfrac{4}{y^3}$

6. ត្រីកោណ$ABC$ មួយមានបរិមាត្រ $2p$ វិលជុំវិញកម្ពស់ដែលគូស

ចេញពីកំពូល $A$ កំណត់បានសូលីតមួយមានមាឌធំបំផុត ។

គណនារង្វាស់ជ្រុងនិងកម្ពស់នៃត្រីកោណសមបាតនោះ ។

## សំរាយបញ្ជាក់ :




តាង $ABC$ ជាត្រីកោណសមបាត

$AB = AC = x; BC = 2r$

យើងបាន $x + x + 2r = 2p \Rightarrow x + r = p$

$\Rightarrow r = p - x$

• $[AH]$ ជាកម្ពស់នៃត្រីកោណសមបាត $ABC$ យើងបាន :

$h = \sqrt{x^2 - (p-x)^2} = \sqrt{2px - p^2}; 2px - p^2 \geq 0 \Rightarrow x \geq \frac{p}{2}$

មាឌនៃសូលីតជាកោណដែលមានផ្ទៃបាត $\pi r^2 = \pi (p-x)^2$

និងកម្ពស់ $h$ គឺ : $V = \frac{1}{3}\pi r^2 h = \frac{1}{3}\pi\sqrt{2px - p^2} \times (p-x)$

$$= \frac{\pi\sqrt{p}}{3}\sqrt{2x-p}\,(p-x)^2$$

$$\Rightarrow V' = \frac{\pi\sqrt{p}}{3}\left[-2(p-x)\sqrt{2x-p} + \frac{(p-x)^2}{\sqrt{2x-p}}\right]$$

$$= \frac{\pi\sqrt{p}}{3}\left(\frac{5x^2 - 8px + 3p^2}{\sqrt{2x-p}}\right)$$

$$V' = 0 \Rightarrow 5x^2 - 8px + 3p^2 = 0 \Rightarrow x = \frac{3p}{5}; x = p$$

តារាងសញ្ញា :

| $x$ | $\frac{p}{2}$ | | $\frac{3p}{5}$ | | $p$ |
|---|---|---|---|---|---|
| $V'$ | | $+$ | $0$ | $-$ | |
| $V$ | | $\nearrow$ | | $\searrow$ | |

យើងឃើញថា $V$ មានតម្លៃអតិបរមាត្រង់ $x = \frac{3p}{5}$ យើងបាន :

$$r = \frac{2p}{5}; BC = \frac{4p}{5}; h = \sqrt{2p \times \frac{3p}{5} - p^2} = \sqrt{\frac{p^2}{5}} = \frac{p\sqrt{5}}{5}$$

ដូចនេះ $\boxed{AB = AC = \frac{3p}{5}; BC = \frac{4p}{5}; AH = \frac{p\sqrt{5}}{5}}$

7- រថយន្តមួយចាប់ផ្តើមចេញដំណើរ ពីចំណុចត្រួតពិនិត្យមួយ ។ នៅខណៈ $t$ វិនាទីរថយន្តនោះឃ្លាតពីចំនុចត្រួតពិនិត្យ ដែលតាងដោយអនុគមន៍ចម្ងាយចរ $S(t) = 4.4t^2$ គិតជាម៉ែត្រហើយ $0 \le t \le 10$

ប្រើអនុគមន៍ខាងលើ រួចបំពេញតារាងខាងក្រោម:

| t | 0 | 2 | 4 | 6 | 8 | 10 |
|---|---|---|---|---|---|---|
| $S(t)$ | | | | | | |
| $V(t)$ | | | | | | |
| $a(t)$ | | | | | | |

## សំរាយបញ្ជាក់ :

បំពេញតារាងដោយប្រើ $S(t)=4.4t^2$ យើងបាន :

$v(t)=8.8t$ និង $a(t)=8.8$

| t | 0 | 2 | 4 | 6 | 8 | 10 |
|---|---|---|---|---|---|---|
| $S(t)$ | 0 | 17.6 | 70.4 | 158.4 | 281.6 | 440 |
| $V(t)$ | 0 | 17.6 | 35.2 | 52.8 | 70.4 | 88 |
| $a(t)$ | 8.8 | 8.8 | 8.8 | 8.8 | 8.8 | 8.8 |

**ជំពូក ៣** **សិក្សាអថេរភាព និងសង់ក្រាប**

## មេរៀនទី១ : អនុគមន៍សនិទាន

### លំហាត់ :

1- រកអាស៊ីមតូតនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{x^2+4x+1}{x+2}$ ខ. $y=\dfrac{x^2+3x+1}{x^2-1}$

គ. $y=-x+3+\dfrac{3}{x-1}$

### សំរាយបញ្ជាក់ :

រកអាស៊ីមតូតនៃអនុគមន៍ខាងក្រោម:

ក. យើងមាន : $y=\dfrac{x^2+4x+1}{x+2}=x+2-\dfrac{3}{x+2}$

ដោយ $\lim\limits_{x\to\pm\infty}\dfrac{3}{x+2}=0$ នោះយើងបាន បន្ទាត់ $y=x+2$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង ។

ម្យ៉ាងទៀត $\lim\limits_{x\to-2}f(x)=\infty$ នោះ $x=-2$ ជាអាស៊ីមតូតឈរ

ខ. $y=\dfrac{x^2+3x+1}{x^2-1}$

យើងមាន $\lim\limits_{x\to\pm1}f(x)=\lim\limits_{x\to\pm1}\dfrac{x^2+3x+1}{x^2-1}=\infty$

នោះយើងបានបន្ទាត់ $x=\pm 1$ ជាអាស៊ីមតូតឈរនៃខ្សែកោង $(C)$ ·

ម្យ៉ាងទៀត $\lim_{x\to\infty} f(x)=1$ នោះបន្ទាត់ $y=1$ ជាអសីុមតូតដេក

គ. $y=-x+3+\dfrac{3}{x-1}$

យើងបាន $\lim_{x\to 1} f(x)=\infty$ នោះ $x=1$ ជាអសីុមតូតឈរក្រាប $(C)$

ម្យ៉ាងទៀត $\lim_{x\to\infty}\left[f(x)-(-x+3)\right]=0$ នោះ $y=-x+3$

ជាអសីុមតូតទ្រេត ។

2- សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{x^2-2x+6}{2x+2}$ ខ. $y=\dfrac{x^2-4x+3}{x^2-3x+2}$

គ. $y=\dfrac{x^2-9}{4-x^2}$

**សំរាយបញ្ជាក់ :**

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. យើងមាន : $y=\dfrac{x^2-2x+6}{2x+2}=\dfrac{x}{2}-\dfrac{3}{2}+\dfrac{9}{2x+2}$

+ **ដែនកំណត់ :** $D=IR-\{-1\}$

+ **ទិសដៅអថេរភាព :**

**- ដេរីវេទី១ :** $y'=\frac{(2x-2)(2x+2)-2(x^2-2x+6)}{(2x+2)^2}$

$$y'=\frac{4x^2-4-2x^2+4x-12}{(2x+2)^2}=\frac{2(x^2+2x-8)}{(2x+2)^2}$$

$$y'=0\Rightarrow x^2+2x-8=0\Rightarrow x=2;x=-4$$

សញ្ញាដេរីវេ :

| $x$ | $-\infty$ | $-4$ | | $-1$ | | $2$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | + | 0 | − | ‖ | − | 0 | + |

**+ចំណុចបរមា :**

- អនុគមន៏ $f$ មានអតិបរមានៅត្រង់ $x=-4$ ដែល $f(-4)=-5$

- អនុគមន៏ $f$ មានអប្បបរមានៅត្រង់ $x=2$ ដែល $f(2)=1$

**+ លីមីត :**

$$\lim_{x\to\pm\infty}f(x)=\lim_{x\to\pm\infty}\frac{x^2-2x+6}{2x+2}=\pm\infty$$

$$\lim_{x\to-1}f(x)=\lim_{x\to\pm\infty}\frac{x^2-2x+6}{2x+2}=\pm\infty$$

**+ អាស៊ីមតូត :**

ដោយ $\lim_{x\to-1}f(x)=\pm\infty$ យើងបានបន្ទាត់ $x=-1$ ជាអាស៊ីមតូត

ឈរនៃក្រាប $(C)$ ។

ម្យ៉ាងទៀត $\lim_{x\to\pm\infty}\left[f(x)-\left(\frac{x}{2}-\frac{3}{2}\right)\right]=0$ នោះ $y=\frac{x}{2}-\frac{3}{2}$

ជាអាស៊ីមតូត ទ្រេត ។

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $-4$ | | $-1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | \|\| | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $-5$ | ↘ | $-\infty$ \|\| $+\infty$ | ↘ | $1$ | ↗ | $+\infty$ |

\+ **សំណង់ខ្សែកោង :**

\- ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស$(x'ox)$ :

$\Rightarrow y=0\Rightarrow x^2-2x+6=0;\Delta'=1-6=-5<0$

សមីការគ្មានឬស បញ្ជាក់ថាខ្សែកោងមិនកាត់អក្សអាប់ស៊ីសទេ ។

\- ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស$(y'oy)\Rightarrow x=0;y=3$

\- **ផ្ចិតឆ្លុះ:** ជាចំណុចប្រសព្វរវាងអាស៊ីមតូតឈរ និងអាស៊ីមតូត

ទ្រេត ដែលកំណត់ដោយ $I(-1,-2)$

តាមរូបមន្ត $f(2a-x)+f(x)=2b$ នោះយើងបាន :

$f(-2-x)+f(x)=-4$ នោះចំណុច$I(-1,-2)$ជាផ្ចិតឆ្លុះ

នៃក្រាប ។ **សង់ក្រាប :**




៣. បើ $x \neq 1$: $y=\frac{x^2-4x+3}{x^2-3x+2}=\frac{(x-1)(x-3)}{(x-1)(x-2)}=\frac{x-3}{x-2}$

- ដែនកំណត់ : $D = IR-\{1;2\}$

- **ទិសដៅអថេរភាព :**

-**ដេរីវេទី១ :** $y'=\frac{1}{(x-2)^2}>0\ ;\forall x \in D_f$

ដោយ $y'>0 \forall x \in D$ នោះបញ្ជាក់ថា $f$ ជាអនុគមន៍កើនជានិច្ច ហើយគ្មានចំនុចបរមាទេ ។

- **លីមីត និង អាស៊ីមតូត :**

$\lim_{x\to 1} f(x)=\infty ; \lim_{x\to 2} f(x)=\infty$ នោះបន្ទាត់ $x=1$ និង $x=2$ ជា

អាស៊ីមតូតឈរ ។

$\lim\limits_{x\to\pm\infty} f(x)=1$ នោះបន្ទាត់ $y=1$ ជាអាស៊ីមតូតដេក ។

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $+$ | ‖ | $+$ | ‖ | $+$ | |
| $y$ | $1$ | ↗ $+\infty$ | ‖ $-\infty$ | ↗ $+\infty$ | ‖ $-\infty$ | ↗ | $1$ |

**សង់ក្រាប :**




គ. $y=\dfrac{x^2-9}{4-x^2}$

+ **ដែនកំណត់ :** $D=IR-\{-2;2\}$

+ **ទិសដៅអថេរភាព :**

-ដេរីវេ $y' = \dfrac{2x(4-x^2)+2x(x^2-9)}{(4-x^2)^2} = \dfrac{-10x}{(4-x^2)^2}$

$\Rightarrow y' = 0 \Rightarrow x = 0; y = -\dfrac{9}{4}$

| $x$ | $-\infty$ | $-2$ | | $0$ | | $2$ | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ |

**ចំនុចបរមា :**

- អនុគមន៍ $f$ អតិបរមានៅត្រង់ $x=0$ ដែល $f(0) = -\dfrac{9}{4}$

**- លីមីត និង អាស៊ីមតូត :**

$\lim\limits_{x\to -2} f(x) = \infty; \lim\limits_{x\to 2} f(x) = \infty$ នោះបន្ទាត់ $x=-2$ និង

$x = 2$ ជាអាស៊ីមតូតឈរ ។

$\lim\limits_{x\to \pm\infty} f(x) = -1$ នោះបន្ទាត់ $y=-1$ ជាអាស៊ីមតូតទ្រេត ។

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $-2$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | ‖ | $+$ | $0$ | $-$ | ‖ | $-$ | |
| $f(x)$ | $1$ ↗ | | $+\infty$ ‖ $-\infty$ | ↗ | $-\dfrac{9}{4}$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $1$ |

**+ សំណង់ក្រាប :**

- ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស$(x'ox)$: $y=0 \Rightarrow x = \pm 3$

- ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស$(y'oy)$ : $x=0 \Rightarrow y=-\dfrac{9}{4}$

ដោយ $f(-x)=\dfrac{(-x)^2-9}{4-(-x)^2}=\dfrac{x^2-9}{4-x^2}=f(x)$

ដោយ $f(-x)=f(x)$ នោះ $f(x)$ ជាអនុគមន៍គូនាំអោយ $f(x)$

មានអ័ក្ស $(y'y)$ ជាអ័ក្សឆ្លុះ ។

**សង់ក្រាប :**




3- **ក.** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y=\dfrac{x^2-4x+8}{x-2}$

**ខ.** សិក្សាទៅតាមតម្លៃ $m$ អត្ថិភាព និងសញ្ញាឫសសមីការ :

$x^2-(m+4)x+2m+8=0$ ដោយប្រើក្រាបតាង $y$ ។

**សំរាយបញ្ជាក់ :**

**ក.** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍

យើងមាន : $y=\dfrac{x^2-4x+8}{x-2}$ មាន :

**+ដែនកំណត់** : $D=IR-\{2\}$

**+ទិសដៅអថេរភាព :**

- ដេរីវេទី១ :

$$y'=\frac{(2x-4)(x-2)-\left(x^2-4x+8\right)}{(x-2)^2}=\frac{x^2-4x}{(x-2)^2}$$

$y'=0\Rightarrow x=0;x=4$

សញ្ញាដេរីវេ :

| $x$ | $-\infty$ | | 0 | | 2 | | 4 | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | + | 0 | − | ‖ | − | 0 | + | |

**ចំនុចបរមា :**

- អនុគមន៍ $f$ មានអតិបរមានៅត្រង់ $x=0$ ដែល $f(0)=-4$

- អនុគមន៍ $f$ មានអប្បបរមានៅត្រង់ $x=4$ ដែល $f(4)=4$

**+លីមីត និងអាស៊ីមតូត :**

$\lim\limits_{x\to 2} f(x)=\infty$ នោះយើងបាន បន្ទាត់ $x=2$ ជាអាស៊ីមតូតឈរ

ម្យ៉ាងទៀត $\lim\limits_{x\to\pm\infty}\left[f(x)-(x-2)\right]=0$ នោះ យើងបានបន្ទាត់

$y=x-2$ ជាអាស៊ីមតូតទ្រេត

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $0$ | | $2$ | | $4$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ ↗ | | $-4$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $4$ | ↗ $+\infty$ | |

**សង់ក្រាប :**




**ខ.** សិក្សាទៅតាមតម្លៃ $m$ អត្ថិភាព និងសញ្ញាឫសសមីការ :

$x^2-(m+4)x+2m+8=0$ ដោយប្រើក្រាបតាង $y$ :

យើងមាន : $x^2-(m+4)x+2m+8=0 \Rightarrow \dfrac{x^2-4x+8}{x-2}=m$

ជាសមីការអាប់ស៊ីសរវាងក្រាបនិងបន្ទាត់ដេក $y=m$ ។

តាមក្រាបយើងបាន :

-បើ $m<-4$ សមីការមានឫសពីរសញ្ញាផ្ទុយគ្នា $x_1<0<x_2$

-បើ $m=-4$ សមីការមានឫសឌុប $x_1=x_2=0$

-បើ $-4<m<4$ សមីការគ្មានឫស

-បើ $m=4$ សមីការមានឫសឌុប $x_1=x_2=4$

-បើ $m>4$ សមីការមានឫសពីរសញ្ញាវិជ្ជមាន $0<x_1<x_2$

**4-** កំណត់តម្លៃ $a$ ដើម្បីឱ្យអនុគមន៍ $y=\dfrac{x^2-2ax+3a^2}{x-2a}$ កើនលើចន្លោះ $(1;+\infty)$ ។

**សំរាយបញ្ជាក់ :**

កំណត់តម្លៃ $a$

យើងមាន : $y=\dfrac{x^2-2ax+3a^2}{x-2a}$ នោះយើងបាន :

$$y'=\frac{(2x-2a)(x-2a)-\left(x^2-2ax+3a^2\right)}{(x-2a)^2}=\frac{x^2-4ax+a^2}{(x-2a)^2}$$

ដើម្បីអនុគមន៍ $y$ ឱ្យកើនលើចន្លោះ $(1;+\infty)$ លុះត្រាតែ $y'>0$

ដោយ $y'=0\Leftrightarrow f'(x)=x^2-4ax+a^2=0$

$\Delta' = 4a^2 - a^2 = 3a^2 \geq 0$

$x_1 = 2a + a\sqrt{3}; x_2 = 2a - a\sqrt{3}$

- បើ $a \geq 0 \Rightarrow x_1 \geq x_2$

| $x$ | | $x_2$ | | $x_1$ | |
|---|---|---|---|---|---|
| $f'(x)$ | + | 0 | − | 0 | + |

យើងបាន $y$ កើនចំពោះ $1 \leq x$ លុះត្រាតែ :

$2a + a\sqrt{3} \leq 1 \Rightarrow a \leq \frac{1}{2+\sqrt{3}} = 2 - \sqrt{3}$ និង $a \geq 0$ នោះ

$a \in \left[0, 2-\sqrt{3}\right]$ (1)

- បើ $a < 0 \Rightarrow x_1 < x_2$

| $x$ | | $x_1$ | | $x_2$ | |
|---|---|---|---|---|---|
| $f'(x)$ | + | 0 | − | 0 | + |

យើងបាន $y$ កើនចំពោះ $1 \leq x$ លុះត្រាតែ

$2a - a\sqrt{3} \leq 1 \Rightarrow a \leq \frac{1}{2-\sqrt{3}} = 2 + \sqrt{3}$ និង $a < 0$ នោះ

$a \in (-\infty; 0)$ . (2)

យក $(1) \cup (2)$ យើងបាន $\boxed{a \leq 2 - \sqrt{3}}$

5- គេឱ្យអនុគមន៍ : $y = \frac{mx^2 + 3mx + 2m + 1}{x + 2}$ ។

**ក.** ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេត កាត់តាមចំណុចនឹងមួយ

ចំពោះគ្រប់ប៉ារ៉ាម៉ែត $m$ ដែលត្រូវកំណត់កូអរដោនេ ។

**ខ.** រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y = m$ ប៉ះនឹងក្រាប ។

**គ.** សិក្សាអថេរភាព និងសង់ក្រាបចំពោះ $m = -1$ ។

## សំរាយបញ្ជាក់ :

**ក.** ស្រាយបញ្ជាក់ថា អាស៊ីមតូតទ្រេត កាត់តាមចំណុចនឹងមួយចំពោះគ្រប់ប៉ារ៉ាម៉ែត $m$ ដែលត្រូវកំណត់កូអរដោនេ :

យើងមាន $y = \dfrac{mx^2 + 3mx + 2m + 1}{x+2} = mx + m + \dfrac{1}{x+2}$

ដោយ $\lim\limits_{x\to\infty} \dfrac{1}{x+2} = 0$ នោះយើងបានបន្ទាត់ $y = mx + m$ ជាអាស៊ីមតូតទ្រេតនៃខ្សែកោង ។ ផ្ទៀងផ្ទាត់គ្រប់តម្លៃ $m$ យើងបាន :

$$y = mx + m \Leftrightarrow m(x+1) - y = 0$$

$$\begin{cases} x+1=0 \\ y=0 \end{cases} \Rightarrow x=-1; y=0$$

ដូចនេះ $\boxed{x=-1; y=0}$

**ខ.** រកតម្លៃ $m$ ដើម្បីឱ្យបន្ទាត់ $y = m$ ប៉ះនឹងក្រាប :

សមីការអាប់ស៊ីសរវាងក្រាបនឹងបន្ទាត់ $y = m$ កំណត់ដោយ:

$$\frac{mx^2+3mx+2m+1}{x+2}=m \Rightarrow mx^2+3mx+2m+1=xm+2m$$

$\Rightarrow mx^2+2mx+1=0 \Leftrightarrow \Delta'=m^2-m$

បន្ទាត់ប៉ះនឹងក្រាបលុះត្រាតែ :

$\Delta'=0 \Rightarrow m(m-1)=0 \Rightarrow m=0; m=1$

តែ $m=0 \Rightarrow y=\dfrac{1}{x+2}$ បើ $y=0 \Rightarrow \dfrac{1}{x+2}=0$ គ្មានឫស

ដូចនេះ $\boxed{m=1}$

គ. សិក្សាអថេរភាព និងសង់ក្រាបចំពោះ $m=-1$

ចំពោះ $m=-1 \Rightarrow y=\dfrac{-x^2-3x-1}{x+2}=-x-1+\dfrac{1}{x+2}$

**+ដែនកំណត់ :** $D=IR-\{-2\}$

**+ទិសដៅអថេរភាព :**

-ដេរីវេ $y'=\dfrac{(-2x-3)(x+2)-(-x^2-3x-1)}{(x+2)^2}=\dfrac{-x^2-4x-5}{(x+2)^2}$

$y'=0 \Rightarrow -x^2-4x-5=0; \Delta'=4-5=-1<0$ គ្មានឫស

នោះយើងបានអនុគមន៍ $f$ ចុះជានិច្ច និងគ្មានចំនុចបរមាទេ ។

**+លីមីត និងអាស៊ីមតូត :**

$\lim\limits_{x\to -2} f(x) = \lim\limits_{x\to -2}\dfrac{-x^2-3x-1}{x+2} = \infty$ នោះ $x = -2$ ជាអាស៊ីមតូតឈរ ។

ម្យ៉ាងទៀត $\lim\limits_{x\to \pm\infty}\left[f(x)-(-x-1)\right] = 0$ នោះយើងបានបន្ទាត់ $y = -x-1$ ជាអាស៊ីតតូតទ្រេត ។

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $-2$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $-$ | |
| $y$ | $+\infty$ ↘ | $-\infty$ | ‖ | $+\infty$ ↘ | $-\infty$ |

**+ សំណង់ខ្សែកោង :**

-ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស $(x'ox)$: $y=0 \Rightarrow x = \dfrac{-3\pm\sqrt{5}}{2}$

-ចំណុចប្រសព្វរវាងក្រាបនឹងអ័ក្ស $(y'oy)$: $x=0 \Rightarrow y = -\dfrac{1}{2}$



6- គេឱ្យអនុគមន៍ : $y=\frac{x^2+2(m+1)x+2}{x+1}$ ។

ក. ចំពោះ $m=0$ សិក្សាអថេរភាពនិងសង់ក្រាប $C$ របស់អនុគ ខាងលើ រួចរកតម្លៃរបស់ $a$ ដើម្បីឱ្យក្រាប $(C)$ ប៉ះនឹងបះ $(P): y=-x+a$ ។

ខ. រកតម្លៃ $m$ ដើម្បីឱ្យអនុគមន៍កើនលើចន្លោះ $[0;+\infty)$ ។

**សំរាយបញ្ជាក់ :**

ក.សិក្សាអថេរភាព និងសង់ក្រាប $m=0$

យើងមាន $y=\frac{x^2+2(m+1)x+2}{x+1}$ ចំពោះ $m=0$

យើងបាន $f(x)=\frac{x^2+2x+2}{x+1}=x+1+\frac{1}{x+1}$

+ **ដែនកំណត់ :** $D=IR-\{-1\}$

+ **ទិសដៅអថេរភាព :**

- ដេរីវេទី១ : $f'(x)=\frac{x^2+2x}{(x+1)^2}$

ដោយ $(x+1)^2>0 \forall x\in D_f$ នោះយើងបាន :

$f'(x)=0 \Leftrightarrow x^2+2x=0 \Rightarrow x=0; x=-2$

**សញ្ញាដេរីវេ :**

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |

**ចំនុចបរមា :**

- អនុគមន៍ $f$ មានអតិបរមានៅត្រង់ $x=-2$ ដែល $f(-2)=-2$

- អនុគមន៍ $f$ មានអប្បបរមានៅត្រង់ $x=0$ ដែល $f(0)=2$

**+លីមីត និងអាស៊ីមតូត :**

$\lim\limits_{x\to-1} f(x)=\infty$ នោះយើងបានបន្ទាត់ $x=-1$ ជាអាស៊ីមតូតឈរ

ម្យ៉ាងទៀត $\lim\limits_{x\to\pm\infty}\left[f(x)-(x+1)\right]=0$ នោះ យើងបានបន្ទាត់

$y=x+1$ ជាអាស៊ីមតូតទ្រេត

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | ↗ | $-2$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $2$ | ↗ | $+\infty$ |

**+សង់ក្រាប**




+រកតម្លៃរបស់ $a$ :

សមីការអាប់ស៊ីសរវាងក្រាប $C$ និងបន្ទាត់ $P$ កំណត់ដោយៈ

$$\frac{x^2+2x+2}{x+1}=-x^2+a$$

$$\Rightarrow x^3+2x^2+(x+1)(2-a)=0$$

ដើម្បីឱ្យក្រាប $C$ ប៉ះនឹងបន្ទាត់ $P$ លុះត្រាតែសមីការមានឫសឌុប

យើងបាន : $2-a=0 \Rightarrow a=2$

ដូចនេះ យើងបាន : $\boxed{a=2}$

**ខ.** រកតម្លៃ $m$ ដើម្បីឱ្យអនុគមន៍កើនលើចន្លោះ $[0;+\infty)$

ដោយ $y=\dfrac{x^2+2(m+1)x+2}{x+1}$ នោះយើងបាន :

$$' = \frac{(2x+2m+2)(x+1)-(x^2+2mx+2x+2)}{(x+1)^2}$$

$$= \frac{2x^2+2x+2mx+2m+2x+2-x^2-2mx-2x-2}{(x+1)^2}$$

$$= \frac{x^2+2x+2m}{(x+1)^2}$$

ម្បីឱ្យ $y$ កើនលើ $[0,+\infty)$ លុះត្រាតែ $y'>0$ លើចន្លោះ $[0,+\infty)$

បើងបាន : $x^2+2x+2m>0$ មាន $\Delta'=1-2m$

បើ $\Delta'<0 \Rightarrow m>\frac{1}{2}$ នោះ $y'$ យកសញ្ញាតាម $a=1>0$

ាះ $y'>0$ គ្រប់តម្លៃ $x$ (1) ។

បើ $\Delta'>0 \Rightarrow m<\frac{1}{2}$ យើងបានតារាងសញ្ញា :

| $x$ | | $-1-\sqrt{1-2m}$ | | $-1+\sqrt{1-2m}$ | |
|---|---|---|---|---|---|
| $y'$ | + | 0 | − | 0 | + |

កើនលើ $[0,+\infty)$ នោះ $-1+\sqrt{1-2m}\le 0 \Rightarrow m\ge 0$ (2)

ម (1) និង (2) យើងបាន $m\ge 0$

ដូច្នេះ $\boxed{m\ge 0}$

7- ចូររកតម្លៃបរមាធៀបរបស់អនុគមន៍ $y=\frac{20x^2+10x+3}{3x^2+2x+1}$ ។

**សំរាយបញ្ជាក់ :**

រកតម្លៃបរមាធៀបរបស់អនុគមន៍

យើងមាន : $y=\frac{20x^2+10x+3}{3x^2+2x+1}$

មានន័យកាលណា $3x^2+2x+1\neq 0$

ដោយ $\Delta=4-12=-8<0\Rightarrow 3x^2+2x+1>0\forall x\in IR$

ដូចនេះ ដែនកំណត់នៃអនុគមន៍គឺ $D=IR$

នោះយើងបាន :

$$y'=\frac{(40x+10x)(3x^2+2x+1)-(6x+2)(20x^2+10x+3)}{(3x^2+2x+1)^2}$$

$$=\frac{10x^2+22x+4}{(3x^2+2x+1)^2}$$

ដោយ $3x^2+2x+1>0\forall x\in IR$ នោះយើងបាន :

$y'=0\Rightarrow 10x^2+22x+4=0\Rightarrow x_1=2;x_2=-\frac{1}{5}$

បើ $x=2\Rightarrow y=7$ និង $x=-\frac{1}{5}\Rightarrow y=\frac{5}{2}$

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $-\frac{1}{5}$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $\frac{5}{2}$ | $\searrow$ | $7$ | $\nearrow$ | $+\infty$ |

**ចំនុចបរមា :**

- អនុគមន៍ $f$ មានអតិបរមានៅត្រង់ $x=-\frac{1}{5}$ ដែល $f(-\frac{1}{5})=\frac{5}{2}$
- អនុគមន៍ $f$ មានអប្បបរមានៅត្រង់ $x=2$ ដែល $f(2)=7$

ដូចនេះ តម្លៃបរិមាគឺ 7 និង $\frac{5}{2}$

8- ចូរកតម្លៃបរមាធៀបរបស់អនុគមន៍ :

$y=x^2+2x+1+\frac{a^2}{(x+1)^2}$ ។ដែល $a$ ជាប៉ារ៉ាម៉ែតខុសពីសូន្យ ។

**សំរាយបញ្ជាក់ :**

យើងមាន : $y=x^2+2x+1+\frac{a^2}{(x+1)^2}$

នោះយើងបាន :

$$y' = 2x+2-\frac{a^2\times 2(x+1)}{(x+1)^4} = \frac{2(x+1)\left[(x+1)^4-a^2\right]}{(x+1)^4}$$

$$= \frac{2(x+1)\left[(x+1)^2-a\right]\left[(x+1)^2+a\right]}{(x+1)^4}$$

$$= \frac{2(x+1)\left(x^2+2x+1-a\right)\left(x^2+2x+1+a\right)}{(x+1)^4}$$

$$y'=0 \Rightarrow \begin{cases} x^2+2x+1-a=0 & (1) \\ x^2+2x+1+a=0 & (2) \end{cases}$$

សមីការ $(1): \Delta' = 1-1+a = a$

សមីការ $(2): \Delta' = 1-1-a = -a$

- បើ $a>0$ សមីការ (1) មានឫសពីរគឺ :

$x_1 = -1+\sqrt{a}; y = 2a$ និង $x_2 = -1-\sqrt{a}; y = 2a$

យើងបាន តម្លៃបរមាគឺ $2a$

- បើ $a<0$ សមីការ (2) មានឫសពីរគឺ :

$x_1 = -1+\sqrt{-a}; y = -2a$ និង $x_2 = -1-\sqrt{-a}; y = -2a$

យើងបាន តម្លៃបរមាគឺ $-2a$

ដូចនេះ តម្លៃបរមានៃអនុគមន៍គឺ $\boxed{2|a|}$

9- សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ $y = x+1+\frac{1}{x+1}$ ។

**សំរាយបញ្ជាក់ :**

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍

យើងមាន : $y = x+1+\frac{1}{x+1}$

+ **ដែនកំណត់** : $D = IR-\{-1\}$

+ **ទិសដៅអថេរភាព :**

- ដេរីវេទី១ : $f'(x) = \frac{x^2+2x}{(x+1)^2}$

ដោយ $(x+1)^2 > 0 \forall x \in D_f$ នោះយើងបាន :

$f'(x)=0 \Leftrightarrow x^2+2x=0 \Rightarrow x=0; x=-2$

**សញ្ញាដេរីវេ :**

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | + | 0 | − | ‖ | − | 0 | + | |

**ចំនុចបរមា :**

- អនុគមន៍ $f$ មានអតិបរមានៅត្រង់ $x=-2$ ដែល $f(-2)=-2$

- អនុគមន៍ $f$ មានអប្បបរមានៅត្រង់ $x=0$ ដែល $f(0)=2$

+ **លីមីត និងអាស៊ីមតូត :**

$\lim\limits_{x\to-1} f(x)=\infty$ នោះយើងបានបន្ទាត់ $x=-1$ ជាអាស៊ីមតូតឈរ

ម្យ៉ាងទៀត $\lim\limits_{x\to\pm\infty}[f(x)-(x+1)]=0$ នោះ យើងបានបន្ទាត់

$y=x+1$ ជាអាស៊ីមតូតទ្រេត ។

**តារាងអថេរភាព :**

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | + | 0 | − | ‖ | − | 0 | + | |
| $y$ | $-\infty$ | ↗ | $-2$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $2$ | ↗ | $+\infty$ |

**+សង់ក្រាប**




**10-**គេឱ្យ $C_m$ ជាក្រាបតាងអនុគមន៍ $y=x+1+\dfrac{4}{(x+m)^2}$ ។

**ក.** តើមានក្រាប $C_m$ ចំនួនប៉ុន្មាន ដែលកាត់តាមចំណុច $A(1;3)$ ។

ខ. ស្រាយបញ្ជាក់ថា បន្ទាត់ប៉ះនឹងក្រាប $C_m$ ត្រង់ចំណុចមានអាប់ស៊ីស $x = 2-m$ ស្របនឹងអ័ក្ស $Ox$ ។

## សំរាយបញ្ជាក់ :

ក. តើមានក្រាប $C_m$ ចំនួនប៉ុន្មាន ដែលកាត់តាមចំណុច $A(1;3)$

យើងមាន : $y = x+1+\dfrac{4}{(x+m)^2}$

ដោយ $C_m$ កាត់តាមចំនុច $A(1;3)$ នោះយើងយកកូអរដោនេរបស់ $A$ ទៅជំនួសក្នុង $y$ យើងបាន :

$3 = 1+1+\dfrac{4}{(1+m)^2} \Rightarrow (1+m)^2 = 4$

$\Rightarrow 1+m = \pm 2 \Rightarrow m = 1; m = -3$

- បើ $m = 1 \Rightarrow y = x+1+\dfrac{4}{(x+1)^2}$

- បើ $m = -3 \Rightarrow y = x+1+\dfrac{4}{(x-3)^2}$

ខ. ស្រាយថា បន្ទាត់ប៉ះត្រង់ $x = 2-m$ ស្របនឹងអ័ក្សអាប់ស៊ីស

ដោយ $y = x+1+\dfrac{4}{(x+m)^2} \Rightarrow y' = 1-\dfrac{8}{(x+m)^3}$

ត្រង់ $x=2-m$ យើងបាន $y'=1-\dfrac{8}{(2-m+m)^2}=0$

យើងបាន បន្ទាត់មានមេគុណប្រាប់ទិសស្មើនឹង 0 នោះបន្ទាត់ស្រប

នឹង អក្ស័អាប់ស៊ីស ។

**មេរៀនទី២ :** **អនុគមន៍អិចស្ប៉ូណង់ស្យែល**

**លំហាត់ :**

**1-** គណនាលីមីតខាងក្រោម:

**ក.** $\lim_{x \to +\infty} e^{3x}$ **ខ.** $\lim_{x \to -\infty} e^{5x}$ **គ.** $\lim_{x \to +\infty} 6e^{2x}$

**សំរាយបញ្ជាក់ :**

គណនាលីមីតខាងក្រោម:

**ក.** $\lim_{x \to +\infty} e^{3x} = +\infty$ **ខ.** $\lim_{x \to -\infty} e^{5x} = 0$ **គ.** $\lim_{x \to +\infty} 6e^{2x} = +\infty$

**2-** គណនាលីមីតខាងក្រោម:

**ក.** $\lim_{x \to +\infty} xe^{x+1}$ **ខ.** $\lim_{x \to -\infty} x^2e^{4x}$ **គ.** $\lim_{x \to +\infty}\left(1+\frac{n}{x}\right)^x$

**សំរាយបញ្ជាក់ :**

**ក.** $\lim_{x \to +\infty} xe^{x+1} = +\infty$ **ខ.** $\lim_{x \to -\infty} x^2e^{4x} = 0$

**គ.** $$\lim_{x \to +\infty}\left(1+\frac{n}{x}\right)^x = \lim_{x \to +\infty}\left[\left(1+\frac{1}{\frac{x}{n}}\right)^{\frac{x}{n}}\right]^n = e^n$$

3- គណនាលីមីតនៃអនុគមន៍ខាងក្រោម:

ក. $\lim_{x\to+\infty}\frac{3e^{x-2}}{x^3}$ ខ. $\lim_{x\to+\infty}\left(\frac{x+3}{x-1}\right)^{x+2}$ គ. $\lim_{x\to0}\left(\frac{e^x-e^{-x}}{x}\right)$

## សំរាយបញ្ជាក់ :

គណនាលីមីតនៃអនុគមន៍ខាងក្រោម:

ក. $\lim_{x\to+\infty}\frac{3e^{x-2}}{x^3}=\lim_{x\to+\infty}3e^{-2}\left(\frac{e^x}{x^3}\right)=+\infty$

ខ. $\lim_{x\to+\infty}\left(\frac{x+3}{x-1}\right)^{x+2}=\lim_{x\to+\infty}\left[\left(1+\frac{4}{x-1}\right)^{\frac{x-1}{4}}\right]^{\frac{4(x+2)}{x-1}}$

$=e^{\lim\limits_{x\to+\infty}\frac{4x+8}{x-1}}=e^4$

គ. $\lim_{x\to0}\left(\frac{e^x-e^{-x}}{x}\right)=\lim_{x\to0}\left(\frac{e^{2x}-1}{xe^x}\right)$

$=\lim_{x\to0}\left[\frac{(e^x-1)(e^x+1)}{xe^x}\right]=\lim_{x\to0}\frac{(e^x-1)}{x}\times\frac{e^x+1}{e^x}=1\times2=2$

ព្រោះ $=\lim_{x\to0}\frac{e^{ax}-1}{x}=a$

4- គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=xe^{-x}$ ខ. $f(x)=x^2e^x$ គ. $g(x)=\frac{e^x-e^{-x}}{e^x+e^{-x}}$

## សំរាយបញ្ជាក់ :

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

**ក.** $y = xe^{-x} \Rightarrow y' = e^{-x} - xe^{-x} = e^{-x}(1-x)$

**ខ.** $f(x) = x^2e^x \Rightarrow f'(x) = 2xe^x + x^2e^x = e^x(x^2+2x)$

**គ.** $g(x) = \dfrac{e^x - e^{-x}}{e^x + e^{-x}}$

$$g'(x) = \frac{(e^x+e^{-x})(e^x+e^{-x}) - (e^x-e^{-x})(e^x-e^{-x})}{(e^x+e^{-x})^2}$$

$$= \frac{e^{2x} + e^x.e^{-x} + e^{-x}.e^x + e^{-2x} - e^{2x} + e^{-x}.e^x + e^{-x}.e^x - e^{-2x}}{(e^x+e^{-x})^2}$$

$$= \frac{e^0+e^0+e^0+e^0}{(e^x+e^{-x})^2} = \frac{1+1+1+1}{(e^x+e^{-x})^2} = \frac{4}{(e^x+e^{-x})^2}$$

5- គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

**ក.** $y = \dfrac{e^x + e^{-x}}{2}$ **ខ.** $f(x) = \dfrac{e^x(1+\cos x)}{1-\cos x}$

**គ.** $g(x) = e^{\frac{x-1}{x+1}}$

## សំរាយបញ្ជាក់ :

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{e^x+e^{-x}}{2}\Rightarrow y'=\dfrac{e^x-e^{-x}}{2}$

ខ. $f(x)=\dfrac{e^x(1+\cos x)}{1-\cos x}$ នោះយើងបាន

$$\Rightarrow f'(x)=\frac{\left[e^x(1+\cos x)\right]'(1-\cos x)-(1-\cos x)'\left[e^x(1+\cos x)\right]}{(1-\cos x)^2}$$

$$=\frac{\left[e^x(1+\cos x)-e^x\sin x\right](1-\cos x)-\sin x\left[e^x(1+\cos x)\right]}{(1-\cos x)^2}$$

$$=\frac{e^x\left(1-2\sin x-\cos^2 x\right)}{(1-\cos x)^2}=\frac{e^x\sin x(\sin x-2)}{(1-\cos x)^2}$$

គ. $g(x)=e^{\frac{x-1}{x+1}}\Rightarrow g'(x)=\left(\dfrac{x-1}{x+1}\right)'e^{\frac{x-1}{x+1}}=\dfrac{2}{(x+1)^2}e^{\frac{x-1}{x+1}}$

6- សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y=x^2e^{-x}$  ខ. $y=5+2e^{-x}$

គ. $g(x)=e^x-x^2$

## សំរាយបញ្ជាក់ :

សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

**ក.** $y = x^2 e^{-x}$

+**ដែនកំណត់ :** $D = IR$

ដេរីវេ $y' = 2xe^{-x} - x^2 e^{-x} = \dfrac{x(2-x)}{e^x}$

$y' = 0 \Rightarrow x = 0; x = 2$

យើងបាន $f(0) = 0; f(2) = \dfrac{4}{e^2} = 0.6$

+**លីមីត អាស៊ីមតូត :**

$\lim\limits_{x \to -\infty} y = +\infty; \lim\limits_{x \to +\infty} y = 0$ នោះបន្ទាត់ $y = 0$ ជាអាស៊ីមតូត

ដេក នៃខ្សែកោង ។

+**តារាងអថេរភាព :**

| $x$ | $-\infty$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | $0$ | $-$ | |
| $y$ | $+\infty$ | $\searrow$ | $0$ | $\nearrow$ | $0.6$ | $\searrow$ | $0$ |

+**ចំនុចបរមា :**

- អនុគមន៍ $f$ មានអប្បបរមានៅត្រង់ $x = 0$ ដែល $f(0) = 0$
- អនុគមន៍ $f$ មានអតិបរមានៅត្រង់ $x = 2$ ដែល $f(2) = 0.6$

+**ចំណុចរបត់ :** ដោយ $y' = \dfrac{x(2-x)}{e^x}$ នោះយើងបាន :

$$y''=\frac{x^2-4x+2}{e^x}$$

$$y''=0\Rightarrow x^2-4x+2=0\Rightarrow x=2+\sqrt{2};x=2-\sqrt{2}$$




ខ. $y=5+2e^{-x}$

+ **ដែនកំណត់ :** $D=IR$

+ **ទិសដៅអថេរភាព :**

- ដេរីវេទី១ : $y'=-2e^{-x}<0$ នោះយើងបាន អនុគមន៍ចុះជានិច្ច ហើយគ្មានចំនុចបរមាទេ ។

+ **លីមីត និងអាស៊ីមតូត :**

$\lim\limits_{x\to-\infty} y=+\infty;\lim\limits_{x\to+\infty} y=5$ នោះបន្ទាត់ $y=5$ ជាអាស៊ីមតូតដេកនៃក្រាប ។

តារាងអថេរភាព

| $x$ | $-\infty$ | $+\infty$ |
|---|---|---|
| $y'$ | $-$ | |
| $y$ | $+\infty$ ↘ | $5$ |

ខ្សែកោង $y$ កាត់ $(y'oy)$ ត្រង់ : $x = 0 \Rightarrow y = 5 + 2e^0 = 7$

**+ចំណុចរបត់** $y'' = 2e^{-x} > 0$ ។ ដោយ $y'' > 0$ នោះ $y$ គ្មានចំណុចរបត់ទេ ។



**គ.** $g(x) = e^x - x^2$

**+ដែនកំណត់** : $D = IR$

**+ដេរីវេ** $g'(x) = e^x - 2x > 0$ នោះ $f$ ជាអនុគមន៍កើនជានិច្ច ។

**+លីមីត :**

$$\lim_{x\to-\infty} g(x) = -\infty;\ \lim_{x\to+\infty} g(x) = +\infty$$

**+តារាងអថេរភាព :**

| $x$ | $-\infty$ | $+\infty$ |
|---|---|---|
| $g'(x)$ | $+$ | |
| $g(x)$ | $-\infty$ ↗ | $+\infty$ |

ខ្សែកោង $g(x)$ កាត់ $(y'oy)$ ត្រង់ $x=0 \Rightarrow y=1$

+ចំណុចរបត់ : $g''(x)=e^x-2; g''(x)=0 \Rightarrow x=\ln 2$

និង $y=2-(\ln 2)^2=1.5$



7- សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $f(x)=\dfrac{1}{2-e^{-x}}$ ខ. $g(x)=\dfrac{e^x}{x^2}$ គ. $g(x)=\dfrac{x}{e^x}$

**សំរាយបញ្ជាក់ :**

សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $f(x)=\dfrac{1}{2-e^{-x}}$

អនុគមន៍មានន័យលុះត្រាតែ $2-e^{-x}\neq 0 \Rightarrow x\neq -\ln 2$

ដូចនេះ $D=IR-\{-\ln 2\}$

ដេរីវេ $f'(x)=-\dfrac{e^{-x}}{\left(2-e^{-x}\right)^2}<0$ នោះ $f$ ជាអនុគមន៍ចុះជានិច្ច ។

+លីមីត និងអាស៊ីមតូត :

$\lim_{x\to-\infty} f(x) = 0; \lim_{x\to+\infty} f(x) = \frac{1}{2}$ យើងបានបន្ទាត់ $y = 0$ និង

$y = \frac{1}{2}$ ជាអាស៊ីមតូតដេក ។

$\lim_{x\to-\ln 2} f(x) = \pm\infty$

+តារាងអថេរភាព :

| $x$ | $-\infty$ | | $-\ln 2$ | | $+\infty$ |
|---|---|---|---|---|---|
| $f'(x)$ | | $-$ | $\Vert$ | $-$ | |
| $f(x)$ | $0$ | $\searrow$ | $-\infty \Vert +\infty$ | $\searrow$ | $\frac{1}{2}$ |

ខ្សែកោងកាត់អ័ក្ស$(y'oy)$ ត្រង់ $x = 0 \Rightarrow y = 1$




ខ. $g(x) = \frac{e^x}{x^2}$

+ដែនកំណត់ : $D = IR - \{0\}$

- ដេរីវេ $g'(x) = \frac{e^x x^2 - 2xe^x}{x^4} = \frac{e^x x(x-2)}{x^4}$

$g'(x) = 0 \Rightarrow x = 2; y = \frac{e^2}{4} = 1.8$

+លីមីត និងអាស៊ីមតូត :

$\lim\limits_{x \to -\infty} g(x) = 0; \lim\limits_{x \to +\infty} g(x) = +\infty$ នោះបន្ទាត់ $y = 0$ ជាអាស៊ីមតូតដេក ។

+តារាងអថេរភាព :

| $x$ | $-\infty$ | | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $g'(x)$ | | $+$ | ‖ | $-$ | $0$ | $+$ | |
| $g(x)$ | $0$ | ↗ $+\infty$ | ‖ | $+\infty$ ↘ | $1.8$ | ↗ | $+\infty$ |

+សង់ក្រាប




ក. $g(x) = \dfrac{x}{e^x}$

+ដែនកំណត់ $D = IR$

បដេរីវេ $g'(x) = \dfrac{e^x - xe^x}{e^{2x}} = \dfrac{e^x(1-x)}{e^{2x}}$

$g'(x) = 0 \Rightarrow x = 1; y = \dfrac{1}{e} = 0.4$

+លីមីត: $\lim\limits_{x \to -\infty} g(x) = -\infty; \lim\limits_{x \to +\infty} g(x) = 0$ នោះបន្ទាត់ $y = 0$ ជាអាស៊ីមតូតដេក ។

+ តារាងអថេរភាព :

| $x$ | $-\infty$ | $1$ | $+\infty$ |
|---|---|---|---|
| $g'(x)$ | $+$ | $0$ | $-$ |
| $g(x)$ | $-\infty \nearrow$ | $0.4$ | $\searrow 0$ |

ក្រាបកាត់អ័ក្ស $(y'oy)$ ត្រង់ $x=0; y=0$

+ សង់ក្រាប :




8- រកប្រាក់សរុបនៃប្រាក់ដើមចំនួន 2000ដុល្លា ដែលគេបានធ្វើវិនិយោគ ក្នុងរយៈពេល 4 ឆ្នាំ ដោយទទួលអត្រាការប្រាក់ 6% តាមរយៈពេលកំណត់ដូចខាងក្រោម:

ក. គិតជាឆ្នាំ ខ. គិតជាឆមាស គ. គិតជាត្រីមាស ឃ. គិតជាខែ

**សំរាយបញ្ជាក់ :**

តាមរូបមន្ត $p = p_o\left(1+\frac{r}{n}\right)^{tn}$

ក. គិតជាឆ្នាំ យើងបាន $n=1$

$$\Rightarrow p=2000(1+0.06)^4=2525 \text{ ដុល្លា}$$

ខ. គិតជាឆមាស យើងបាន $n=2$

$$\Rightarrow p=2000\left(1+\frac{0.06}{2}\right)^8=2533 \text{ ដុល្លា}$$

គ. គិតជាត្រីមាស យើងបាន $n=4$

$$\Rightarrow p=2000\left(1+\frac{0.06}{4}\right)^{16}=2537 \text{ ដុល្លា}$$

ឃ. គិតជាខែ យើងបាន $n=12$

$$\Rightarrow p=2000\left(1+\frac{0.06}{12}\right)^{48}=2541 \text{ ដុល្លា}$$

9- ឧបមាថា គេយកប្រាក់ 5000 ដុល្លាទៅផ្ញើរនៅធនាគារមួយដោយទទួលបានអត្រាការប្រាក់សមាស 11% ក្នុងមួយឆ្នាំ។ បើគេផ្ញើប្រាក់រយៈពេល 10ឆ្នាំ តើគេទទួលបានប្រាក់សរុបទាំងអស់ចំនួនប៉ុន្មាន បើការទូទាត់ច្រើនដងក្នុងមួយឆ្នាំ?

**សំរាយបញ្ជាក់ :**

ដោយការទូទាត់ច្រើនដងគឺ 10 ឆ្នាំ យើងបាន :

តាមរូបមន្ត : $p=p_0e^{rt}=5000e^{0.11\times10}=15020$ ដុល្លា

**10-** ឧបមាថា បើគេយកប្រាក់ទៅ ផ្ញើនៅធនាគារមួយដោយទទួលបាន អត្រាការសមាស 7% នោះ តើប៉ុន្មានឆ្នាំទើបគេទទួលបានប្រាក់សរុប ស្មើនឹងបីដងនៃប្រាក់ដើម បើការទូទាត់ច្រើនដងក្នុងមួយឆ្នាំ? ចម្លើយគិតជាឆ្នាំ?

**សំរាយបញ្ជាក់ :**

ដោយការទូទាត់ច្រើនដង យើងបាន :

$p = p_o e^{rt}$ តែ $p = 3p_o$ យើងបាន

$$3p_o = p_o e^{rt} \Rightarrow e^{0.07t} = 3 \Rightarrow t = \frac{\ln 3}{0.07} = 15.7$$

ដូចនេះ គេប្រើរយៈពេលពី 15ទៅ16 ឆ្នាំ

## មេរៀនទី៣ : អនុគមន៍លោការីត

### លំហាត់ :

1 គណនាតម្លៃនៃកន្សោមខាងក្រោម:

ក. $e^{\ln 7}$ ខ. $\ln e^{x-2}$ គ. $\ln e^{7x}$

### សំរាយបញ្ជាក់ :

ក. $e^{\ln 7} = 7$ ខ. $\ln e^{x-2} = x-2$ គ. $\ln e^{7x} = 7x$

2- សង់ក្រាបនៃអនុគមន៍ :

ក. $y = 3 - \ln x$ ខ. $y = \ln(x-3)$

គ. $y = \ln\left(2+e^{x}\right)$

### សំរាយបញ្ជាក់ :

ក. $y = 3 - \ln x$



ខ. $y=\ln(x-3)$



គ. $y=\ln\left(2+e^{x}\right)$



3- គណនាលីមីតនៃអនុគមន៍ខាងក្រោម:

ក. $\lim\limits_{x\to+\infty} x^{-5}\ln x$ ខ. $\lim\limits_{x\to+\infty}\dfrac{(1+\ln x)}{x^{2}}$

គ. $\lim\limits_{x\to 0}(x\ln x)$

**សំរាយបញ្ជាក់ :**

គណនាលីមីតនៃអនុគមន៍ខាងក្រោម:

ក. $\lim\limits_{x\to+\infty} x^{-5}\ln x = \lim\limits_{x\to+\infty}\frac{\ln x}{x^5} = 0$

ខ. $\lim\limits_{x\to+\infty}\frac{(1+\ln x)}{x^2} = \lim\limits_{x\to+\infty}\left(\frac{1}{x^2}+\frac{\ln x}{x^2}\right) = 0$

គ: $\lim\limits_{x\to 0}(x\ln x)$ តាង $t=\frac{1}{x}\Rightarrow x=\frac{1}{t}$ ពេល

$x\to 0\Rightarrow t\to+\infty$ យើងបាន :

$\lim\limits_{x\to 0}(x\ln x) = \lim\limits_{t\to+\infty}\left(\frac{1}{t}\ln\frac{1}{t}\right) = \lim\limits_{t\to+\infty}-\frac{\ln t}{t} = 0$

4- គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=\sqrt{x}.\ln x$ ខ. $y=x\sqrt[3]{\ln x}$ គ. $y=\ln\left(x+\sqrt{1+x^2}\right)$

**សំរាយបញ្ជាក់ :**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=\sqrt{x}.\ln x\Rightarrow y'=\frac{\ln x}{2\sqrt{x}}+\frac{\sqrt{x}}{x}=\frac{\ln x+2}{2\sqrt{x}}$

ខ. $y=x\sqrt[3]{\ln x}\Rightarrow y'=\sqrt[3]{\ln x}+\frac{1}{3}x\times\frac{1}{x}\times(\ln x)^{\frac{1}{3}-1}$

យើងបាន $y'=\sqrt[3]{\ln x}+\frac{1}{3}(\ln x)^{-\frac{2}{3}}=(\ln x)^{\frac{1}{3}}+\frac{1}{3(\ln x)^{\frac{2}{3}}}$

ដូចនេះ $y' = \dfrac{3\ln x+1}{3\sqrt[3]{\ln^2 x}}$

គ. $y = \ln\left(x+\sqrt{1+x^2}\right)$ យើងបាន :

$$y' = \frac{\left(x+\sqrt{1+x^2}\right)'}{x+\sqrt{1+x^2}} = \frac{1+\dfrac{x}{\sqrt{1+x^2}}}{x+\sqrt{1+x^2}} = \frac{1}{\sqrt{1+x^2}}$$

5- គណនាដេរីវេនៃអនុគមន៍ខាងក្រោមៈ

ក. $y = \ln\dfrac{e^x}{e^x+1}$ ខ. $y = x\ln x - x$

គ. $y = x^2\ln\dfrac{1}{x^2}$

**សំរាយបញ្ជាក់ :**

គណនាដេរីវេនៃអនុគមន៍ខាងក្រោមៈ

ក. $y = \ln\dfrac{e^x}{e^x+1}$ យើងបាន

$$y' = \frac{\left(\dfrac{e^x}{e^x+1}\right)'}{\dfrac{e^x}{e^x+1}} = \frac{e^x\left(e^x+1\right)-e^{2x}}{\left(e^x+1\right)^2}\times\frac{e^x+1}{e^x} = \frac{1}{e^x+1}$$

ខ. $y = x\ln x - x$ យើងបាន $y' = \ln x + 1 - 1 = \ln x$

គ. $y = x^2 \ln \frac{1}{x^2}$ នោះយើងបាន :

$$y' = 2x\ln\frac{1}{x^2} + x^2 \times \frac{-2}{x^3} \times x^2 = -2x\ln x^2 - 2x$$

6- សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y = \frac{x}{\ln x}$ ខ. $y = \ln x + e^x$ , គ. $y = \ln^2 x + \frac{1}{\ln^2 x + 2}$

## សំរាយបញ្ជាក់ :

សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. យើងមាន : $y = \frac{x}{\ln x}$

អនុគមន៍មានន័យលុះត្រាតែ $\begin{cases} x > 0 \\ x \neq 1 \end{cases} \Rightarrow x \in (0,1) \cup (1,+\infty)$

- ដេរីវេ : $y' = \frac{\ln x - 1}{\ln^2 x}$

$y' = 0 \Rightarrow x = e; y = e$

+លីមីត: $\lim\limits_{x\to 0} y = \lim\limits_{x\to 0}\frac{x}{\ln x} = 0; \lim\limits_{x\to+\infty} y = \lim\limits_{x\to+\infty}\frac{x}{\ln x} = +\infty$

និង $\lim\limits_{x\to 1} y = \lim\limits_{x\to 1}\frac{x}{\ln x} = \pm\infty$

+តារាងអថេរភាព :

| $x$ | $-\infty$ | | $1$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $0$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $e$ | ↗ | $+\infty$ |

យើងបាន អនុគមន៍មានតម្លៃអប្បបរមាត្រង់ $x = e; y = e$

+ សង់ក្រាប :




ខ. $y = \ln x + e^{x}$

+ ដែនកំណត់ : អនុគមន៍មានន័យលុះត្រាតែ $x > 0$

- ដេរីវេ : $y' = \dfrac{1}{x} + e^{x} > 0$ នោះ $f$ កើនជានិច្ច ហើយគ្មានបរមាទេ

លីមីត: $\lim\limits_{x \to 0} y = \lim\limits_{x \to 0}\left(\ln x + e^{x}\right) = -\infty; \lim\limits_{x \to +\infty} y = +\infty$

+ តារាងអថេរភាព :

| $x$ | $0$ | | $+\infty$ |
|---|---|---|---|
| $y'$ | | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $+\infty$ |



+ សង់ក្រាប :

បើ $x = 1 \Rightarrow y = e$

គ. $y=\ln^2 x+\dfrac{1}{\ln^2 x+2}$

+ ដែនកំណត់ $D=(0,+\infty)$

-ដេរីវេ $y'=\dfrac{2}{x}\ln x-\dfrac{\dfrac{2}{x}\ln x}{\left(\ln^2 x+2\right)^2}=\dfrac{\dfrac{2}{x}\ln x\left[\left(\ln^2 x+2\right)^2-1\right]}{\left(\ln^2 x+2\right)^2}$

$$=\frac{\dfrac{2}{x}\ln x\left(\ln^2 x+1\right)\left(\ln^2 x+3\right)}{\left(\ln^2 x+2\right)^2}$$

$y'=0\Rightarrow \ln x=0\Rightarrow x=1; y=\dfrac{1}{2}$

+ លីមីត: $\lim\limits_{x\to+\infty} y=+\infty;\ \lim\limits_{x\to 0^+} y=+\infty$

+ តារាងអថេរភាព :

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $+\infty$ | ↘ | $\frac{1}{2}$ | ↗ | $+\infty$ |



7. សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y = 2x - x\ln x$

ខ. $y = f(x) = \begin{cases} x(1-\ln x) & \text{បើ } x > 0 \\ 0 & \text{បើ } x = 0 \end{cases}$

**ដំណោះស្រាយ :**

សិក្សាអថេរភាព និងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y = 2x - x\ln x$

+ **ដែនកំណត់** $D = (0, +\infty)$

- ដេរីវេ : $y' = 2 - (\ln x + 1) = 1 - \ln x$

$y' = 0 \Rightarrow x = e; y = e$

- **លីមីត:** $\lim_{x\to+\infty} y = \lim_{x\to+\infty} x(2 - \ln x) = -\infty$

$\lim_{x\to 0} y = \lim_{x\to 0}(2x - x\ln x)$

តាង $t = \frac{1}{x} \Rightarrow x = \frac{1}{t}$ ពេល $x \to 0^+ \Rightarrow t \Rightarrow +\infty$

$\lim_{x\to 0}(2x - x\ln x) = \lim_{t\to+\infty}\left(\frac{2}{t} + \frac{\ln t}{t}\right) = 0$

+ **តារាងអថេរភាព :**

| $x$ | $0$ | | $e$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | + | 0 | − | |
| $y$ | $0$ | ↗ | $e$ | ↘ | $-\infty$ |

ខ្សែកោងកាត់អ័ក្សអាប់ស៊ីសត្រង់

$y=0\Rightarrow x(2-\ln x)=0\Rightarrow \ln x=2\Rightarrow x=e^{2}$

បើ $x=1; y=2$



ខ. $y=f(x)=\begin{cases} x(1-\ln x) & \text{បើ } x>0 \\ 0 & \text{បើ } x=0 \end{cases}$

អនុគមន៍ $y=x(1-\ln x)$

+ **ដែនកំណត់** $D=(0;+\infty)$

+ **ដេរីវេ** $y'=1-\ln x-1=-\ln x$

$y'=0\Rightarrow x=1; y=1$

+ **លីមីត:** $\lim_{x\to+\infty} y=-\infty; \lim_{x\to 0} y=0$

ដោយ $\lim_{x\to 0} y=f(0)=0$ យើងបាន $y$ ជាប់ត្រង់ $x=0$ ។

+ **តារាងអថេរភាព :**

| $x$ | 0 | | 1 | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | + | 0 | − | |
| $y$ | | ↗ | 1 | ↘ | $-\infty$ |

ខ្សែកោងកាត់អ័ក្សអាប់ស៊ីសត្រង់

$y = 0 \Rightarrow x = e$




8- ក. សិក្សាអថេរភាព និងសង់ក្រាប $(c)$ របស់អនុគមន៍

$y = -2\ln|x| + x - 2$ ។

ខ. ក្រាប $C$ កាត់ $Ox$ ត្រង់បីចំណុច $P; Q; R$ ដែលមានអាប់ស៊ីសរៀងគ្នា $p; q; r$ ។ ចូរប្រៀបធៀប $P; Q; R$ និងបណ្ដាចំនួនខាងក្រោម : $-1; 0; 1; 5; 6$ ។

**សំរាយបញ្ជាក់ :**

ក. $y = -2\ln|x| + x - 2$

- បើ $x > 0$ យើងបាន :

$$y = -2\ln x + x - 2 = x\left(\frac{-2\ln x}{x} + 1 - \frac{2}{x}\right)$$

ដេរីវេ $y' = -\frac{2}{x} + 1 = \frac{-2 + x}{x}$

$y' = 0 \Rightarrow x = 2; y = -2\ln 2 = -2\times 0.7 = -1.4$

+ លីមីត: $\lim\limits_{x\to+\infty} y = +\infty; \lim\limits_{x\to 0^+} y = +\infty$

+ តារាងអថេរភាព :

| $x$ | $0$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $+\infty$ | $\searrow$ | $-1.4$ | $\nearrow$ | $+\infty$ |

-បើ $x<0$ យើងបាន :

$$y=-2\ln(-x)+x-2=x\left(\frac{-2\ln(-x)}{x}+1-\frac{2}{x}\right)$$

- ដេរីវេ $y' = -\frac{2}{x}+1 = \frac{-2+x}{x} = 1-\frac{2}{x} > 0$

នោះយើងបាន $f$ ជាអនុគមន៍កើនជានិច្ចចំពោះ $x<0$ ។

+ លីមីត: $\lim\limits_{x\to-\infty} y = -\infty; \lim\limits_{x\to 0} y = +\infty$

+ តារាងអថេរភាព :

| $x$ | $-\infty$ | | $0$ |
|---|---|---|---|
| $y'$ | | $+$ | |
| $y$ | $-\infty$ | $\nearrow$ | $+\infty$ |

+ សំណង់ខ្សែកោង :




**8.** ដោយ $f(-1)=-1-2=-3; f(0)=-2$

$$f(5)=-0.2; f(6)=0.4; \lim_{x\to 0} y=+\infty; f\left(-\frac{1}{100}\right)>0$$

$f\left(\frac{1}{100}\right)>0$ ដែល $-\frac{1}{100}\simeq 0; \frac{1}{100}\simeq 0$ យើងបាន :

$$f(-1).f\left(-\frac{1}{100}\right)<0 \Rightarrow -1<P<0$$

$$f\left(\frac{1}{100}\right).f(1)<0 \Rightarrow 0<Q<1$$

$$f(5).f(6)<0 \Rightarrow 5<P<6$$

**9-** រោងចក្រឧស្សាហកម្មមួយបានទិញម៉ាស៊ីនហ្វាក់តម្លៃ250ដុល្លារហើយមានអត្រាតម្លៃថយចុះ 25% ក្នុងមួយឆ្នាំ។ តើបីឆ្នាំក្រោយ ម៉ាស៊ីនហ្វាក់នេះនឹងមានតម្លៃប៉ុន្មាន?

**សំរាយបញ្ជាក់ :**

ដោយប្រើរូបមន្ត $c=c_o(1-r)^t$ ដែល

$c_o=250\$;r=0.25;t=3$ យើងបាន

$c=250(1-0.25)^3=105.5\$$

ដូចនេះ $\boxed{c=105.5\$}$

10- បាត់តេរីមួយប្រភេទបំបែកខ្លួន ដោយមានមេគុណអត្រាកំណើន $k=0.872$ ដែល $t$ គិតជាថ្ងៃ ។បើដើមដំបូងមានបាត់តេរីចំនួន 9 តើរយៈពេលប៉ុន្មានថ្ងៃ ទើបចំនួនបាត់តេរីកើនដល់ 738 ?

**សំរាយបញ្ជាក់ :**

ដោយប្រើ $A=A_oe^{kt}$ ដែល $A_o=9;k=0.872;A=738$

យើងបាន $738=9e^{0.872}\Rightarrow e^{0.872t}=\frac{738}{9}=82$

$\Rightarrow t=\frac{\ln 82}{0.872}=5.05$

ដូចនេះ $\boxed{t=5.05}$ ថ្ងៃ

11- នៅទីក្រុងមួយកាលពី 10 ឆ្នាំមុន មានប្រជាជនចំនួន 45600 នាក់ ហើយចំនួនប្រជាជនមានការកើន ឡើងដោយអត្រាមួយថេរជារៀងរាល់ឆ្នាំ ។ បើបច្ចុប្បន្នមានប្រជាជនចំនួន 64800 នាក់ រកអត្រាកំណើននៃប្រជាជនប្រចាំឆ្នាំក្នុងទីក្រុងនេះ ។

## សំរាយបញ្ជាក់ :

ដោយប្រើ $p = p_o e^{rt}$ ដែល $p = 64800; p_o = 45600; t = 10$

យើងបាន $64800 = 45600e^{10r} \Rightarrow r = 0.036 = 3.6\%$

ដូចនេះ $\boxed{r = 3.6\%}$

# លំហាត់ជំពូក៣

1- រកដែនកំណត់នៃអនុគមន៍ខាងក្រោម:

ក. $y = \sqrt{x^2 - 2\sqrt{x^2 - 1}} + \sqrt{x - 3 + 2\sqrt{x - 4}}$

ខ. $y = \lg\left(\dfrac{2^{1-x} - 2x + 1}{2^x - 1}\right)$

## សំរាយបញ្ជាក់ :

ក. $y = \sqrt{x^2 - 2\sqrt{x^2 - 1}} + \sqrt{x - 3 + 2\sqrt{x - 4}}$

អនុគមន៍មានន័យលុះត្រាតែ :

$$\begin{cases} x^2 - 1 \geq 0 \\ x^2 - 2\sqrt{x^2 - 1} \geq 0 \\ x - 4 \geq 0 \\ x - 3 + 2\sqrt{x - 4} \geq 0 \end{cases} \Rightarrow \begin{cases} x^2 - 1 \geq 0 \\ \left(\sqrt{x^2 - 1} - 1\right)^2 \geq 0 \\ x - 4 \geq 0 \\ \left(\sqrt{x - 4} + 1\right)^2 \geq 0 \end{cases}$$

$$\Rightarrow \begin{cases} x \le -1; x \ge 1 \\ x \ge 4 \end{cases} \Rightarrow x \ge 4$$

ដូចនេះ $\boxed{x \ge 4}$

៨. $y = \lg\left(\dfrac{2^{1-x} - 2x + 1}{2^x - 1}\right)$

អនុគមន៍ $y$ មានន័យកាលណា :

$$\begin{cases} \dfrac{2^{1-x} - 2x + 1}{2^x - 1} > 0 \\ 2^x - 1 \ne 0 \end{cases} \Rightarrow \begin{cases} \dfrac{2\left(\dfrac{1}{2}\right)^x - 2x + 1}{2^x - 1} > 0 \\ x \ne 0 \end{cases}$$

បើ $2^x - 1 > 0 \Rightarrow x > 0$ យើងបាន

$$2\left(\frac{1}{2}\right)^x - 2x + 1 > 0 \Rightarrow 2\left(\frac{1}{2}\right)^x > 2x - 1$$

តាង $f(x) = 2\left(\dfrac{1}{2}\right)^x ; g(x) = 2x - 1$ យើងឃើញថា :



ក្រាបទាំងពីរកាត់គ្នាត្រង់ $x=1; y=1$

$$2\left(\frac{1}{2}\right)^x > 2x-1 \Rightarrow 0<x<1$$

បើ បើ $2^x-1<0 \Rightarrow x<0$ យើងបាន :

$2\left(\frac{1}{2}\right)^x -2x+1<0 \Rightarrow 2\left(\frac{1}{2}\right)^x < 2x-1$ យើងឃើញថាគ្មាន

តម្លៃ$x$ដែលធ្វើឱ្យ $f<g$ ក្នុងចន្លោះ $(+\infty,0)$ទេ

ដូចនេះ $\boxed{0<x<1}$

**2.** រកអាស៊ីមតូតរបស់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{4x-3}{2x+5}$ ខ. $y=\dfrac{3x^2-7x+15}{x-1}$

គ. $y=\dfrac{2x-1}{x^2-7x+10}$

**សំរាយបញ្ជាក់ :**

ក. យើងមាន : $y=\dfrac{4x-3}{2x+5}$

មាន $\lim\limits_{x\to\infty}=\dfrac{4x-3}{2x+5}=2$និង$\lim\limits_{x\to-\frac{5}{2}}=\dfrac{4x-3}{2x+5}=\infty$នោះយើងបាន

អាស៊ីមតូតឈរ $x=-\dfrac{5}{2}$; អាស៊ីមតូតដេក $y=2$

ខ. $y=\dfrac{3x^2-7x+15}{x-1}$

$$f(x)=\frac{3x^2-7x+15}{x-1}=3x-4+\frac{11}{x-1}$$

ដោយ $\lim\limits_{x\to\infty}=\dfrac{11}{x-1}=0$ នោះយើងបានបន្ទាត់ $y=3x-4$ ជាអាអាស៊ីមតូតទ្រេត $y=3x-4$ ហើយ $\lim\limits_{x\to1}=f(x)=\infty$ នោះយើងបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរនៃក្រាប ។

គ. $y=\dfrac{2x-1}{x^2-7x+10}=\dfrac{2x-1}{(x-2)(x-5)}$

ដោយ $\lim\limits_{x\to2}\dfrac{2x-1}{(x-2)(x-5)}=\infty$ និង $\lim\limits_{x\to5}\dfrac{2x-1}{(x-2)(x-5)}=\infty$

នោះយើងបានបន្ទាត់ $x=2$ និង $x=5$ អាស៊ីមតូតឈរនៃក្រាប និងមានបន្ទាត់ $y=0$ ជាអាស៊ីមតូតដេក ។

3- សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{x^2+3x+3}{x+2}$ ខ. $y=\dfrac{x^2}{x-1}$

គ. $y=\dfrac{x-2}{x^2-2x+1}$

**សំរាយបញ្ជាក់ :**

សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោម:

ក. $y = \dfrac{x^2+3x+3}{x+2} = x+1+\dfrac{1}{x+2}$

**+ដែនកំណត់** $D = IR - \{-2\}$

**+ទិសដៅអថេរភាព :**

**- ដេរីវេ** $f'(x) = \dfrac{x^2+4x+3}{x+2}$

$f'(x) = 0 \Rightarrow x = -1; x = -3$ ដែល $f(-1) = 1; f(-3) = -3$

**- លីមីត និង អាស៊ីមតូត:**

$\lim\limits_{x\to-2} f(x) = \lim\limits_{x\to-2} \dfrac{x^2+3x+3}{x+2} = \infty$ ៊ យើងបានបន្ទាត់ $x = -2$ ជាអាស៊ីមតូតឈរ ។

$\lim\limits_{x\to\infty} [f(x) - (x+1)] = 0$ នោះយើងបាន បន្ទាត់ $y = x+1$ ជាអាស៊ីមតូតទ្រេត ។

**+តារាងអថេរភាព :**

| $x$ | $-\infty$ | | $-3$ | | $-2$ | | $-1$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | ↗ | $-3$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $-1$ | ↗ | $+\infty$ |

**+សង់ក្រាប :**

ក្រាបកាត់អ័ក្ស $(y'oy): x = 0 \Rightarrow y = \dfrac{3}{2}$




៨. $y=\dfrac{x^2}{x-1}=x+1+\dfrac{1}{x-1}$

+ ដែនកំណត់ $D=IR-\{1\}$

- ដេរីវេ $y'=\dfrac{x^2-2x}{(x+2)^2};y'=0\Rightarrow x=0;x=2$ ដែល

$y(0)=0;y(2)=4$ ។

+ លីមីត និង អាស៊ីមតូត:

$\lim\limits_{x\to\pm\infty}y=\pm\infty;\lim\limits_{x\to 1}y=\pm\infty$ យើងបានបន្ទាត់ $x=1$ ជាអាស៊ីមតូតឈរ ។ $\lim\limits_{x\to\pm\infty}\left[f(x)-(x+1)\right]=0$ យើងបាន បន្ទាត់ $y=x+1$ ជាអាស៊ីមតូតទ្រេត ។

+ តារាងអថេរភាព:

| $x$ | $-\infty$ | | $0$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | + | 0 | − | ‖ | − | 0 | + | |
| $y$ | $-\infty$ | ↗ | 0 | ↘ | $-\infty$ ‖ $+\infty$ | ↘ | 4 | ↗ | $+\infty$ |

+សង់ក្រាប :




គ. $y = \dfrac{x-2}{x^2-2x+1}$

+ដែនកំណត់ : $D = IR - \{1\}$

- ដេរីវេ $y' = \dfrac{-x^2+4x-3}{(x-1)^2}; y' = 0 \Rightarrow x = 3; y = \dfrac{1}{4}$

+លីមីត និង អាស៊ីមតូត:

$\lim\limits_{x\to 1} y = -\infty$ យើងបាន បន្ទាត់ $x = 1$ ជាអាស៊ីមតូតឈរ

$\lim\limits_{x\to \pm\infty} y = 0$ យើងបាន បន្ទាត់ $y = 0$ ជាអាស៊ីមតូតដេក

+តារាងអថេរភាព :

| $x$ | $-\infty$ | | 1 | | 3 | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $+$ | 0 | $-$ | |
| $y$ | 0 ↘ | | $-\infty$ ‖ $-\infty$ | ↗ | $\frac{1}{4}$ | ↘ | 0 |

ចំណុចប្រសព្វរវាងខ្សែកោងនឹងអ័ក្ស

- $(x'ox): y=0 \Rightarrow x=2$

-$(y'oy): x=0 \Rightarrow y=-2$

+ **សង់ខ្សែកោង :**




**4-** គេឱ្យអនុគមន៍ $f: y=\dfrac{2x^2+x+1}{x+1}$ :

**ក.** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $f$ ។

**ខ.** តាមក្រាបរកតម្លៃអតិបរមានិងអប្បបរមានៃ

$$A=\frac{2\cos^2 x+|\cos x|+1}{|\cos x|+1}$$ ។

**សំរាយបញ្ជាក់ :**

**ក.** សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $f$ :

ក. យើងមាន $y = f(x) = \dfrac{2x^2 + x + 1}{x+1} = 2x - 1 + \dfrac{2}{x+1}$

**+ ដែនកំណត់ :** $D = IR - \{-1\}$

**+ ទិសដៅអថេរភាព :**

-ដេរីវេទី១ : $f'(x) = \dfrac{2x^2 + 4x}{(x+1)^2}$ ដោយ $(x+1)^2 > 0 \forall x \in D$

នោះ $f'(x)$ ត្រូវយកសញ្ញាតាម $2x^2 + 4x$

$f'(x) = 0 \Rightarrow x = -2; x = 0$

ដែល $f(-2) = -7; f(0) = 1$

**+ លីមីត និងអាស៊ីមតូត :**

យើងមាន $\lim\limits_{x\to -1} f(x) = \lim\limits_{x\to -1} \dfrac{2x^2 + x + 1}{x+1} = \infty$ យើងបាន បន្ទាត់

$x = -1$ ជាអាស៊ីមតូតឈរ ។

ម្យ៉ាងទៀត $\lim\limits_{x\to \pm\infty} \left[ f(x) - (2x-1) \right] = 0$ យើងបាន បន្ទាត់

$y = 2x - 1$ ជាអាស៊ីមតូតទ្រេត ។

**+ តារាងអថេរភាព :**

| $x$ | $-\infty$ | | $-2$ | | $-1$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $y'$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $-\infty$ | ↗ | $-7$ | ↘ | $-\infty$ ‖ $+\infty$ | ↘ | $1$ | ↗ | $+\infty$ |

+ចំនុចបរមា :

- អនុគមន៍ $f$ មានអតិបរមានៅត្រង់ចំនុច $x=-2$ ដែល $f(-2)=-7$

- អនុគមន៍ $f$ មានអប្បបរមានៅត្រង់ចំនុច $x=0$ ដែល $f(0)=1$

+សង់ក្រាប :




ខ. តាមក្រាបរកតម្លៃអតិបរមានិងអប្បបរមានៃ :

$$A=\frac{2\cos^2 x+|\cos x|+1}{|\cos x|+1}$$

តាង $t=|\cos x|$ ដែល $0\leq t\leq 1$ យើងបាន :

$$A(t)=\frac{2t^2+t+1}{t+1}$$

តាមក្រាបយើងបានពេល $t=0\Rightarrow A(0)=1$ ជាតម្លៃអប្បបរមា

ពេល $t=1\Rightarrow A(1)=2$ ជាតម្លៃអតិបរមា ។

5- គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{e^x}{x-1}$ ខ. $y=e^{2x}-2e^x$ គ. $y=\dfrac{e^x+1}{e^x-1}$

**សំរាយបញ្ជាក់ :**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=\dfrac{e^x}{x-1}\Rightarrow y'=\dfrac{e^x(x-1)-e^x}{(x-1)^2}=\dfrac{e^x(x-2)}{(x-1)^2}$.

ខ. $y=e^{2x}-2e^x\Rightarrow y'=2e^{2x}-2e^x$

គ. $y=\dfrac{e^x+1}{e^x-1}\Rightarrow y'=\dfrac{e^x\left(e^x-1\right)-e^x\left(e^x+1\right)}{\left(e^x-1\right)^2}=\dfrac{-2e^x}{\left(e^x-1\right)^2}$

6- គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=x-1-\ln x$ ខ. $y=\ln\left(\dfrac{x-3}{x+2}\right)$

គ. $y=x^2\ln x-\dfrac{x^2}{2}$

**សំរាយបញ្ជាក់ :**

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក. $y=x-1-\ln x\Rightarrow y'=1-\dfrac{1}{x}=\dfrac{x-1}{x}$

ខ. $y=\ln\left(\frac{x-3}{x+2}\right)\Rightarrow y'=\frac{\left(\frac{x-3}{x+2}\right)'}{\frac{x-3}{x+2}}$

$=\frac{x+2-x+3}{(x+2)^2}\times\frac{x+2}{x-3}=\frac{5}{(x-3)(x+2)}$

គ. $y=x^2\ln x-\frac{x^2}{2}\Rightarrow y'=2x\ln x+x-x=2x\ln x$

7- សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក. $y=\frac{e^x}{x-1}$ ខ. $y=e^{2x}-2e^x$ គ. $y=\frac{e^x+1}{e^x-1}$

**សំរាយបញ្ជាក់ :**

សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក. $y=\frac{e^x}{x-1}$

+ **ដែនកំណត់** $:D=IR-\{1\}$

- ដេរីវេ $y'=\frac{e^x(x-2)}{(x-1)^2}; y'=0\Rightarrow x=2; y=e^2$

+ **លីមីត និងអាស៊ីមតូតៈ** $\lim_{x\to+\infty}y=+\infty$

$\lim_{x\to-\infty}y=\lim_{x\to-\infty}\frac{e^x}{(x-1)}=\lim_{t\to+\infty}\frac{e^{-t}}{(-t-1)}=\lim_{t\to+\infty}\frac{1}{e^t(-t-1)}=0$

បន្ទាត់ $y = 0$ ជាអាស៊ីមតូតដេក ។

$\lim\limits_{x\to 1} y = \pm\infty$ នោះបន្ទាត់ $x = 1$ ជាអាស៊ីមតូតឈរ ។

**+ តារាងអថេរភាព :**

| $x$ | $-\infty$ | | $1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $-$ | ‖ | $-$ | $0$ | $+$ | |
| $y$ | $0$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $e^2$ | ↗ | $+\infty$ |

ខ្សែកោងកាត់អ័ក្ស $(y'oy)$ ត្រង់ $x = 0 \Rightarrow y = -1$

**+ សង់ក្រាប :**




**៨.** $y = e^{2x} - 2e^{x}$

**+ ដែនកំណត់ :** $D = IR$

**- ដេរីវេ** $y' = 2e^{2x} - 2e^{x} = 2e^{x}\left(e^{x} - 1\right)$.

$y' = 0 \Rightarrow e^{x} - 1 = 0 \Rightarrow x = 0; y = -1$

+ **លីមីតនិងអាស៊ីមតូត :** $\lim\limits_{x\to+\infty} y = +\infty; \lim\limits_{x\to-\infty} y = 0$ នោះបន្ទាត់ $y = 0$ ជាអាស៊ីមតូតដេក ។

+ **តារាងអថេរភាព :**

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $0$ | $\searrow$ | $-1$ | $\nearrow$ | $+\infty$ |

+ ចំណុចប្រសព្វរវាងខ្សែកោងនឹងអ័ក្ស :

$(x'ox): y=0 \Rightarrow e^{2x} - 2e^{x} = 0$

$\Rightarrow e^{x}\left(e^{x}-2\right) = 0 \Rightarrow e^{x} - 2 = 0 \Rightarrow x = \ln 2 = 0.7$

+ **ចំណុចរបត់** $y'' = 4e^{2x} - 2e^{x} = 2e^{x}\left(2e^{x}-1\right)$

$y'' = 0 \Rightarrow 2e^{x} - 1 = 0 \Rightarrow e^{x} = \dfrac{1}{2} \Rightarrow x = -\ln 2 = -0.7$

$\Rightarrow y = e^{2\ln\frac{1}{2}} - 2e^{\ln\frac{1}{2}} = \dfrac{1}{4} - 1 = -\dfrac{3}{4}$

+ **សង់ក្រាប :**



គ. $y = \dfrac{e^x + 1}{e^x - 1}$

+ដែនកំណត់ : $D = IR - \{0\}$

- ដេរីវេ $y' = \dfrac{-2e^x}{\left(e^x - 1\right)^2} < 0$ នោះយើងបាន $f$ ជាអនុគមន៍ចុះជានិច្ច ហើយគ្មានចំនុចបរមាទេ ។

+លីមីតនិងអាស៊ីមតូត: $\lim\limits_{x\to+\infty} y = 1; \lim\limits_{x\to-\infty} y = -1$ យើងបាន បន្ទាត់ $y = -1$ និង $y = 1$ ជាអាស៊ីមតូតដេក ។

$\lim\limits_{x\to 0} y = \pm\infty$ យើងបាន បន្ទាត់ $x = 0$ ជាអាស៊ីមតូតឈរ ។

+តារាងអថេរភាព :

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | \|\| | $-$ | |
| $y$ | $-1$ ↘ | | $-\infty$ \|\| $+\infty$ | | ↘ $1$ |

+សង់ក្រាប :



8- សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក. $y = x - 1 - \ln x$ ខ. $y = \ln\left(\dfrac{x-3}{x+2}\right)$

គ. $y = x^2 \ln x - \dfrac{x^2}{2}$

**សំរាយបញ្ជាក់ :**

សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ខាងក្រោមៈ

ក. $y = x - 1 - \ln x = x\left(1 - \dfrac{1}{x} - \dfrac{\ln x}{x}\right)$

+ដែនកំណត់ : $D = (0, +\infty)$

- ដេរីវេ: $y' = 1 - \dfrac{1}{x} = \dfrac{x-1}{x}; y' = 0 \Rightarrow x = 1; y = 0$

+លីមីត: $\lim\limits_{x\to 0} y = +\infty; \lim\limits_{x\to+\infty} y = +\infty$

+តារាងអថេរភាព :

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $+\infty$ | $\searrow$ | $0$ | $\nearrow$ | $+\infty$ |

ចំពោះ $x = 4 \Rightarrow y = 3 - \ln 4 = 3 - 1.4 = 1.6$

+សង់ក្រាប :




ខ. $y=\ln\left(\frac{x-3}{x+2}\right)$

+**ដែនកំណត់** :អនុគមន៍មានន័យលុះត្រាតែ :

$\frac{x-3}{x+2}>0 \Rightarrow x\in(-\infty,-2)\cup(3,+\infty)$

- ដេរីវេ : $y'=\frac{5}{(x-3)(x+2)}>0$ នោះយើងបាន $f$ ជាអនុគមន៍

កើនជានិច្ច ហើយគ្មានបរមាទេ ។

+**លីមីតនិងអាស៊ីមតូត:** $\lim_{x\to\pm\infty} y = \lim_{x\to\pm\infty}\left(\frac{x-3}{x-2}\right) = \ln 1 = 0$

យើងបាន បន្ទាត់ $y=0$ ជាអាស៊ីមតូតដេក ។

$\lim_{x\to -2^-} y = \pm\infty; \lim_{x\to 3^+} y = \pm\infty$ យើងបាន បន្ទាត់ $x=-2$ និង

$y=3$ ជាអាស៊ីមតូតឈរ ។

+ តារាងអថេរភាព :

| $x$ | $-\infty$ | | $-2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $y'$ | | $+$ | | [redacted] | | $+$ | |
| $y$ | $0$ | $\nearrow$ | $+\infty$ | | $-\infty$ | $\nearrow$ | $0$ |

+ សង់ក្រាប




គ. $y = x^2 \ln x - \frac{x^2}{2}$

+ ដែនកំណត់ $D = (0, +\infty)$

-ដេរីវេ : $y' = 2x \ln x; y' = 0 \Rightarrow \ln x = 0 \Rightarrow x = 1; y = -\frac{1}{2}$

+ លីមីត: $\lim\limits_{x \to +\infty} y = +\infty; \lim\limits_{x \to 0} y = 0$

+ តារាងអថេរភាព :

| $x$ | $0$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $y'$ | | $-$ | $0$ | $+$ | |
| $y$ | $0$ | $\searrow$ | $\frac{1}{2}$ | $\nearrow$ | $+\infty$ |



9- មន្ត្រីរាជការម្នាក់មានអាយុ 30ឆ្នាំ បានយកប្រាក់ចំនួន 1000ដុល្លារ ទៅផ្ញើនៅធនាគារមួយដោយទទួលបានអត្រាការប្រាក់សមាស11% ក្នុងមួយឆ្នាំ។ ពេលចូលនិវត្តន៍អាយុ60ឆ្នាំតើគាត់មានប្រាក់សរុបទាំងអស់ចំនួនប៉ុន្មាន បើធនាគារទូទាត់ការប្រាក់ជាបន្តបន្ទាប់?

**សំរាយបញ្ជាក់ :**

តាមរូបមន្ត : $A = P(1+r)^t$ ដែល :

$P = 1000\$; r = 11\% = 0.11; t = 30$ ឆ្នាំ យើងបាន :

$A = 1000(1+0.11)^{30} = 22892\$$

ដូចនេះ នៅពេលចូលនិវត្តន៍អាយុ 60ឆ្នាំ មន្ត្រីនោះមានប្រាក់សរុប 22892ដុល្លា។

10-នៅទីក្រុងមួយកាលពី 20ឆ្នាំមុន មានប្រជាជនចំនួន 60000នាក់ ហើយចំនួនប្រជាជនមានការកើន ឡើងដោយអត្រាមួយថេរជារៀងរាល់ឆ្នាំ។ បើបច្ចុប្បន្នមានប្រជាជនចំនួន 150000នាក់ រកអត្រាកំណើននៃចំនួនប្រជាជនក្នុងទីក្រុងនេះ។

**សំរាយបញ្ជាក់ :**

រកអត្រាកំណើននៃចំនួនប្រជាជនក្នុងទីក្រុង :

តាមរូបមន្ត $p(t)=p_o e^{kt}$ ដែល $p_o$ ចំនួនប្រជាជនកាលពី 20ឆ្នាំ មុន $t$ រយៈពេល ។

តាមសម្មតិកម្ម $150000=60000e^{k20}$

$$\Rightarrow e^{20k}=\frac{150000}{60000}=2.5\Rightarrow 20k=\ln 2.5$$

$$\Rightarrow k=\frac{\ln 2.5}{20}=0.0458$$

ដូចនេះ ប្រជាជនក្នុងទីក្រុងនេះ មានអត្រាកើនឡើងប្រមាណជា 4.58% ក្នុងមួយឆ្នាំ ។

# ជំពូក ៤ : អាំងតេក្រាល

## មេរៀនទី១ ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់

### លំហាត់ :

1-បង្ហាញថា $F(x)$ ជាព្រីមីទីវនៃ $f(x)$ ;$\forall x\in IR$ ដែល:

ក. $F(x)=-7x+4$ និង $f(x)=-7$

ខ. $F(x)=3x^3-7x$ និង $f(x)=9x^2-7$

គ. $F(x)=3e^{x^2-1}-7$ និង $f(x)=6xe^{x^2-1}$

ឃ. $F(x)=\ln\left(e^{3x}-x\right)+\sqrt{11}$ និង $f(x)=\dfrac{3e^{3x}-1}{e^{3x}-x}$

### សំរាយបញ្ជាក់ :

បង្ហាញថា $F(x)$ ជាព្រីមីទីវនៃ $f(x)$ ;$\forall x\in IR$ ដែល:

ក. $F(x)=-7x+4$ យើងបាន $F'(x)=-7=f(x)$

ដូចនេះ $F(x)$ ជាព្រីមីទីវនៃ $f(x)$ .

ខ. $F(x)=3x^3-7x$ យើងបាន $F'(x)=9x^2-7=f(x)$

ដូចនេះ $F(x)$ ជាព្រីមីទីវនៃ $f(x)$ ។

គ. $F(x)=3e^{x^2-1}-7$ យើងបាន $F'(x)=6xe^{x^2-1}=f(x)$

ដូចនេះ $F(x)$ ជាព្រីមីទីវនៃ $f(x)$ ។

ឃ. $F(x)=\ln\left(e^{3x}-x\right)+\sqrt{11}$ នោះយើងបាន :

$$F'(x)=\frac{3e^{3x}-1}{e^{3x}-x}=f(x)$$

ដូចនេះ $F(x)$ ជាព្រីមីទីវនៃ $f(x)$ ។

2-រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)$ កំណត់និងជាប់លើចន្លោះ $I$ ដោយៈ

ក. $f(x)=5\ ;I=IR$

ខ. $f(x)=-4x+3\ ;I=IR$

គ. $f(x)=-x^2+3x+5\ ;I=IR$

ឃ. $f(x)=\frac{2}{x}\ ;I=\left(0;+\infty\right)$

ង. $f(x)=\frac{1}{3x+2}\ ;I=\left(-\frac{2}{3};+\infty\right)$

ច. $f(x)=\frac{x}{x^2+5}\ ;I=IR$

ឆ. $f(x)=e^{3x-2}\ ;I=IR$

ជ. $f(x)=xe^{x^2}\ ;I=IR$

## សំរាយបញ្ជាក់ :

រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)$ កំណត់និងជាប់លើចន្លោះ $I$

ដោយ:

ក. $f(x)=5$ ; $I=IR$ យើងបាន :

$$F(x)=\int f(x)dx=\int 5dx=5x+c \quad ;c\in IR$$

ខ. $f(x)=-4x+3$ ; $I=IR$ យើងបាន :

$$F(x)=\int f(x)dx=\int(-4x+3)dx=-2x^2+3x+c\,;c\in IR$$

គ. $f(x)=-x^2+3x+5$ ; $I=IR$ យើងបាន

$$F(x)=\int f(x)dx=\int\left(-x^2+3x+5\right)dx$$

$$=-\frac{1}{3}x^3+\frac{3}{2}x^2+5x+c\,;c\in IR$$

ឃ. $f(x)=\frac{2}{x}$ ; $I=(0;+\infty)$ នោះយើងបាន :

$$F(x)=\int f(x)dx=\int\frac{2}{x}dx=2\ln|x|+c\,;c\in IR$$

ង. $f(x)=\frac{1}{3x+2}$ ; $I=\left(-\frac{2}{3};+\infty\right)$ នោះយើងបាន :

$$F(x)=\int f(x)dx=\int\frac{1}{3x+2}dx=\frac{1}{3}\int\frac{(3x+2)'}{3x+2}dx$$

$$=\frac{1}{3}\ln|3x+2|+c\,;c\in IR$$

ច. $f(x)=\frac{x}{x^2+5}$ ; $I=IR$ យើងបាន :

$$F(x)=\int f(x)dx=\int\left(\frac{x}{x^2+5}\right)dx=\frac{1}{2}\int\frac{\left(x^2+5\right)'}{x^2+5}dx$$

$$=\frac{1}{2}\ln\left(x^2+5\right)+c \quad ;c\in IR$$

ឃ. $f(x)=e^{3x-2} \quad ;I=IR$ យើងបាន

$$F(x)=\int f(x)dx=\int e^{3x-2}dx$$

$$=\frac{1}{(3x-2)'}e^{3x-2}=\frac{1}{3}e^{3x-2}+c;c\in IR$$

ង. $f(x)=xe^{x^2} \quad ;I=IR$ យើងបាន

$$F(x)=\int(x)dx=\int xe^{x^2}dx$$

$$=\frac{1}{2}\int\left(x^2\right)'e^{x^2}dx=\frac{1}{2}e^{x^2}+c;c\in IR$$

3- រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំណត់ដោយ:

ក. $f(x)=\dfrac{3}{\cos^2 x}$ និង $F\left(\dfrac{\pi}{4}\right)=-1$

ខ. $f(x)=x^2-x$ និង $F(0)=1$

គ. $f(x)=x^2-e^x$ និង $F(0)=1$

ឃ. $f(x)=x^2-xe^{x^2}$ និង $F(0)=1$

**សំរាយបញ្ជាក់ :**

រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំណត់ដោយ:

ក. $f(x)=\dfrac{3}{\cos^2 x}$ និង $F\left(\dfrac{\pi}{4}\right)=-1$ យើងបាន :

$$F(x)=\int f(x)dx=\int\frac{3}{\cos^2 x}dx=3\tan x+c$$

ដោយ $F\left(\dfrac{\pi}{4}\right)=-1\Rightarrow 3\tan\dfrac{\pi}{4}+c=-1\Rightarrow c=-4$

ដូចនេះ $\boxed{F(x)=3\tan x-4}$

ខ. $f(x)=x^2-x$ និង $F(0)=1$ យើងបាន

$$F(x)=\int\left(x^2-x\right)dx=\frac{1}{3}x^3-\frac{1}{2}x^2+c$$

ដោយ $F(0)=1\Rightarrow c=1$

ដូចនេះ $\boxed{F(x)=\dfrac{1}{3}x^3-\dfrac{1}{2}x^2+1}$

គ. $f(x)=x^2-e^x$ និង $F(0)=1$ យើងបាន :

$$F(x)=\int f(x)dx=\int\left(x^2-e^x\right)dx=\frac{1}{3}x^3-e^x+c$$

ដោយ $F(0)=1\Rightarrow -1+c=1\Rightarrow c=2$

ដូចនេះ $\boxed{F(x)=\dfrac{1}{3}x^3-e^x+2}$

ឃ. $f(x)=x^2-xe^{x^2}$ និង $F(0)=1$ យើងបាន :

$$F(x)=\int\left(x^2-xe^{x^2}\right)dx=\int\left(x^2-\frac{1}{2}\left(x^2\right)'e^{x^2}\right)dx$$

$$=\frac{1}{3}x^3-\frac{1}{2}e^{x^2}+c$$

ដោយ $F(0)=1\Rightarrow -\frac{1}{2}+c=1\Rightarrow c=\frac{3}{2}$

ដូចនេះ $\boxed{F(x)=\frac{1}{3}x^3-\frac{1}{2}e^{x^2}+\frac{3}{2}}$

**4-រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f$ ដែលកំណត់ដោយៈ**

**ក.** $f(x)=\sin x$ និង $F(0)=3$

**ខ.** $f(x)=x-e^x$ និង $F(1)=1-e$

**គ.** $f(x)=\frac{x}{\left(x^2-4\right)^3}$ និង $F(5)=3$

**ឃ.** $f(x)=\sin x\cos^3 x$ និង $F\left(\frac{\pi}{4}\right)=16$

**សំរាយបញ្ជាក់ :**

**ក.** $f(x)=\sin x$ និង $F(0)=3$ យើងបាន :

$F(x)=\int\sin x dx=-\cos x+c$

ដោយ $F(0)=3\Rightarrow -1+c=3\Rightarrow c=4$

ដូចនេះ $\boxed{F(x)=-\cos x+4}$

ខ. $f(x)=x-e^x$ និង $F(1)=1-e$ យើងបាន :

$$F(x)=\int\left(x-e^x\right)dx=\frac{1}{2}x^2-e^x+c$$

ដោយ $F(1)=1-e\Rightarrow\frac{1}{2}-e+c=1-e\Rightarrow c=\frac{1}{2}$

ដូចនេះ $\boxed{F(x)=\frac{1}{2}x^2-e^x+\frac{1}{2}}$

គ. $f(x)=\frac{x}{\left(x^2-4\right)^3}$ និង $F(5)=3$ យើងបាន :

$$F(x)=\int\frac{x}{\left(x^2-4\right)^3}dx=\frac{1}{2}\int\left(x^2-4\right)'\left(x^2-4\right)^{-3}dx$$

$$=-\frac{1}{4}\left(x^2-4\right)^{-2}+c=-\frac{1}{4\left(x^2-4\right)^2}+c$$

ដោយ $F(5)=3\Rightarrow-\frac{1}{4\left(25-4\right)^2}+c=3\Rightarrow c=\frac{5293}{1764}$

ដូចនេះ $\boxed{F(x)=-\frac{1}{4\left(x^2-4\right)^2}+\frac{5293}{1764}}$

ឃ. $f(x)=\sin x\cos^3x$ និង $F\left(\frac{\pi}{4}\right)=16$ យើងបាន :

$$F(x)=\int\sin x\cos^3xdx=-\int\left(\cos x\right)'\cos^3xdx$$

$$=-\frac{1}{4}\cos^4x+c$$

ដោយ $F\left(\frac{\pi}{4}\right)=16 \Rightarrow -\frac{1}{4}\times\left(\frac{\sqrt{2}}{2}\right)^4+c=16 \Rightarrow c=\frac{257}{16}$

ដូចនេះ $\boxed{F(x)=-\frac{1}{4}\cos^4 x+\frac{257}{16}}$

5- គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int(2x^3-5x^2+3x+1)dx$ ខ. $\int\left(5-\frac{1}{\sqrt{x}}\right)dx$

គ. $\int 2\sqrt[4]{x}dx$ ឃ. $\int\left(\frac{3}{x^4}+\frac{1}{x^5}\right)dx$

ង. $\int(x^2-1)\sqrt{x}dx$ ច. $\int\left(2e^x+\frac{6}{x}-\ln 5\right)dx$

ឆ. $\int\frac{4x^4-3x^5+1}{x^4}dx$ ជ. $\int\frac{3x^2-2x+1}{\sqrt{x}}dx$

ឈ. $\int(3\sin x+5\cos x)dx$ ញ. $\int\left(\frac{1}{\sin^2 x}+\frac{4}{\cos^2 x}-5\right)dx$

ដ. $\int\frac{e^{3x}+1}{e^x+1}dx$ ឋ. $\int(1-e^x)^2dx$

ឌ. $\int\frac{\cos 2x dx}{\sin^2 x\cos^2 x}$ ឍ. $\int\frac{dx}{\sin^2 x\cos^2 x}$

## សំរាយបញ្ជាក់ :

គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int\left(2x^3-5x^2+3x+1\right)dx=\frac{1}{2}x^4-\frac{5}{3}x^3+\frac{3}{2}x^2+x+c$

ខ. $\int\left(5-\frac{1}{\sqrt{x}}\right)dx=5x-2\sqrt{x}+c \quad ;c\in IR$

គ. $\int 2\sqrt[4]{x}dx=2\int x^{\frac{1}{4}}dx=2\times\frac{4}{5}x^{\frac{5}{4}}+c=\frac{8}{5}x^{\frac{5}{4}}+c \ ;c\in IR$

ឃ. $\int\left(\frac{3}{x^4}+\frac{1}{x^5}\right)dx=\int\left(3x^{-4}+x^{-5}\right)dx=\frac{3}{-3}x^{-3}+\frac{1}{-4}x^{-4}+c$

$=-\frac{1}{x^3}-\frac{1}{4x^4}+c \ ;c\in IR$

ង. $\int\left(x^2-1\right)\sqrt{x}dx=\int\left(x^2-1\right)x^{\frac{1}{2}}dx=\int\left(x^{\frac{5}{2}}-x^{\frac{1}{2}}\right)dx$

$=\frac{2}{7}x^{\frac{3}{2}}-\frac{2}{3}x^{\frac{3}{2}}+c \ ;c\in IR$

ច. $\int\left(2e^x+\frac{6}{x}-\ln 5\right)dx=2e^x+6\ln|x|-x\ln 5+c$

ឆ. $\int\frac{4x^4-3x^5+1}{x^4}dx=\int\left(4-3x+x^{-4}\right)dx$

$=4x-\frac{3}{2}x^2-\frac{1}{3x^3}+c \quad ;c\in IR$

ជ. $\int\frac{3x^2-2x+1}{\sqrt{x}}dx=\int\left(3x^{\frac{3}{2}}-2x^{\frac{1}{2}}+x^{-\frac{1}{2}}\right)dx$

$=\frac{6}{5}x^{\frac{5}{2}}-\frac{3}{4}x^{\frac{3}{2}}+2x^{\frac{1}{2}}+c \quad ;c\in IR$

ឈ. $\int(3\sin x+5\cos x)dx=-3\cos x+5\sin x+c \quad ;c\in IR$

ញ. $\int\left(\frac{1}{\sin^2 x}+\frac{4}{\cos^2 x}-5\right)dx=-\cot x+4\tan x-5x+c, c\in IR$

ដ. $\int\frac{e^{3x}+1}{e^x+1}dx=\int\frac{(e^x+1)(e^{2x}-e^x+1)}{e^x+1}dx$

$=\int(e^{2x}-e^x+1)dx=\frac{1}{2}e^{2x}-e^x+x+c \quad ;c\in IR$

ឋ. $\int(1-e^x)^2dx=\int(1-2e^x+e^{2x})dx$

$=x-2e^x+\frac{1}{2}e^{2x}+c \quad ;c\in IR$

ឌ. $\int\frac{\cos 2x dx}{\sin^2 x\cos^2 x}=\int\frac{\cos^2 x-\sin^2 x}{\sin^2 x\cos^2 x}dx$

$=\int\left(\frac{1}{\sin^2 x}-\frac{1}{\cos^2 x}\right)dx=-\cot x-\tan x+c \quad ;c\in IR$

ឍ. $\int\frac{dx}{\sin^2 x\cos^2 x}=\int\frac{\sin^2 x+\cos^2 x}{\sin^2 x\cos^2 x}dx$

$=\int\left(\frac{1}{\cos^2 x}+\frac{1}{\sin^2 x}\right)dx=\tan x-\cot x+c \quad ;c\in IR$

6- គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int 3e^{3x}dx$

ខ. $\int 2xe^{x^2}dx$

គ. $\int 5e^{4-5x}dx$

ឃ. $\int(6x-7)e^{3x^2-7x}dx$

ង. $\int(3x^2-2x+1)e^{x^3-x^2+x}dx$

ច. $\int\cos x e^{\sin x}dx$

ឆ. $\int xe^{x^2}dx$

ជ. $\int 6x^2e^{x^3}dx$

ឈ. $\int(x+1)e^{x^2+2x}dx$

ញ. $\int\frac{2}{\sqrt{x}e^{\sqrt{x}}}dx$ ។

## សំរាយបញ្ជាក់ :

គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int 3e^{3x}dx=3\times\frac{1}{3}e^{3x}+c=e^{3x}+c\quad;c\in IR$

ខ. $\int 2xe^{x^2}dx=\int(x^2)'e^{x^2}dx=e^{x^2}+c\quad;c\in IR$

គ. $\int 5e^{4-5x}dx=-\int(4-5x)'e^{4-5x}dx=-e^{4-5x}+c$

ឃ. $\int(6x-7)e^{3x^2-7x}dx=\int(3x^2-7x)'e^{3x^2-7x}dx$

$=e^{3x^2-7x}+c\quad;c\in IR$

ង. $\int(3x^2-2x+1)e^{x^3-x^2+x}dx=\int(x^3-x^2+x)'e^{x^3-x^2+x}dx$

$=e^{x^3-x^2+x}+c\quad;c\in IR$

ច. $\int\cos x e^{\sin x}dx=\int(\sin x)'e^{\sin x}dx=e^{\sin x}+c\ ;c\in IR$

ឆ. $\int xe^{x^2}dx=\frac{1}{2}\int(x^2)'e^{x^2}dx=\frac{1}{2}e^{x^2}+c\quad;c\in IR$

ជ. $\int 6x^2e^{x^3}dx=2\int(x^3)'e^{x^3}dx=2e^{x^3}+c\ ;c\in IR$

ឈ. $\int (x+1)e^{x^2+2x}dx = \frac{1}{2}\int (x^2+2x)' e^{x^2+2x}dx$

$= \frac{1}{2}e^{x^2+2x} + c \quad ; c \in IR$

ញ. $\int \frac{2}{\sqrt{x}e^{\sqrt{x}}}dx = -4\int (-\sqrt{x})' e^{-\sqrt{x}}dx = -4e^{-\sqrt{x}} + c \quad ; c \in IR$

7- គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម៖

ក. $\int xe^{-x}dx$

ខ. $\int xe^{\frac{x}{2}}dx$

គ. $\int (1-x)e^{x}dx$

ឃ. $\int (3-2x)e^{-x}dx$

ង. $\int x\ln 2x dx$

ច. $\int x\ln x^2 dx$

ឆ. $\int xe^{-\frac{x}{5}}dx$

ជ. $\int xe^{0.1x}dx$

ឈ. $\int x\sqrt{x-6}dx$

ញ. $\int x\sqrt{1-x}dx$

ដ. $\int x(x+1)^8 dx$

ឋ. $\int (x+1)(x+2)^6 dx$

ឌ. $\int \frac{x}{\sqrt{x+2}}dx$

ឍ. $\int \frac{x}{\sqrt{2x+1}}dx$

ណ. $\int x^2e^{-x}dx$

ត. $\int x^2e^{3x}dx$

ថ. $\int x^3e^{x}dx$

ទ. $\int x^3e^{2x}dx$

ធ. $\int x^2\ln x dx$

ន. $\int x(\ln x)^2 dx$

ប. $\int \frac{\ln x}{x^2} dx$ ផ. $\int \frac{\ln x}{x^3} dx$ ។

**សំរាយបញ្ជាក់ :**

គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int xe^{-x}dx$ តាង $f(x)=x \Rightarrow f'(x)=1$ និង

$g'(x)=e^{-x} \Rightarrow g(x)=-e^{-x}$ យើងបាន :

$$\int xe^{-x}dx=-xe^{-x}+\int e^{-x}dx=-xe^{-x}-e^{-x}+c \ ;c\in IR$$

ខ. $\int xe^{\frac{x}{2}}dx$ តាង $f(x)=x \Rightarrow f'(x)=1$ និង

$g'(x)=e^{\frac{x}{2}} \Rightarrow g(x)=2e^{\frac{x}{2}}$ យើងបាន :

$$\int xe^{\frac{x}{2}}dx=2xe^{\frac{x}{2}}-2\int e^{\frac{x}{2}}dx=2xe^{\frac{x}{2}}-4e^{\frac{x}{2}}+c \ ;c\in IR$$

គ. $\int (1-x)e^{x}dx$ តាង $f(x)=1-x \Rightarrow f'(x)=-1$ និង

$g'(x)=e^{x} \Rightarrow g(x)=e^{x}$ យើងបាន :

$$\int (1-x)e^{x}dx=(1-x)e^{x}+\int e^{x}dx$$

$$=(1-x)e^{x}+e^{x}+c \ ;c\in IR$$

ឃ. $\int (3-2x)e^{-x}dx$ តាង $f(x)=3-2x \Rightarrow f'(x)=-2$

$g'(x)=e^{-x} \Rightarrow g(x)=-e^{-x}$ យើងបាន :

$$\int(3-2x)e^{-x}dx=-(3-2x)e^{-x}-2\int e^{-x}$$

$$=-(3-2x)e^{-x}+2e^{-x}+c=2xe^{-x}-e^{-x}+c\ \ ;c\in IR$$

ង. $\int x\ln 2x dx$ តាង $f(x)=\ln 2x\Rightarrow f'(x)=\dfrac{1}{x}$ និង

$g'(x)=x\Rightarrow g(x)=\dfrac{x^2}{2}$ យើងបាន :

$$\int x\ln 2x dx=\frac{x^2}{2}\ln 2x-\frac{1}{2}\int xdx$$

$$=\frac{x^2}{2}\ln 2x-\frac{1}{4}x^2+c\ \ ;c\in IR$$

ច. $\int x\ln x^2 dx$ តាង $f(x)=\ln x^2\Rightarrow f'(x)=\dfrac{2}{x}$ និង

$g'(x)=x\Rightarrow g(x)=\dfrac{x^2}{2}$ យើងបាន :

$$\int x\ln x^2dx=\frac{x^2}{2}\text{in}\, x^2-\int xdx=\frac{x^2}{2}\ln x^2-\frac{x^2}{2}+c\ \ ;c\in IR$$

ឆ. $\int xe^{-\frac{x}{5}}dx$ តាង $f(x)=x\Rightarrow f'(x)=1$ និង

$g'(x)=e^{-\frac{x}{5}}\Rightarrow g(x)=-5e^{-\frac{x}{5}}$ យើងបាន :

$$\int xe^{-\frac{x}{5}}dx=-5xe^{-\frac{x}{5}}+5\int e^{-\frac{x}{5}}=-5xe^{-\frac{x}{5}}-25e^{-\frac{x}{5}}+c\ ;c\in IR$$

ជ. $\int xe^{0.1x}dx$ តាង $f(x)=x\Rightarrow f'(x)=1$ និង

$g'(x)=e^{0.1x} \Rightarrow g(x)=10e^{0.1x}$ យើងបាន :

$\int xe^{0.1x}dx=10xe^{0.1x}-10\int e^{0.1x}dx$

$=10xe^{0.1x}-100e^{0.1x}+c \quad ;c\in IR$

ឈ. $\int x\sqrt{x-6}dx$ តាង $f(x)=x \Rightarrow f'(x)=1$ និង

$g'(x)=\sqrt{x-6} \Rightarrow g(x)=\frac{2}{3}(x-6)^{\frac{3}{2}}$ យើងបាន :

$$\int x\sqrt{x-6}dx=\frac{2x}{3}(x-6)^{\frac{3}{2}}-\frac{2}{3}\int(x-6)^{\frac{3}{2}}dx$$

$$=\frac{2x}{3}(x-6)^{\frac{3}{2}}-\frac{2}{3}\times\frac{2}{5}(x-6)^{\frac{5}{2}}+c$$

$$=\frac{2x}{3}(x-6)^{\frac{3}{2}}-\frac{4}{15}(x-6)^{\frac{5}{2}}+c \quad ;c\in IR$$

ញ. $\int x\sqrt{1-x}dx$ តាង $f(x)=x \Rightarrow f'(x)=1$ និង

$g'(x)=\sqrt{1-x} \Rightarrow g(x)=-\frac{2}{3}(1-x)^{\frac{3}{2}}$ យើងបាន :

$$\int x\sqrt{1-x}dx=-\frac{2x}{3}(1-x)^{\frac{3}{2}}+\frac{2}{3}\int(1-x)^{\frac{3}{2}}dx$$

$$=-\frac{2x}{3}(1-x)^{\frac{3}{2}}-\frac{4}{15}(1-x)^{\frac{5}{2}}+c \quad ;c\in IR$$

ដ. $\int x(x+1)^8dx$ តាង $f(x)=x \Rightarrow f'(x)=1$ និង

$g'(x)=(x+1)^8 \Rightarrow g(x)=\frac{1}{9}(x+1)^9$ យើងបាន :

$$\int x(x+1)^8 dx = \frac{x}{9}(x+1)^9 - \frac{1}{9}\int (x+1)^9 dx$$

$$= \frac{x}{9}(x+1)^9 - \frac{1}{90}(x+1)^{10} + c \quad ; c \in IR$$

ឋ. $\int (x+1)(x+2)^6 dx$ តាង $f(x) = x+1 \Rightarrow f'(x) = 1$

និង $g'(x) = (x+2)^6 \Rightarrow g(x) = \frac{1}{7}(x+2)^7$ យើងបាន :

$$\int (x+1)(x+2)^6 dx = \frac{(x+1)(x+2)^7}{7} - \frac{1}{7}\int (x+2)^7 dx$$

$$= \frac{(x+1)(x+2)^7}{7} - \frac{1}{56}(x+2)^8 + c \quad ; c \in IR$$

ឌ. $\int \frac{x}{\sqrt{x+2}} dx$ តាង $f(x) = x \Rightarrow f'(x) = 1$ និង

$g'(x) = \frac{1}{\sqrt{x+2}} \Rightarrow g(x) = 2(x+2)^{\frac{1}{2}}$ យើងបាន :

$$\int \frac{x}{\sqrt{x+2}} dx = 2x(x+2)^{\frac{1}{2}} - 2\int (x+2)^{\frac{1}{2}} dx$$

$$= 2x(x+2)^{\frac{1}{2}} - \frac{4}{3}(x+2)^{\frac{3}{2}} + c \quad ; c \in IR$$

ឍ. $\int \frac{x}{\sqrt{2x+1}} dx$ តាង $f(x) = x \Rightarrow f'(x) = 1$ និង

$g'(x) = \frac{1}{\sqrt{2x+1}} \Rightarrow g(x) = (2x+1)^{\frac{1}{2}}$ យើងបាន :

$$\int \frac{x}{\sqrt{2x+1}}dx = x(2x+1)^{\frac{1}{2}} - \int (2x+1)^{\frac{1}{2}}dx$$

$$= x(2x+1)^{\frac{1}{2}} - \frac{1}{3}(2x+1)^{\frac{3}{2}} + c \quad ; c \in IR$$

ណ. $\int x^2 e^{-x}dx$ តាង $f(x) = x^2 \Rightarrow f'(x) = 2x$ និង

$g'(x) = e^{-x} \Rightarrow g(x) = -e^{-x}$ យើងបាន :

$$\int x^2 e^{-x}dx = -x^2 e^{-x} + 2\int xe^{-x}dx$$

ដោយ $\int xe^{-x}dx = -xe^{-x} - e^{-x} + c \; ; c \in IR$

$$\Rightarrow \int x^2 e^{-x}dx = -x^2 e^{-x} - 2xe^{-x} - 2e^{-x} + c \; ; c \in IR \, .$$

ត. $\int x^2 e^{3x}dx$ តាង $f(x) = x^2 \Rightarrow f'(x) = 2x$ និង

$g'(x) = e^{3x} \Rightarrow g(x) = \frac{1}{3}e^{3x}$ យើងបាន :

$$\int x^2 e^{3x}dx = \frac{1}{3}x^2 e^{3x} - \frac{2}{3}\int xe^{3x}dx$$

គណនា $\int xe^{3x}dx$ តាង $f(x) = x \Rightarrow f'(x) = 1$ និង

$g'(x) = e^{3x} \Rightarrow g(x) = \frac{1}{3}e^{3x}$ យើងបាន :

$$\int xe^{3x}dx = \frac{x}{3}e^{3x} - \frac{1}{3}\int e^{3x} = \frac{x}{3}e^{3x} - \frac{1}{9}e^{3x} + c$$

$$\Rightarrow \int x^2 e^{3x}dx = \frac{1}{3}x^2 e^{3x} - \frac{2}{3}\left(\frac{x}{3}e^{3x} - \frac{1}{9}e^{3x} + c\right)$$

$$= \frac{1}{3}x^2e^{3x} - \frac{2x}{9}e^{3x} + \frac{2}{27}e^{3x} + c \quad ;c \in IR$$

ថ. $\int x^3e^x dx$ តាង $f(x) = x^3 \Rightarrow f'(x) = 3x^2$

និង $g'(x) = e^x \Rightarrow g(x) = e^x$ យើងបាន :

$$\int x^3e^x dx = x^3e^x - 3\int x^2e^x dx$$

តែ $\int x^2e^x dx$ តាង $f(x) = x^2 \Rightarrow f'(x) = 2x$ និង

$g'(x) = e^x \Rightarrow g(x) = e^x$ យើងបាន :

$\int x^2e^x dx = x^2e^x - 2\int xe^x dx$ និង $\int xe^x dx$ តាង

$f(x) = x \Rightarrow f'(x) = 1$ និង $g'(x) = e^x \Rightarrow g(x) = e^x$

$$\Rightarrow \int xe^x dx = xe^x - \int e^x dx = xe^x - e^x + c$$

$$\Rightarrow \int x^2e^x dx = x^2e^x - 2\left(xe^x - e^x + c\right)$$

$$= x^2e^x - 2xe^x + 2e^x + c$$

$$\Rightarrow \int x^3e^x dx = x^3e^x - 3\left(x^2e^x - 2xe^x + 2e^x + c\right)$$

$$= x^3e^x - 3x^2e^x + 6xe^x - 6e^x + c \quad ;c \in IR$$

ទ. $\int x^3e^{2x} dx = \frac{1}{2}x^3e^{2x} - \frac{3}{4}x^2e^{2x} + \frac{3}{4}xe^{2x} - \frac{3}{8}e^{2x} + c; c \in IR$

ស្រាយដូចខាងលើ :

ធ. $\int x^2 \ln x dx$ តាង $f(x) = \ln x \Rightarrow f'(x) = \frac{1}{x}$ និង

$$g'(x)=x^2 \Rightarrow g(x)=\frac{1}{3}x^3$$ យើងបាន :

$$\int x^2 \ln x dx=\frac{1}{3}x^3 \ln x-\frac{1}{3}\int x^2 dx$$

$$=\frac{1}{3}x^3 \ln x-\frac{1}{9}x^3+c \quad ;c\in IR$$

ឱ. $\int x(\ln x)^2 dx$ តាង $f(x)=(\ln x)^2 \Rightarrow f'(x)=\frac{2}{x}\ln x$

និង $g'(x)=x \Rightarrow g(x)=\frac{x^2}{2}$ យើងបាន :

$$\int x(\ln x)^2 dx=\frac{x^2}{2}(\ln x)^2-\int x\ln x dx$$

តែ $\int x\ln x dx$ តាង $f(x)=\ln x \Rightarrow f'(x)=\frac{1}{x}$ និង

$g'(x)=x \Rightarrow g(x)=\frac{x^2}{2}$ យើងបាន :

$$\int x\ln x dx=\frac{x^2}{2}\ln x-\frac{1}{2}\int x dx=\frac{x^2}{2}\ln x-\frac{1}{4}x^2+c$$

$$\Rightarrow \int x(\ln x)^2 dx=\frac{x^2}{2}(\ln x)^2-\frac{x^2}{2}\ln x+\frac{1}{4}x^2+c \ ;c\in IR$$

ឋ. $\int \frac{\ln x}{x^2}dx$ តាង $f(x)=\ln x \Rightarrow f'(x)=\frac{1}{x}$ និង

$g'(x)=\frac{1}{x^2} \Rightarrow g(x)=-\frac{1}{x}$ យើងបាន :

$$\int\frac{\ln x}{x^2}dx=-\frac{\ln x}{x}+\int\frac{1}{x^2}dx=-\frac{\ln x}{x}-\frac{1}{x}+c\quad ;c\in IR$$

ផ. $\int\frac{\ln x}{x^3}dx$ តាង $f(x)=\ln x\Rightarrow f'(x)=\frac{1}{x}$ និង

$g'(x)=\frac{1}{x^3}\Rightarrow g(x)=-\frac{1}{2x^2}$ យើងបាន:

$$\int\frac{\ln x}{x^3}dx=-\frac{\ln x}{2x^2}-\frac{1}{2}\int\frac{1}{x^3}dx=-\frac{\ln x}{2x^2}-\frac{1}{2}\int x^{-3}dx$$

$$=-\frac{\ln x}{2x^2}-\frac{1}{4x^2}+c\quad ;c\in IR$$

**8-** តម្លៃរបស់រថយន្តមាន ការថយចុះជារៀងរាល់ឆ្នាំស្របទៅនឹងអាយុកាលរបស់វា។ បើអត្រាចុះកំណត់ដោយអនុគមន៍ : $f(t)=-100t(t+3)^{-2}$ (គិតជាម៉ឺនរៀល) ដែល $t$ ជាអាយុកាលរបស់រថយន្តគិតជាឆ្នាំ។ រកអនុគមន៍នៃតម្លៃរថយន្ត ក្នុងរយះពេល $t$ ឆ្នាំដោយដឹងថាតម្លៃរថយន្ត ពេលទើបផលិតថ្មី $F(0)=1200$ (គិតជាម៉ឺនរៀល) ។

## សំរាយបញ្ជាក់ :

រកអនុគមន៍នៃតម្លៃរថយន្ត ក្នុងរយះពេល $t$ ឆ្នាំ

ដោយ $f(t)=-100t(t+3)^{-2}$ យើងបាន :

$$F(t)=\int f(t)dt=-100\int t(t+3)^{-2}dt$$

តាង $f(t)=t \Rightarrow f'(t)=1$ និង

$g'(t)=(t+3)^{-2} \Rightarrow g(t)=-\frac{1}{t+3}$ យើងបាន :

$$F(t)=-100\left(-\frac{t}{t+3}+\int\frac{dt}{t+3}\right)=\frac{100t}{t+3}-100\ln|t+3|+c$$

ដោយ $F(0)=1200$ យើងបាន :

$$F(0)=-100\ln 3+c=1200 \Rightarrow c=1200+100\ln 3$$

ដូចនេះ $\boxed{F(t)=\frac{100t}{t+3}-100\ln|t+3|+1200+100\ln 3}$

9- តម្លៃដីនៅតាមកសិដ្ឋានមានការកើនឡើងជារៀងរាល់ឆ្នាំ ដែលអត្រាកំណើននៃតម្លៃដីក្នុងមួយហិចតាកំណត់ដោយអនុគមន៍

$V'(x)=\frac{0.4x^3}{\sqrt{0.2x^4+8000}}$ (គិតជាម៉ឺនរៀល) ហើយ $x$ ជាចំនួនឆ្នាំ

បើគេដឹងថាតម្លៃដីពេលបច្ចុប្បន្ន900 (គិតជាម៉ឺនរៀល) ក្នុងមួយហិចតា ។រកអនុគមន៍តម្លៃដីមួយហិចតានៅរយៈពេល 10ឆ្នាំទៅមុខទៀត

**សំរាយបញ្ជាក់ :**

រកអនុគមន៍តម្លៃដីមួយហិចតានៅរយៈពេល 10ឆ្នាំទៅមុខទៀត

ដោយ $V'(x)=\frac{0.4x^3}{\sqrt{0.2x^4+8000}}$ យើងបាន :

$$V(x)=\int\frac{0.4x^3}{\sqrt{0.2x^4+8000}}dx$$

$$=\frac{1}{2}\int(0.2x^4+8000)'(0.2x^4+8000)^{-\frac{1}{2}}$$

$$=(0.2x^4+8000)^{\frac{1}{2}}+c$$

ដោយ $V(0)=900\Rightarrow 8000^{\frac{1}{2}}+c=900\Rightarrow c=900-89=811$

យើងបាន $V(x)=(0.2x^4+8000)^{\frac{1}{2}}+811$

$\Rightarrow V(10)=(0.2\times10^4+8000)^{\frac{1}{2}}+811=911$ ម៉ឺនរៀល ។

ដូចនេះ $\boxed{V(10)=911}$ ម៉ឺនរៀល .

**10-** អត្រាកំណើនប្រជាពលរដ្ឋក្នុងទីក្រុងមួយជាអនុគមន៍

$P'(t)=5+4t^{\frac{1}{3}}$ នាក់ក្នុងមួយខែ ដែល $t$ ជាចំនួនខែ ។

បើគេដឹងថាចំនួនប្រជាពលរដ្ឋបច្ចុប្បន្ន មាន 2 000 000នាក់ ។

រកអនុគមន៍នៃចំនួនប្រជាពលរដ្ឋនៅរយះពេល8ខែទៅមុខទៀត ។

**សំរាយបញ្ជាក់ :**

ដោយ $P'(t)=5+4t^{\frac{1}{3}}$ យើងបាន :

$$P(x)=\int\left(5+4t^{\frac{1}{3}}\right)dt=5t+4\times\frac{3}{4}t^{\frac{4}{3}}+c=5t+3t^{\frac{4}{3}}+c$$

ដោយ $P(0) = c = 2000000$

$\Rightarrow P(8) = 5\times 8 + 3\times 8^{\frac{4}{3}} + 2000000 = 2000088$ នាក់

ដូចនេះ $\boxed{P(8) = 2000088}$ នាក់

## មេរៀនទី២ : អាំងតេក្រាលកំណត់

### លំហាត់

1- គណនាតម្លៃនៃ :

ក. $\int_1^2 f(x)dx + \int_2^1 f(x)dx$ ខ. $\int_1^1 \frac{f(x)}{3}dx$ ។

**សំរាយបញ្ជាក់ :**

គណនាតម្លៃនៃ :

ក. $\int_1^2 f(x)dx + \int_2^1 f(x)dx = \int_1^2 f(x)dx - \int_1^2 f(x)dx = 0$

ខ. $\int_1^1 \frac{f(x)}{3}dx = \frac{1}{3}[F(1) - F(1)] = 0$

2- គេមាន $f$ និង $g$ ជាអនុគមន៍ជាប់ហើយ $\int_1^2 f(x)dx = -4$

$\int_2^5 f(x)dx = 6$ ; $\int_1^5 g(x)dx = 8$ ។ គណនា :

ក . $\int_1^5 f(x)dx$ ខ. $\int_5^1 [-4f(x)]dx$

គ. $\int_1^5 [4f(x) - 2g(x)]dx$

**សំរាយបញ្ជាក់ :**

ក . $\int_1^5 f(x)dx = \int_1^2 f(x)dx + \int_2^5 f(x)dx = -4 + 6 = 2$

ខ. $\int_5^1 [-4f(x)]dx = 4\int_1^5 f(x)dx = 8$

គ. $\int_1^5[4f(x)-2g(x)]dx=4\int_1^5 f(x)dx-2\int_1^5 g(x)dx$

$=4\times2-2\times8=-8$

3- ចូរគណនាតម្លៃនៃ $k$ បើ $\int_1^k \frac{1}{\sqrt{2x-1}}dx=2$ ។

**សំរាយបញ្ជាក់ :**

គណនាតម្លៃនៃ $k$ បើ $\int_1^k \frac{1}{\sqrt{2x-1}}dx=2$

យើងមាន : $\int_1^k \frac{1}{\sqrt{2x-1}}dx=\int_1^k(2x-1)^{-\frac{1}{2}}=\left[\sqrt{2x-1}\right]_1^k$

$=\left(\sqrt{2k-1}-1\right)$

តែ $\int_1^k \frac{1}{\sqrt{2x-1}}dx=2\Rightarrow\left(\sqrt{2k-1}-1\right)=2\Rightarrow\sqrt{2k-1}=3$

$\Rightarrow 2k-1=9\Rightarrow k=5$

ដូចនេះ $\boxed{k=5}$

4- គណនា :

ក. $\int_1^1\left(3x^2+1\right)dx$

ខ. $\int_1^2\left(\frac{1}{x^2}-3\right)dx$

គ. $\int_4^9\frac{2}{\sqrt{x}}dx$

ឃ. $\int_2^4\sqrt{x-2}dx$

ង. $\int_2^4\sqrt[3]{x-2}dx$

ច. $\int_{-4}^0\frac{1}{\sqrt{4-x}}dx$

ង. $\int_5^1 \frac{1}{\sqrt{3x+1}}dx$ ច. $\int_1^3 5x\left(x^2-7\right)^3 dx$

ឈ. $\int_0^2 3x^2\sqrt{x^3+1}dx$ ញ. $\int_1^2 \frac{x+2}{\sqrt{x^2+4x+1}}dx$

ដ. $\int_1^4\left(\frac{3-\sqrt{x}}{\sqrt{x}}\right)dx$ ឋ. $\int_0^1\left(3x^2-2x\right)^2 dx$

ឌ. $\int_0^4\left[\frac{x+1}{\left(x^2+2x+2\right)^3}\right]dx$ ។

## សំរាយបញ្ជាក់ :

គណនា :

ក. $\int_1^1\left(3x^2+1\right)dx=0$

ខ. $\int_1^2\left(\frac{1}{x^2}-3\right)dx=\left[-\frac{1}{x}-3x\right]_1^2=\left(-\frac{1}{2}-6\right)-(-1-3)=-\frac{5}{2}$

គ. $\int_4^9 \frac{2}{\sqrt{x}}dx=4\left[\sqrt{x}\right]_4^9=4(3-2)=4$

ឃ. $\int_2^4\sqrt{x-2}dx=\int_2^4(x-2)^{\frac{1}{2}}dx=\frac{2}{3}\left[(x-2)^{\frac{3}{2}}\right]_2^4$

$=\frac{2}{3}\left(2\sqrt{2}-0\right)=\frac{4\sqrt{2}}{3}$

ង. $\int_2^4\sqrt[3]{x-2}dx=\int_2^4(x-2)^{\frac{1}{3}}dx=\frac{3}{4}\left[(x-2)^{\frac{4}{3}}\right]_2^4$

$$= \frac{3}{4}\left(2\sqrt[3]{2}-0\right) = \frac{3\sqrt[3]{2}}{2}$$

ច. $\int_{-4}^{0} \frac{1}{\sqrt{4-x}}dx = \int_{-4}^{0}(4-x)^{-\frac{1}{2}}dx = -2\left[\sqrt{4-x}\right]_{-4}^{0}$

$$= -2\left(2-2\sqrt{2}\right) = -4+4\sqrt{2}$$

ឆ. $\int_{5}^{1} \frac{1}{\sqrt{3x+1}}dx = \int_{5}^{1}(3x+1)^{-\frac{1}{2}}dx = \frac{2}{3}\left[\sqrt{3x+1}\right]_{5}^{1}$

$$= \frac{2}{3}(2-4) = -\frac{4}{3}$$

ជ. $\int_{1}^{3} 5x\left(x^2-7\right)^3 dx = \frac{5}{2}\int_{1}^{3}\left(x^2-7\right)'\left(x^2-7\right)^3 dx$

$$= \frac{5}{8}\left[\left(x^2-7\right)^4\right]_{1}^{3} = \frac{5}{8}(16-1296) = -800$$

ឈ. $\int_{0}^{2} 3x^2\sqrt{x^3+1}dx = \int_{0}^{2}\left(x^3+1\right)'\left(x^3+1\right)^{\frac{1}{2}}dx$

$$= \frac{2}{3}\left[\left(x^3+1\right)^{\frac{3}{2}}\right]_{0}^{2} = \frac{2}{3}(27-1) = \frac{52}{3}$$

ញ. $\int_{1}^{2} \frac{x+2}{\sqrt{x^2+4x+1}}dx = \frac{1}{2}\int_{1}^{2}\left(x^2+4x+1\right)'\left(x^2+4x+1\right)^{-\frac{1}{2}}dx$

$$= \left[\left(x^2+4x+1\right)^{\frac{1}{2}}\right]_{1}^{2} = \sqrt{13}-\sqrt{6}$$

ដ. $\int_{1}^{4}\left(\frac{3-\sqrt{x}}{\sqrt{x}}\right)dx = \int_{1}^{4}\left(3x^{-\frac{1}{2}}-1\right)dx$

$$=\left[6\sqrt{x}-x\right]_1^4=(12-4)-(6-1)=3$$

ឋ. $\int_0^1\left(3x^2-2x\right)^2dx=\int_0^1\left(9x^4-12x^3+4x^2\right)dx$

$$=\left[\frac{9}{5}x^5-3x^4+\frac{4}{3}x^3\right]_0^1=\frac{9}{5}-3+\frac{4}{3}=\frac{27-45+20}{15}=\frac{2}{15}$$

ឌ. $\int_0^4\left[\frac{x+1}{\left(x^2+2x+2\right)^3}\right]dx$

$$=\frac{1}{2}\int_0^4\left(x^2+2x+2\right)'\left(x^2+2x+2\right)^{-3}dx=-\frac{1}{4}\left[\frac{1}{\left(x^2+2x+2\right)^2}\right]_0^4$$

$$=-\frac{1}{4}\left(\frac{1}{676}-\frac{1}{4}\right)=-\frac{1}{4}\times\frac{-168}{676}=\frac{168}{2704}=\frac{21}{338}$$

**5.** គណនា :

ក. $\int_1^2 3e^{4x}dx$ ខ. $\int_0^1 4x^3e^{2x^4}dx$ គ. $\int_1^4\frac{e^{\sqrt{x}}}{\sqrt{x}}dx$

ឃ. $\int_1^3 3e^{2x}\left(e^{-2x}-1\right)dx$ ង. $\int_0^1\frac{dx}{2+3x}$ ។

## ដំណោះស្រាយ :

គណនា :

ក. $\int_1^2 3e^{4x}dx=\frac{3}{4}\left[e^{4x}\right]_1^2=\frac{3}{4}\left(e^8-e^4\right)$

ខ. $\int_0^1 4x^3e^{2x^4}dx = \frac{1}{2}\int_0^1 (2x^4)' e^{2x^4}dx = \frac{1}{2}\left[e^{2x^4}\right]_0^1$

$= \frac{1}{2}\left(e^2 - 1\right)$

គ. $\int_1^4 \frac{e^{\sqrt{x}}}{\sqrt{x}}dx = 2\int_1^4 (\sqrt{x})' e^{\sqrt{x}}dx = 2\left[e^{\sqrt{x}}\right]_1^4 = 2\left(e^2 - e\right)$

ឃ. $\int_1^3 3e^{2x}\left(e^{-2x} - 1\right)dx = \int_1^3 \left(3 - 3e^{2x}\right)dx = \left[3x - \frac{3}{2}e^{2x}\right]_1^3$

$= \left(9 - \frac{3}{2}e^6\right) - \left(3 - \frac{3}{2}e^2\right) = 6 - \frac{3}{2}e^6 + \frac{3}{2}e^2$

ង. $\int_0^1 \frac{dx}{2+3x} = \frac{1}{3}\int_0^1 \frac{(2+3x)'}{2+3x}dx = \frac{1}{3}\left[\ln|2+3x|\right]_0^1$

$= \frac{1}{3}(\ln 5 - \ln 2) = \frac{1}{3}\ln\frac{5}{2}$

**6.** គណនា :

ក. $\int_0^1 \frac{2x^2}{1+2x^3}dx$

ខ. $\int_1^{\ln 2} \frac{e^x}{4e^x - 2}dx$

គ. $\int_0^2 \frac{x}{(1+x^2)}dx$

ឃ. $\int_1^e \frac{(\ln x)^2}{x}dx$

ង. $\int_0^1 xe^{2x^2}dx$

ច. $\int_0^{\frac{\pi}{3}} \tan x dx$

ឆ. $\int_1^e \frac{(1+\ln x)^2}{2x}dx$

ជ. $\int_e^{e^2} \frac{1}{x\ln x}dx$

## សំរាយបញ្ជាក់ :

ក. $\int_0^1 \frac{2x^2}{1+2x^3}dx = \frac{1}{3}\int_0^1 \frac{\left(1+2x^3\right)'}{1+2x^3}dx$

$= \frac{1}{3}\left[\ln\left|1+2x^3\right|\right]_0^1 = \frac{1}{3}(\ln 3 - \ln 1) = \frac{1}{3}\ln 3$

ខ. $\int_1^{\ln 2} \frac{e^x}{4e^x-2}dx = \frac{1}{4}\int_1^{\ln 2} \frac{\left(4e^x-2\right)'}{4e^x-2}dx = \frac{1}{4}\left[\ln\left|4e^x-2\right|\right]_1^{\ln 2}$

$= \frac{1}{4}(\ln 6 - \ln(4e-2)) = \frac{1}{4}\ln 6 - \frac{1}{4}\ln(4e-2)$

គ. $\int_0^2 \frac{x}{\left(1+x^2\right)}dx = \frac{1}{2}\int_0^2 \frac{\left(1+x^2\right)'}{\left(1+x^2\right)}dx$

$= \frac{1}{2}\left[\ln\left|1+x^2\right|\right]_0^2 = \frac{1}{2}(\ln 5 - \ln 1) = \frac{1}{2}\ln 5$

ឃ. $\int_1^e \frac{(\ln x)^2}{x}dx = \int_1^e (\ln x)'(\ln x)^2 dx$

$= \frac{1}{3}\left[(\ln x)^3\right]_1^e = \frac{1}{3}\left(\ln^3 e - \ln^3 1\right) = \frac{1}{3}$

ង. $\int_0^1 xe^{2x^2}dx = \frac{1}{4}\int_0^1 \left(2x^2\right)'e^{2x^2}dx = \frac{1}{4}\left[e^{2x^2}\right]_0^1 = \frac{1}{4}\left(e^2-1\right)$

ច. $\int_0^{\frac{\pi}{3}} \tan x dx = \int_0^{\frac{\pi}{3}} \frac{\sin x}{\cos x}dx = -\int_0^{\frac{\pi}{3}} \frac{(\cos x)'}{\cos x}dx = -\left[\ln|\cos x|\right]_0^{\frac{\pi}{3}}$

$= -\left(\ln\cos\frac{\pi}{3} - \ln\cos 0\right) = -\left(\ln\frac{1}{2} - \ln 1\right) = -\ln 2^{-1} = \ln 2$

ឆ. $\int_1^e \frac{(1+\ln x)^2}{2x}dx = \frac{1}{2}\int_1^e (1+\ln x)'(1+\ln x)^2 dx$

$= \frac{1}{6}\left[(1+\ln x)^3\right]_1^e = \frac{1}{6}\left[(1+\ln e)^3 - (1+\ln 1)^3\right]$

$= \frac{1}{6}(8-1) = \frac{7}{6}$

ជ. $\int_e^{e^2} \frac{1}{x\ln x}dx = \int_e^{e^2} \frac{(\ln x)'}{\ln x}dx$

$= \left[\ln\ln x\right]_e^{e^2} = \ln\ln e^2 - \ln\ln e = \ln 2 - \ln 1 = \ln 2$

7- សហគ្រាសមួយ ទទួលបានប្រាក់ចំណូលបន្ថែមពីការលក់ផលិតផល ប្រើប្រាស់ចំនួន $t$ គ្រឿង ។ បើអត្រានៃចំណូលបន្ថែមកំណត់ដោយ អនុគមន៍ $R'(t) = 180 + 0.2t$ ( គិតជាពាន់រៀល ) ក្នុងមួយគ្រឿង រកបម្រែបម្រួលនៃប្រាក់ចំណូលក្នុងការលក់កើនឡើងពីចំនួន 30ទៅ 40គ្រឿង ។

## សំរាយបញ្ជាក់ :

បម្រែបម្រួលនៃប្រាក់ចំណូលក្នុងការលក់កើនឡើងពីចំនួន 30ទៅ40 គ្រឿងកំណត់ដោយ :

$\int_{30}^{40}(180+0.2t)dt = \left[180t + 0.1t^2\right]_{30}^{40}$

$= (7200+160) - (5400+90) = 1870$ គិតជាពាន់រៀល

# លំហាត់ជំពូក៤

1. គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int 2xdx$ ខ. $\int 4dx$

គ. $\int (2x+3)dx$ ឃ. $\int (-2)dx$

ង. $\int (-5x+4)dx$ ច. $\int x^2dx$

ឆ. $\int 3x^2dx$ ជ. $\int \left(-4x^2+5x+7\right)dx$

ឈ. $\int \left(-4x^7-5x^4+7x^3-6x+8\right)dx$

ញ. $\int \frac{1}{x^2}dx$ ដ. $\int \frac{-5}{x^2}dx$

ឋ. $\int \left(4-\frac{7}{x^2}\right)dx$ ឌ. $\int \frac{3}{4}\sqrt{x}dx$

ឍ. $\int \left(4\sqrt{x}+\frac{4}{x^2}\right)dx$ ណ. $\int \frac{3}{4}\sqrt{2x+1}dx$

ត. $\int (3x-1)^2 dx$ ថ. $\int 5(3x-1)^4 dx$

ទ. $\int 5x\left(3x^2-1\right)^4 dx$ ធ. $\int 2\left(2x^3+1\right)^4 6x^2dx$

ន. $\int 2x^2\left(2x^3+1\right)^4 dx$ ។

## សំរាយបញ្ជាក់ :

គណនាអាំងតេក្រាលមិនកំណត់ខាងក្រោម:

ក. $\int 2xdx = x^2 + c \quad ;c\in IR$

ខ. $\int 4dx = 4x + c \quad ;c\in IR$

គ. $\int (2x+3)dx = x^2 + 3x + c \quad ;c\in IR$

ឃ. $\int (-2)dx = -2x + c \quad ;c\in IR$

ង. $\int (-5x+4)dx = -\frac{5}{2}x^2 + 4x + c \quad ;c\in IR$

ច. $\int x^2dx = \frac{1}{3}x^3 + c \quad ;c\in IR$

ឆ. $\int 3x^2dx = x^3 + c \quad ;c\in IR$

ជ. $\int (-4x^2+5x+7)dx = -\frac{4}{3}x^3 + \frac{5}{2}x^2 + 7x + c \quad ;c\in IR$

ឈ. $\int (-4x^7 - 5x^4 + 7x^3 - 6x + 8)dx$

$= -\frac{1}{2}x^8 - x^5 + \frac{7}{4}x^4 - 3x^2 + 8x + c \quad ;c\in IR$

ញ. $\int \frac{1}{x^2}dx = \int x^{-2}dx = -\frac{1}{x} + c \quad ,c\in IR$

ដ. $\int \frac{-5}{x^2}dx = \frac{5}{x} + c \quad ,c\in IR$

ឋ. $\int \left(4 - \frac{7}{x^2}\right)dx = 4x + \frac{7}{x} + c \quad ;c\in IR$

ឌ. $\int \frac{3}{4}\sqrt{x}dx = \frac{1}{2}x^{\frac{3}{2}} + c \quad ;c\in IR$

ឍ. $\int\left(4\sqrt{x}+\frac{4}{x^2}\right)dx=\frac{8}{3}x^{\frac{3}{2}}-\frac{4}{x}+c \quad ;c\in IR$

ណ. $\int\frac{3}{4}\sqrt{2x+1}dx=\frac{1}{4}(2x+1)^{\frac{3}{2}}+c \quad ;c\in IR$

ត. $\int(3x-1)^2dx=\frac{1}{9}(3x-1)^3+c \quad ;c\in IR$

ថ. $\int5(3x-1)^4dx=\frac{1}{3}(3x-1)^5+c \quad ;c\in IR$

ទ. $\int5x\left(3x^2-1\right)^4dx=\frac{5}{6}\int\left(3x^2-1\right)'\left(3x^2-1\right)^4dx$

$=\frac{1}{6}\left(3x^2-1\right)^5+c \quad ;c\in IR$

ធ. $\int2\left(2x^3+1\right)^4 6x^2dx=2\int\left(2x^3+1\right)'\left(2x^3+1\right)^4dx$

$=\frac{2}{5}\left(2x^3+1\right)^5+c \quad ;c\in IR$

ន. $\int2x^2\left(2x^3+1\right)^4dx=\frac{1}{3}\int\left(2x^3+1\right)'\left(2x^3+1\right)^4dx$

$=\frac{1}{15}\left(2x^3+1\right)^5+c \quad ;c\in IR$

2- គណនាអាំងតេក្រាលដោយប្រើអថេរជំនួសៈ

ក. $\int_2^3 2(2x+1)\left(x^2+x-3\right)dx$ ខ. $\int_{\frac{1}{2}}^0(4x+1)e^{2x^2+x}dx$

គ. $\int_2^3\frac{2x+1}{x^2+x-1}dx$ ឃ. $\int_0^1 xe^{x^2+1}dx$

ង. $\int_{\frac{\pi}{4}}^{\frac{\pi}{3}} \sin x \cos x dx$ ច. $\int_{0}^{\frac{\pi}{2}} \sin x \cos^5 x dx$

ឆ. $\int_{-\frac{\pi}{2}}^{0} \cos x\left(\sin x + \sin^3 x\right)dx$ ជ. $\int_{0}^{\frac{\pi}{4}} \frac{\sin x}{\cos^3 x}dx$

ឈ. $\int_{\frac{\pi}{4}}^{\frac{\pi}{2}} \frac{\cos x}{\sin^2 x}dx$ ញ. $\int_{e}^{\sqrt{e}} \frac{\ln x}{x}dx$

ដ. $\int_{1}^{2} \frac{10x+1}{\sqrt{5x^2+x+3}}dx$ ឋ. $\int_{1}^{2} \frac{e^{\frac{1}{x}}}{x^2}dx$

ឌ. $\int_{1}^{e} \frac{\ln x+1}{x}dx$ ឍ. $\int_{0}^{\pi} (\cos x)\left(1-3\sin^2 x\right)dx$

## សំរាយបញ្ជាក់ :

គណនាអាំងតេក្រាលដោយប្រើអថេរជំនួស:

ក. $\int_{2}^{3} 2(2x+1)\left(x^2+x-3\right)dx$ តាង $t = x^2 + x - 3$

$\Rightarrow dt = (2x+1)dx$ បើ $x = 2 \Rightarrow t = 3; x = 3; t = 9$

$\int_{2}^{3} 2(2x+1)\left(x^2+x-3\right)dx = 2\int_{3}^{9} tdt = \left[t^2\right]_{3}^{9} = 81-9 = 72$

ខ. $\int_{-\frac{1}{2}}^{0} (4x+1)e^{2x^2+x}dx$ តាង $t = 2x^2 + x \Rightarrow dt = (4x+1)dx$

បើ $x = -\frac{1}{2} \Rightarrow t = 0; x = 0 \Rightarrow t = 0$ យើងបាន :

$\int_{-\frac{1}{2}}^{0} (4x+1)e^{2x^2+x}dx = \int_{0}^{0} e^t dt = 0$

| $\sum x = 48$ | $\sum y = 881$ | $\sum xy = 4679$ | $\sum x^2 = 270$ | $\sum y^2 = 91321$ |

$$a = \frac{n\sum xy - \sum x \sum y}{n\sum x^2 - \left(\sum x\right)^2} = \frac{10\times 4679 - 48\times 881}{10\times 270 - (48)^2} = 11.37$$

$$b = \frac{1}{n}\left(\sum y - a\sum x\right) = \frac{1}{10}(881 - 11.37\times 48) = 33.52$$

$$\Rightarrow y = 11.37x + 33.52$$

ខ. រកតម្លៃរថយន្តដែលមានចំណាស់ 5ឆ្នាំ និង2ឆ្នាំ

ដោយ $y = 11.37x + 33.52$ យើងបាន :

បើ $x = 5 \Rightarrow y = 11.37\times 5 + 33.52 = 90.37$

បើ $x=2 \Rightarrow y=11.37\times 2+33.52=56.26$

គ. រកមេគុណតម្រែតម្រង់លីនេអ៊ែ

$$r=\frac{n\sum xy-\sum x\sum y}{\sqrt{n\sum x^2-\left(\sum x\right)^2}\times\sqrt{n\sum y^2-\left(\sum y\right)^2}}$$

$$=\frac{10\times 4679-48\times 881}{\sqrt{10\times 270-48^2}\times\sqrt{10\times 91321-881^2}}=0.61$$

ដោយ $r=0.61$ បញ្ជាក់ថា $x$ និង $y$ មិនសូវមានទំនាក់ទំនងគ្នាល្អទេ ។

**8-** នៅរយៈពេល 5 ឆ្នាំចុងក្រោយនេះ អ្នកគ្រប់គ្រងផ្នែកឃោសនាពាណិជ្ជកម្មម្នាក់បានប្រមូលទិន្នន័យដែលបង្ហាញពីទំនាក់ទំនងរវាងចំនួនថវិកាឃោសនាទំនិញ ( គិតជាកោដិរៀល ) និងបរិមាណផលិតផលដែលលក់បាន ( គិតជាពាន់ឯកតាផលិតផល ) ។គេបានតារាងទិន្នន័យដូចខាងក្រោម:

| | | | | | |
|---|---|---|---|---|---|
| $x_i$ ចំនួនថវិកាឃោសនា | 4.5 | 6.5 | 3.5 | 3.2 | 2.6 |
| $y_i$ បរិមាណផលិតផលលក់បាន | 37 | 46 | 42 | 32 | 29 |

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែរ ។

ខ. ធ្វើការប៉ាន់ស្មានបរិមាណឯកតាផលិតផលដែលបានលក់ បើគេចំណាយថវិកាអស់ 4 កោដិរៀល ។

គ. រកមេគុណតម្រែតម្រង់លីនេអ៊ែរ ។

**សំរាយបញ្ជាក់ :**

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែរ :

| $x_i$ | $y_i$ | $x_i y_i$ | $x_i^2$ | $y_i^2$ |
|---|---|---|---|---|
| 4.5 | 37 | 166.5 | 20.25 | 1369 |
| 6.5 | 46 | 299 | 42.25 | 2116 |
| 3.5 | 42 | 147 | 12.25 | 1764 |
| 3.2 | 32 | 102.4 | 10.24 | 1024 |
| 2.6 | 29 | 75.4 | 6.76 | 841 |
| $\sum x = 20.3$ | $\sum y = 186$ | $\sum xy = 790.3$ | $\sum x^2 = 91.75$ | $\sum y^2 = 7204$ |

$$a = \frac{n\sum xy - \sum x \sum y}{n\sum x^2 - (\sum x)^2} = \frac{5\times 790.3 - 20.3\times 186}{5\times 91.75 - (20.3)^2} = 3.76$$

$$b = \frac{1}{n}(\sum y - a\sum x) = \frac{1}{5}(186 - 3.76\times 20.3) = 22$$

$$\Rightarrow y = 3.76x + 22$$

ខ. ចំពោះ $x = 4 \Rightarrow y = 3.76\times 4 + 22 = 37.04$

គ. រកមេគុណតម្រែតម្រង់លីនេអ៊ែរ :

$$r = \frac{n\sum xy - \sum x\sum y}{\sqrt{n\sum x^2 - (\sum x)^2}\times\sqrt{n\sum y^2 - (\sum y)^2}}$$

$$= \frac{5\times 790.3 - 20.3\times 186}{\sqrt{5\times 91.75 - (20.3)^2}\times\sqrt{5\times 7204 - (186)^2}} = 0.68$$

ដោយ $r = 0.68$ បញ្ជាក់ថា $x$ និង $y$ មិនសូវមានទំនាក់ទំនងគ្នាខ្លាំងទេ ។

# លំហាត់ជំពូក៥

**1-** គេឱ្យតារាងស្ថិតិនៃពីរអថេរខាងក្រោម:

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| $x_i$ | 3 | 2 | 3.5 | 4 | 5 | 6 | 6.5 | 7 | 8 | 9 |
| $y_i$ | 11 | 13 | 20 | 25 | 19 | 30 | 35 | 38 | 32 | 40 |

**ក.** បកស្រាយស្ថិតិនៃពីរអថេរជាចំណុច ។

**ខ.** ផ្គុំចំណុចខាងលើជាពីរក្រុម ។

**គ.** រកចំណុចមធ្យម $M_1$ និង $M_2$ រួចរកសមីការបន្ទាត់ដែល កាត់តាម $M$ និង $M_2$ ។

## សំរាយបញ្ជាក់ :

**ក.** បកស្រាយស្ថិតិនៃពីរអថេរជាចំណុច

$(3;11);(2;13);(3.5;20);(4;25);(5;19);(6;30)$

$(6.5;35);(7;38);(8;32);(9;40)$ ។

**ខ.** ផ្គុំចំណុចខាងលើជាពីរក្រុម

**ក្រុមទី១:** $(3;11);(2;13);(3.5;20);(4;25);(5;19)$

**ក្រុមទី២:** $(6;30);(6.5;35);(7;38);(8;32);(9;40)$ ។

**គ.** រកចំណុចមធ្យម $M_1$ និង $M_2$

$M_1$ មាន $x_1 = \dfrac{3+2+3.5+4+5}{5} = 3.5$

$$y_1 = \frac{11+13+20+25+19}{5} = 17.6$$

$M_2$ មាន $x_2 = \frac{6+6.5+7+8+9}{5} = 7.3$

$$y_2 = \frac{30+35+38+32+40}{5} = 35$$

យើងបាន សមីការបន្ទាត់កាត់តាមចំណុច $M_1$ និង $M_2$ កំណត់ដោយ:

$$\frac{y-17.6}{x-3.5} = \frac{35-17.5}{7.3-3.5} \Rightarrow y = 4.58x + 1.57$$

**2-** គេមានសមីការបន្ទាត់ $y = -0.6x + 3$ និង $y = -x + 3$ និងតារាងទិន្នន័យ:

| $x_i$ | 0 | 2 | 2 | 5 | 6 |
|---|---|---|---|---|---|
| $y_i$ | 4 | 2 | 0 | -2 | 1 |

ក. ចូរសង់តារាងផលបូកនៃ $x_i$ និង $y_i; y; d$ និង $d^2$ ។

ខ. តើបន្ទាត់មួយណាដែលនៅជិតចំណុចទាំងនោះជាងគេ?

គ. ដោយប្រើបន្ទាត់ដែលរកឃើញ គណនាតម្លៃ $y$ ចំពោះ $x = 3$ និង $x = 4$ ។

**សំរាយបញ្ជាក់ :**

ក. ចំពោះ $y = -0.6x + 3$ យើងបាន តារាងផលបូក :

| $x_i$ | $y_i$ | $y$ | $d$ | $d^2$ |
|---|---|---|---|---|
| 0 | 4 | 3 | 1 | 1 |
| 2 | 2 | 1.8 | 0.2 | 0.04 |
| 2 | 0 | 1.8 | −1.8 | 3.24 |
| 5 | −2 | 0 | −2 | 4 |
| 6 | 1 | −0.6 | 1.6 | 2.56 |
| | | | | $\sum d^2 = 10.84$ |

ចំពោះ $y = -x + 3$ យើងបាន តារាងផលបូក :

| $x_i$ | $y_i$ | $y$ | $d$ | $d^2$ |
|---|---|---|---|---|
| 0 | 4 | 3 | 1 | 1 |
| 2 | 2 | 1 | 1 | 1 |
| 2 | 0 | 1 | −1 | 1 |
| 5 | −2 | −2 | 0 | 0 |
| 6 | 1 | −3 | 4 | 16 |
| | | | | $\sum d^2 = 19$ |

ខ. តើបន្ទាត់មួយណាដែលនៅជិតចំណុចទាំងនោះជាងគេ?

ដោយ $\sum d^2$ នៃបន្ទាត់ $y = -0.6x + 3$ តូចជាង $\sum d^2$ នៃបន្ទាត់ $y = -x + 3$ នោះ ចំណុចទាំងនោះនៅជិតបន្ទាត់ $y = -0.6x + 3$ ។

គ. ដោយ $y = -0.6x + 3$

ចំពោះ $x = 3 \Rightarrow y = 1.2; x = 4 \Rightarrow y = 0.6$

**3-** តារាងទិន្នន័យខាងក្រោមបង្ហាញ ពីចំនួនប្រាក់ដែលចំណាយលើការសាង

សង់ក្នុងតំបន់មួយនៅអំឡុងពេល 5ខែ ។

| $x_i$ ខែ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា |
|---|---|---|---|---|---|
| $y_i$ ចំនួនប្រាក់( គិតជាពាន់ដុល្លារ) | 15 | 17 | 24 | 20 | 25 |

បើ $x_i = 0$ តាងខែមករា

**ក.** រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែរ ។

**ខ.** ចូរធ្វើការប៉ាន់ស្មានចំនួនប្រាក់ដែលនឹងចំណាយក្នុងខែមិថុនា ។

**សំរាយបញ្ជាក់ :**

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអែ

| $x_i$ | $y_i$ | $x_i y_i$ | $x_i^2$ | $y_i^2$ |
|---|---|---|---|---|
| 0 | 15 | 0 | 0 | 225 |
| 1 | 17 | 17 | 1 | 289 |
| 2 | 24 | 48 | 4 | 576 |
| 3 | 20 | 60 | 9 | 400 |
| 4 | 25 | 100 | 16 | 625 |
| $\sum x = 10$ | $\sum y = 101$ | $\sum xy = 225$ | $\sum x^2 = 30$ | $\sum y^2 = 2115$ |

$$a = \frac{n\sum xy - \sum x \sum y}{n\sum x^2 - (\sum x)^2} = \frac{5\times 225 - 10\times 101}{5\times 30 - 10^2} = 2.3$$

$$b = \frac{1}{n}\left(\sum y - a\sum x\right) = \frac{1}{5}(101 - 2.3\times 10) = 15.6$$

$$\Rightarrow y = 2.3x + 15.6$$

ខ. ខែមិថុនាត្រូវនឹង $x = 5 \Rightarrow y = 2.3\times5+15.6 = 27.1$

**4-** ចូរពិនិត្យតារាងទិន្នន័យនៃពីរអថេរ :

| $x_i$ | -3 | -2 | -1 | 0 | 1 | 2 | 3 |
|---|---|---|---|---|---|---|---|
| $y_i$ | 9 | 4 | 1 | 0 | 1 | 4 | 9 |

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែរ ។

ខ. រកមេគុណតម្រែតម្រង់លីនេអ៊ែ $r$ ។

គ. តាមតម្លៃ $r$ ខាងលើ តើ $x_i$ និង $y_i$ មានទំនាក់ទំនងគ្នាដែរឬទេ? តើគេអាចប្រើសមីការតម្រែតម្រង់លីនេអ៊ែខាងលើសម្រាប់ធ្វើការប៉ាន់ស្មានលទ្ធផលឬទេ?

## សំរាយបញ្ជាក់ :

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែរ :

| $x_i$ | $y_i$ | $x_i y_i$ | $x_i^2$ | $y_i^2$ |
|---|---|---|---|---|
| $-3$ | 9 | $-27$ | 9 | 81 |
| $-2$ | 4 | $-8$ | 4 | 16 |
| $-1$ | 1 | $-1$ | 1 | 1 |
| 0 | 0 | 0 | 0 | 0 |
| 1 | 1 | 1 | 1 | 1 |
| 2 | 4 | 8 | 4 | 16 |
| 3 | 9 | 27 | 9 | 81 |

| | | | | |
|---|---|---|---|---|
| $\sum x=0$ | $\sum y=28$ | $\sum xy=0$ | $\sum x^2=28$ | $\sum y^2=196$ |

$$a=\frac{n\sum xy-\sum x\sum y}{n\sum x^2-\left(\sum x\right)^2}=\frac{7\times 0-0\times 28}{7\times 28-0}=0$$

$$b=\frac{1}{n}\left(\sum y-a\sum x\right)=\frac{1}{7}(28-0)=4$$

$$\Rightarrow y=4$$

ខ. រកមេគុណតំរែតម្រង់លីនេអ៊ែ $r$

$$r=\frac{n\sum xy-\sum x\sum y}{\sqrt{n\sum x^2-\left(\sum x\right)^2}\times\sqrt{n\sum y^2-\left(\sum y\right)^2}}=0$$

គ. ដោយ $r=0$ យើងឃើញថាចំណុច $x_i$ និង $y_i$ ពុំមានទំនាក់ទំនងធៀបទៅនឹងបន្ទាត់ $y=4$ ។

## ជំពូក៦ កោនិក

## មេរៀនទី១ ប៉ារ៉ាបូល

### លំហាត់ :

**1-** រកកូអរដោនេកំពូល កំណុំនិងសមីការបន្ទាត់ ប្រាប់ទិសនៃប៉ារ៉ាបូលខាងក្រោម រួចសង់ក្រាបះ

ក. $y^2 = 4x$ ខ. $y^2 = 12x$ គ. $x^2 = 8y$

ឃ. $x^2 = -2y$ ង. $(y+2)^2 = 4(x-1)$

ច. $(y-1)^2 = -(x+3)$ ឆ. $(x-3)^2 = 2(y+2)$

ជ. $(x-1)^2 + 8(y+2) = 0$ ឈ. $(x+3) + (y-2)^2 = 0$

ញ. $\left(x+\frac{1}{2}\right)^2 = 4(y-3)$ ។

### សំរាយបញ្ជាក់ :

រកកូអរដោនេកំពូល កំណុំនិងសមីការបន្ទាត់ ប្រាប់ទិសនៃប៉ារ៉ាបូលខាងក្រោម រួចសង់ក្រាបះ

តាង $I$ ជាកំពូល និង $F$ ជាកំណុំ :

ក. $y^2 = 4x \Rightarrow I(0;0); F(1;0)$ និង បន្ទាត់ប្រាប់ទិស $x = -1$

ខ. $y^2 = 12x \Rightarrow I(0;0); F(3;0)$ និង បន្ទាត់ប្រាប់ទិស $x = -3$

គ. $x^2 = 8y \Rightarrow I(0;0); F(0;2)$ និងបន្ទាត់ប្រាប់ទិស $y = -2$

ឃ. $x^2 = -2y \Rightarrow I(0;0); F\left(0;-\frac{1}{2}\right)$ និង $y = \frac{1}{2}$



ង. $(y+2)^2 = 4(x-1) \Rightarrow I(1;-2); F(2;-2)$ និង $x = 0$



ច. $(y-1)^2 = -(x+3) \Rightarrow I(-3;1); F\left(-\frac{13}{4};1\right)$ និង $x=-\frac{11}{4}$

ឆ. $(x-3)^2 = 2(y+2) \Rightarrow I(3;-2); F\left(3;-\frac{3}{2}\right)$ និង $y=-\frac{5}{2}$







ជ. $(x-1)^2+8(y+2)=0 \Rightarrow I(1;-2); F(1;-4)$ និង $y=0$

ឈ. $(x+3)+(y-2)^2=0 \Rightarrow I(-3;2)\cdot F\left(-\frac{13}{4};2\right)$ និង

$x=-3+\frac{1}{4}=-\frac{11}{4}$






ញ. $\left(x+\frac{1}{2}\right)^2=4(y-3)\Rightarrow I\left(-\frac{1}{2};3\right);F\left(-\frac{1}{2};4\right)$ និង $y=2$




2-បម្លែងសមីការទូទៅនីមួយៗខាងក្រោមទៅជាសមីការស្តង់ដា :

ក. $x^2-2x-3y-8=0$ ខ. $4x-y^2-2y-33=0$

គ. $y^2-4y-4x=0$ ឃ. $x^2+4x+4y-4=0$

ង. $9y^2-36y-2x+24=0$ ច. $y^2-4x+4y+24=0$

**សំរាយបញ្ជាក់ :**

ក. $x^2-2x-3y-8=0\Rightarrow x^2-2x+1=3y+9$

$\Rightarrow(x-1)^2=3(y+3)$

ខ. $4x-y^2-2y-33=0\Rightarrow y^2-2y+1=4x-32$

$\Rightarrow(y-1)^2=4(x-8)$

គ. $y^2-4y-4x=0\Rightarrow y^2-4y+4=4x+4$

$\Rightarrow(y-2)^2=4(x+1)$

ឃ. $x^2+4x+4y-4=0 \Rightarrow x^2+4x+4=-4y+8$

$\Rightarrow (x+2)^2=-4(y-2)$

ង. $9y^2-36y-2x+24=0 \Rightarrow 9y^2-36y+36=2x+12$

$\Rightarrow 9(y-2)^2=2(x+6) \Rightarrow (y-2)^2=\frac{2}{9}(x+6)$

ច. $y^2-4x+4y+24=0 \Rightarrow y^2+4y+4=4x-20$

$\Rightarrow (y+2)^2=4(x-5)$

**3.** រកកូអរដោនេនៃកំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិសនៃប៉ារ៉ាបូល តាមសមីការនីមួយៗខាងក្រោម រួចសង់ក្រាប:

ក. $y=\frac{1}{4}(x^2-2x+5)$ ខ. $y^2+6y+8x+25=0$

គ. $x^2+4x+4y-4=0$ ឃ. $y^2+4y+8x-12=0$

ង. $2x^2+4x-9y+20=0$ ច. $4y^2+8y-3x+10=0$

**សំរាយបញ្ជាក់ :**

រកកូអរដោនេនៃកំពូល កំណុំ និងសមីការបន្ទាត់ប្រាប់ទិសនៃប៉ារ៉ាបូល តាមសមីការនីមួយៗខាងក្រោម រួចសង់ក្រាប:

ក. $y=\frac{1}{4}(x^2-2x+5) \Rightarrow (x-1)^2=4(y-1)$

យើងបាន $I(1;1); F(1;2)$ និង $y=0$

ខ. $y^2+6y+8x+25=0 \Rightarrow (y+3)^2=-8(x+2)$

យើងបាន $I(-2;-3);F(-4;-3)$ និង $x=-4$





គ. $x^2+4x+4y-4=0 \Rightarrow (x+2)^2=-4(y-2)$

យើងបាន $I(-2;2);F(-2;1)$ និង $y=3$

ឃ. $y^2+4y+8x-12=0 \Rightarrow (y+2)^2=-8(x-2)$

យើងបាន $I(2;-2);F(0;-2)$ និង $x=4$





ង. $2x^2+4x-9y+20=0 \Rightarrow (x+1)^2=\dfrac{9}{2}(y-2)$

យើងបាន $I(-1;2);F\left(-1;\dfrac{25}{8}\right)$ និង $x=-\dfrac{17}{8}$




ច. $4y^2+8y-3x+10=0 \Rightarrow (y+1)^2=\frac{3}{4}(x-2)$

យើងបាន $I(2;-1);F\left(\frac{35}{16};-1\right)$ និង $x=\frac{29}{16}$ ។




**4-** រកសមីការនៃប៉ារ៉ាបូលដែលកំណត់ដោយលក្ខខណ្ឌដូចខាងក្រោម:

ក. កំពូល $V(0;0)$ និងកំណុំ $F(2;0)$

ខ. កំពូល $V(3;2)$ និងសំណុំ $F(1;2)$

គ. កំពូល $V(0;-4)$ និងសមីការបន្ទាត់ប្រាប់ទិស $y-2=0$

ឃ. កំពូល $V(-2;1)$ និងសមីការបន្ទាត់ប្រាប់ទិស $x-1=0$

ង. កំណុំ $F(2;1)$ និងសមីការបន្ទាត់ប្រាប់ទិស $x=-2$

ច. អ័ក្សឆ្លុះនៃប៉ារ៉ាបូលស្របនិងអ័ក្សអាប់ស៊ីសហើយក្រាបកាត់តាមចំណុច $(4;2)$ ; $(0;0)$ និងចំណុច $(3;-3)$ ។

## សំរាយបញ្ជាក់ :

រកសមីការនៃប៉ារ៉ាបូលដែលកំណត់ដោយលក្ខខណ្ឌដូចខាងក្រោម:

ក. កំពូល $V(0;0)$ និងកំណុំ $F(2;0)$

សមីការមានរាង $y^2=4px$

ដោយ $F(2;0)$ យើងបាន $p=2 \Rightarrow y^2=8x$

ខ. កំពូល $V(3;2)$ និងសំណុំ $F(1;2)$

សមីការស្តង់ដាមានរាង $(y-k)^2=4p(x-h)$

ដោយ $\begin{cases} V(3;2) \\ F(1;2) \end{cases} \Rightarrow \begin{cases} h=3 \\ k=2 \\ p=-2 \end{cases}$

$\Rightarrow (y-2)^2=-8(x-3)$

គ. កំពូល $V(0;-4)$ និងសមីការបន្ទាត់ប្រាប់ទិស $y-2=0$

សមីការស្តង់ដាមានរាង $(x-h)^2=4p(y-k)$

ដោយ កំពូល$V(0;-4) \Rightarrow h=0;k=-4$ និងសមីការបន្ទាត់ ប្រាប់ទិស

$y-2=0 \Rightarrow -4-p=2 \Rightarrow p=-6$

$\Rightarrow x^2=-24(y+4)$

**ឃ.** កំពូល $V(-2;1)$ និងសមីការបន្ទាត់ប្រាប់ទិស $x-1=0$

សមីការស្តង់ដាមានរាង $(y-k)^2=4p(x-h)$

ដោយ កំពូល$V(-2;1) \Rightarrow h=-2;k=1$ និងសមីការបន្ទាត់ ប្រាប់ទិស

$x-1=0 \Rightarrow -2-p=1 \Rightarrow p=-3$

$\Rightarrow (y-1)^2=-12(x+2)$

**ង.** កំណុំ $F(2;1)$ និងសមីការបន្ទាត់ប្រាប់ទិស $x=-2$

សមីការស្តង់ដាមានរាង $(y-k)^2=4p(x-h)$

ដោយ កំណុំ $F(2;1) \Rightarrow \begin{cases} h+p=2 \\ k=1 \end{cases}$ និងសមីការបន្ទាត់ប្រាប់ទិស

$x=-2 \Rightarrow h-p=-2$ តាមសមីការខាងលើយើងបាន :

$\begin{cases} h+p=2 \\ h-p=-2 \end{cases} \Rightarrow h=0; p=2$

$\Rightarrow (y-1)^2=8x$

**ច.** អ័ក្សឆ្លុះនៃប៉ារ៉ាបូលស្របនិងអ័ក្សអាប់ស៊ីស ហើយក្រាបកាត់តាម

ចំណុច $(4;2)$ ;$(0;0)$ និងចំណុច $(3;-3)$

ដោយសមីការស្តង់ដាមានរាង $(y-k)^2=4p(x-h)$ កាត់តាមចំណុច

$(4;2)$ ; $(0;0)$ និងចំណុច $(3;-3)$ យើងបាន :

$$\begin{cases}(2-k)^2=4p(4-h)\\ k^2=4p(-h)\\ (-3-k)^2=4p(3-h)\end{cases}\Rightarrow\begin{cases}4-4k+k^2=16p-4ph\ (1)\\ k^2=-4ph\ (2)\\ 9+6k+k^2=12p-4ph\ (3)\end{cases}$$

យក (2) ជំនួសក្នុង (1) និង (3) យើងបាន :

$$\begin{cases}4-4k-4ph=16p-4ph\\ 9+6k-4ph=12p-4ph\end{cases}\Rightarrow\begin{cases}1-k=4p\\ 3+2k=4p\end{cases}$$

$$\Rightarrow k=-\frac{2}{3};p=\frac{5}{12};h=-\frac{4}{15}$$

$$\Rightarrow\left(y+\frac{2}{3}\right)^2=\frac{5}{3}\left(x+\frac{4}{15}\right)$$

**5-** រកសមីការនៃបន្ទាត់ប៉ះទៅនឹងក្រាបនៃប៉ារ៉ាបូល $y^2=2x$ ដែលកាត់តាមចំណុច $(-4;1)$ ។

**សំរាយបញ្ជាក់ :**

រកសមីការនៃបន្ទាត់ប៉ះទៅនឹងក្រាបនៃប៉ារ៉ាបូល :

សមីការបន្ទាត់ប៉ះមានរាង $y=ax+b$ កាត់តាមចំណុច$(-4;1)$

$$\Rightarrow 1=-4a+b\Rightarrow b=1+4a\Rightarrow y=ax+1+4a$$

$$\Rightarrow x=\frac{y-1-4a}{a}\quad(1)$$

ដោយប៉ារ៉ាបូល $y^2=2x\Rightarrow x=\frac{y^2}{2}$ (2)

ផ្ទឹម (1) និង(2) យើងបាន $\frac{y-1-4a}{a}=\frac{y^2}{2}$

$\Rightarrow ay^2-2y+2+8a=0$ បន្ទាត់នឹងប៉ារ៉ាបូលប៉ះគ្នាកាលណា :

$\Delta'=0 \Rightarrow 1-a(2+8a)=0 \Rightarrow -8a^2-2a+1=0$

$\Rightarrow a=\frac{1}{4}; a=-\frac{1}{2}$

- បើ $a=\frac{1}{4} \Rightarrow b=2$ យើងបាន $y=\frac{1}{4}x+2$

- បើ $a=-\frac{1}{2} \Rightarrow b=-1$ យើងបាន $y=-\frac{1}{2}x-1$

**6-** រកសមីការនៃប៉ារ៉ាបូលដែលអ័ក្សឆ្លុះស្របនិងអ័ក្សអរដោនេ ហើយមាន កំពូល $V(0;2)$ ដែលកាត់តាមចំណុច $P(4;8)$ ។

**សំរាយបញ្ជាក់ :**

រកសមីការនៃប៉ារ៉ាបូលដែលអ័ក្សឆ្លុះស្របនិងអ័ក្សអរដោនេ

សមីការស្តង់ដាមានរាង $(x-h)^2=4p(y-k)$

ដោយ កំពូល $V(0;2) \Rightarrow h=0; k=2$ នោះ $x^2=4p(y-2)$

កាត់តាមចំណុច $P(4;8)$ យើងបាន $16=24p \Rightarrow p=\frac{2}{3}$

$\Rightarrow x^2=\frac{8}{3}(y-2)$

**7-** ចំណុច $P$ មួយចល័តដែលមានចម្ងាយស្មើពីចំណុច $F(-1;2)$ និងបន្ទាត់មួយមានសមីការ $y-6=0$ ។ រកសមីការនៃសំណុំចំណុចនៃចំណុច $P$ ។

**សំរាយបញ្ជាក់ :**




រកសមីការនៃសំណុំចំណុចនៃចំណុច $P$

តាង $P(x;y)$ និង $H(x;6)$

ដោយ $PH = PF$

$\Rightarrow \sqrt{(x-x)^2+(6-y)^2}$

$= \sqrt{(-1-x)^2+(2-y)^2}$

$\Rightarrow 36-12y+y^2$

$= 1+2x+x^2+4-4y+y^2$

$\Rightarrow x^2+2x+1=-12y+36+4y-4$

$\Rightarrow (x+1)^2=-8(y-4)$

សំណុំចំណុច $P$ គឺជាប៉ារ៉ាបូលដែលមានកំពូល $V(-1;4)$ កំណុំ $F(-1;2)$ និងបន្ទាត់ប្រាប់ទិស $y=6$ ។

**8-** រកសមីការនៃប៉ារ៉ាបូល ដែលមានអ័ក្សឆ្លុះជាអ័ក្សឈរ ហើយក្រាបវាកាត់តាមចំណុច $A(2;5)$ ; $B(-2;-3)$ និង $C(1;6)$ ។

**សំរាយបញ្ជាក់ :**

រកសមីការនៃប៉ារ៉ាបូល

សមីការស្តង់ដាមានរាង $(x-h)^2=4p(y-k)$ កាត់តាមចំណុច $A(2;5)$ ; $B(-2;-3)$ និង $C(1;6)$ យើងបាន :

$$\begin{cases}(2-h)^2=4p(5-k)\\(-2-h)^2=4p(-3-k)\\(1-h)^2=4p(6-k)\end{cases}$$

$$\Rightarrow h=1;k=6;p=-\frac{1}{4}\Rightarrow(x-1)^2=-(y-6)$$

**9-** រកសមីការនៃប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះជាអ័ក្សដេក ហើយក្រាបវាកាត់តាមចំណុច $A(-1;1)$ ; $B(11;-2)$ និង $C(5;-1)$ ។

**សំរាយបញ្ជាក់ :**

រកសមីការនៃប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះជាអ័ក្សដេក :

សមីការស្តង់ដាមានរាង $(y-k)^2=4p(x-h)$ កាត់តាមចំណុច $A(-1;1)$ ; $B(11;-2)$ និង $C(5;-1)$ យើងបាន :

$$\begin{cases}(1-k)^2=4p(-1-h)\\(-2-k)^2=4p(11-h)\Rightarrow h=-\frac{5}{4};k=\frac{3}{2};p=\frac{1}{4}\\(-1-k)^2=4p(5-h)\end{cases}$$

$$\Rightarrow\left(y-\frac{3}{2}\right)^2=x+\frac{5}{4}$$

**10-** តាង $m$ និង $b$ ជាចំនួនពិតពីរខុសពីសូន្យ ។បើបន្ទាត់ $y=mx+b$ កាត់ប៉ារ៉ាបូល $y^2=4px$ ត្រង់ចំណុចមួយ ។បង្ហាញថា $p=mb$ ។បង្ហាញថាបន្ទាត់ប៉ះទៅនឹងប៉ារ៉ាបូល $y^2=4px$ ត្រង់ចំណុច $P(x_1;y_1)$ មានមេគុណេ

ប្រាប់ទិសស្មើនឹង $\frac{y_1}{2x_1}$ ។

**សំរាយបញ្ជាក់ :**

ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} y^2 = 4px \\ y = mx + b \end{cases} \Rightarrow (mx+b)^2 = 4px$

$\Rightarrow m^2x^2 + (2mb - 4p)x + b^2 = 0$

បន្ទាត់ប៉ះនឹងប៉ារ៉ាបូលលុះត្រាតែ $\Delta' = 0$

$\Rightarrow \Delta' = (mb - 2p)^2 - m^2b^2 = -4mbp + 4p^2 = 0$

$\Rightarrow 4p(-mb + p) = 0 \Rightarrow p = bm$

ប្រើចំណុច $P(x_1; y_1)$ ; $y = mx + b \Rightarrow b = mx_1 - y_1$ និង

$p = mb = m(y_1 - mx_1)$ (1) តែ $y_1^2 = 4px_1 \Rightarrow p = \frac{y_1^2}{4x_1}$ (2)

តាម (1) និង (2) យើងបាន :

$m(y_1 - mx_1) = \frac{y_1^2}{4x_1} \Rightarrow 4x_1^2m^2 - 4x_1y_1m + y_1^2 = 0$

មេគុណប្រាប់ទិស $m = \frac{4x_1y_1 \pm \sqrt{16x_1^2y_1^2 - 16x_1^2y_1^2}}{8x_1^2} = \frac{y_1}{2x_1}$

**11-** ថាសផ្កាយរណបមួយមានរាងជា ផ្ទៃដែលបានពីរង្វិលនៃប៉ារ៉ាបូលជុំវិញអ័ក្សរបស់វា ។ ការផ្សាយចេញពីផ្កាយរណបបានមកប៉ះ ផ្ទៃនៃថាស ហើយត្រូវបានចាំងផ្លាតទៅប្រសព្វគ្នាត្រង់ចំណុចមួយដែលបានដាក់គ្រឿង ទទួល (**រូប ក**) ។បើមាត់ថាសមានអង្កត់ផ្ចិត $3m$ និងមានជម្រៅពីផ្ចិតទៅកំពូល

$1.2m$ ។តើគ្រឿងទទួលត្រូវដាក់នៅត្រូវទីតាំងណា?

**សំរាយបញ្ជាក់ :**



សមីការស្តង់ដានៃប៉ារ៉ាបូលគឺ :

$x^2 = 4py$

បើយមានកំណុំ $(o; p)$ ។ចំណុច

$(1.5;1.2)$ ស្ថិតនៅលើប៉ារ៉ាបូលគេបាន:

$1.5^2 = 4\times1.2\times p$

$\Rightarrow p = \dfrac{2.25}{4.8} = 0.47$

ដូចនេះ គ្រឿងទទួលខុសត្រូវស្ថិតនៅ $0.47m$ ពីកំពូលនៃថាសផ្កាយរណប ហើយស្ថិតនៅលើអ័ក្សឆ្លុះនៃប៉ារ៉ាបូល ។

**12**-ចង្កៀងភ្លើងបញ្ចាំងមើលផ្លូវមួយមានបន្ទះឆ្លាតពន្លឺជា ផ្ទៃដែលបានមកពី រង្វិលនៃប៉ារ៉ាបូលជុំវិញអ័ក្សរបស់វា។ បើប្រភពពន្លឺស្ថិតលើអ័ក្សឆ្លុះចម្ងាយ $0.6m$ ពីបាត និងនៅមុខកាត់ មាត់ចង្កៀងមានអង្កត់ផ្ចិត $1.5m$ ។ តើ ចង្កៀងនេះមានជម្រៅប៉ុន្មានម៉ែត?

**សំរាយបញ្ជាក់ :**




យើងឃើញថាប៉ារ៉ាបូលនេះកំណត់ដោយ

$x^2 = 4py$ ដែល $p = 0.6m$

$$\Rightarrow x^2 = 2.4y \text{ ដែល } x = \frac{1.5}{2} = \frac{3}{4}$$

$$\Rightarrow \left(\frac{3}{4}\right)^2 = 2.4y \Rightarrow y = \frac{9}{16}\times\frac{1}{2.4} = 0.23m$$

**13-**ផ្នែកខាងក្រៅនៃស្ពានមួយមានរាងជាប៉ារ៉ាបូល ។ ចម្ងាយរវាងចុងនៃមែកប៉ារ៉ាបូលស្មើនឹង $36m$ និងផ្នែកខាងក្រោមនៃស្ពានដែលមានរាងប៉ារ៉ាបូលមានកម្ពស់អតិបរមា $7.5m$ (**រូប ខ**) ។ រកកម្ពស់នៃចំណុច នៅលើប៉ារ៉ាបូលដែលមានចម្ងាយ $3m$ ;$9m$ និង$15m$ ពីផ្ចិត ។




(រូប ខ.)

**សំរាយបញ្ជាក់ :**

រកកម្ពស់នៃចំណុច នៅលើប៉ារ៉ាបូលដែលមានចម្ងាយ $3m$ ;$9m$ និង$15m$ ពីផ្ចិត

សមីការប៉ារ៉ាបូលរាង $x^2 = 4py$ ដែល$OH = 7.5m$ និង $OA' = 18$



យើងបាន : $A(18;7.5)$ យកជំនួសក្នុង $x^2 = 4py$ នោះយើងបាន :

សមីការប៉ារ៉ាបូល $18^2 = 4\times7.5p \Rightarrow p = 10.8$

$\Rightarrow x^2 = 43.2y$

តាង ចំណុច $B(3;y_o)$ ផ្ទៀងផ្ទាត់សមីការប៉ារ៉ាបូល :

$9 = 43.2y_o \Rightarrow y_o = 0.21$

$\Rightarrow H'B = H'B' - BB' = 7.5 - 0.21 = 7.29m$

ដូចនេះ $B(3;7.29)$

តាង $C(9;y_o)$ យកជំនួសដូចខាងលើ យើងបាន $y_o = 5.63$

តាង $D(15;y_o)$ យកជំនួសដូចខាងលើ យើងបាន $y_o = 2.3$

**14-** ខ្សែកាបនៃស្ពានព្យួរមួយមានរាងជាប៉ារ៉ាបូលត្រូវបានចងព្យួរនៅចន្លោះប៉មពីរមានចម្ងាយ $120m$ ពីគ្នា និងមានកម្ពស់ $15m$ ពីផ្លូវថ្នល់ (**រូប គ**) ។ខ្សែកាបនេះបានប៉ះផ្ទៃផ្លូវត្រង់ចំណុចកណ្ដាលរវាងប៉មទាំងពីរ ។ រកសមីការប៉ារ៉ាបូលនៃខ្សែកាបនីមួយៗ ។



(រូប គ.)

**សំរាយបញ្ជាក់ :**

សមីការប៉ារ៉ាបូលមានរាង $x^2 = 4py$

កាត់តាមចំនុច $(120;15)$ យើងបាន :

$$120^2 = 4\times 15p \Rightarrow y = \frac{14400}{60} = 240$$

$$\Rightarrow x^2 = 960y$$

## មេរៀនទី២ : អេលីប

### លំហាត់ :

1- រកកូអរដោនេនៃផ្ចិត កំពូល កំណុំ និងអ៊ិចសង់ទ្រីស៊ីតេនៃអេលីប ហើយសង់អេលីបនីមួយៗ។

ក. $x^2+4y^2=4$ ខ. $5x^2+2y^2=10$

គ. $\dfrac{(x-3)^2}{16}+\dfrac{(y+4)^2}{9}=1$ ឃ. $(x+2)^2+\dfrac{(y+4)^2}{\frac{1}{4}}=1$

ង. $\dfrac{(x-1)^2}{9}+\dfrac{(y-5)^2}{25}=1$ ច. $\dfrac{(x+2)^2}{4}+\dfrac{(y+2)^2}{25}=1$

### សំរាយបញ្ជាក់ :

រកកូអរដោនេនៃផ្ចិត កំពូល កំណុំ និងអ៊ិចសង់ទ្រីស៊ីតេនៃអេលីប ហើយសង់អេលីបនីមួយៗ :

ក. $x^2+4y^2=4 \Rightarrow \dfrac{x^2}{4}+\dfrac{y^2}{1}=1$ យើងបាន :

$h=0;k=0;a=2;b=1;c=\sqrt{4-1}=\sqrt{3}$

ផ្ចិត $(0;0)$ កំពូល $(-2;0);(2;0)$ កំណុំ $\left(-\sqrt{3};0\right);\left(\sqrt{3};0\right)$

និង $e=\dfrac{c}{a}=\dfrac{\sqrt{3}}{2}$ ។

ខ. $5x^2+2y^2=10 \Rightarrow \dfrac{x^2}{2}+\dfrac{y^2}{5}=1$ មាន :

$h=0;k=0;a=\sqrt{5};b=\sqrt{2};c=\sqrt{3}$

ផ្ចិត $(0;0)$ កំពូល$\left(0;-\sqrt{5}\right);\left(0;\sqrt{5}\right)$ កំណុំ $\left(0;-\sqrt{3}\right);\left(0;\sqrt{3}\right)$

និង $e=\frac{c}{a}=\frac{\sqrt{3}}{\sqrt{5}}$ ។

គ. $\frac{(x-3)^2}{16}+\frac{(y+4)^2}{9}=1$ មាន :

$h=3;k=-4;a=4;b=3;c=\sqrt{7}$

ផ្ចិត $(3;-4)$ កំពូល $(-1;-4);(7;-4)$ កំណុំ

$\left(3-\sqrt{7};-4\right);\left(3+\sqrt{7};-4\right)$ និង $e=\frac{c}{a}=\frac{\sqrt{7}}{4}$ ។

ឃ. $(x+2)^2+\frac{(y+4)^2}{\frac{1}{4}}=1$ មាន :

$h=-2;k=-4;a=1;b=\frac{1}{2};c=\frac{\sqrt{3}}{2}$

ផ្ចិត $(-2;-4)$ កំពូល $(-3;-4);(-1;-4)$

កំណុំ $\left(-2-\frac{\sqrt{3}}{2};-4\right);\left(-2+\frac{\sqrt{3}}{2};-4\right)$ និង $e=\frac{c}{a}=\frac{\sqrt{3}}{2}$

ង. $\frac{(x-1)^2}{9}+\frac{(y-5)^2}{25}=1$ មាន :

$h=1;k=5;a=5;b=3;c=4$

ផ្ចិត $(1,5)$ កំពូល $(1;0);(1;10)$ កំណុំ $(1;1);(1;9)$

និង $e=\frac{c}{a}=\frac{4}{5}$ ។

ច. $\frac{(x+2)^2}{4}+\frac{(y+2)^2}{25}=1$ មាន :

$h=-2;k=-2;a=5;b=2;c=\sqrt{21}$

ផ្ចិត $(-2,-2)$ កំពូល $(-2,-7);(-2,3)$

កំណុំ $(-2;-2-\sqrt{21});(-2;-2+\sqrt{21})$ និង $e=\frac{c}{a}=\frac{\sqrt{21}}{5}$ ។

**2-** រកកូអរដោនេនៃផ្ចិត កំពូល កំណុំ និងអ៊ិចសង់ទ្រីស៊ីតេនៃអេលីប រួចសង់អេលីបនីមួយៗ :

ក. $9x^2+4y^2+36x-24y+36=0$

ខ. $100x^2+16y^2-100x-64y-311=0$

គ. $9x^2+16y^2+54x-32y-47=0$

ឃ. $25x^2+4y^2-25x-16y+541=0$

ង. $2x^2+3y^2-8x+6y+5=0$

ច. $4x^2+y^2+4y=0$

## សំរាយបញ្ជាក់ :

រកកូអរដោនេនៃផ្ចិត កំពូល កំណុំ និងអ៊ិចសង់ទ្រីស៊ីតេនៃអេលីប រួចសង់អេលីបនីមួយៗ :

ក. $9x^2+4y^2+36x-24y+36=0$

$$\Rightarrow 9x^2+36x+36+4y^2-24y+36=36$$

$$\Rightarrow 9(x+2)^2+4(y-3)^2=36$$

$$\Rightarrow \frac{(x+2)^2}{4}+\frac{(y-3)^2}{9}=1$$

យើងបាន $h=-2; k=3; a=3; a=2; c=\sqrt{5}$

ផ្ចិត $(-2;3)$ កំណុំ $\left(-2;3\pm\sqrt{5}\right)$ កំពូល $(-2;6);(-2;0)$

និង $e=\frac{c}{a}=\frac{\sqrt{5}}{3}$ ។




ខ. $100x^2+16y^2-100x-64y-311=0$

$$\Rightarrow 100x^2-100x+25+16y^2-64y+64=400$$

$$\Rightarrow 100\left(x-\frac{1}{2}\right)^2+16(y-2)^2=400$$

$$\Rightarrow \frac{\left(x-\frac{1}{2}\right)^2}{4}+\frac{(y-2)^2}{25}=1$$

មាន $h=\frac{1}{2};k=2;a=5;b=2;c=\sqrt{21}$

ផ្ចិត $\left(\frac{1}{2};2\right)$ កំពូល $\left(\frac{1}{2};-3\right);\left(\frac{1}{2};7\right)$

កំណុំ $\left(\frac{1}{2};2-\sqrt{21}\right);\left(\frac{1}{2};2+\sqrt{21}\right)$ និង $e=\frac{c}{a}=\frac{\sqrt{21}}{5}$




គ. $9x^2+16y^2+54x-32y-47=0$

$\Rightarrow 9x^2+54x+81+16y^2-32y+16=144$

$\Rightarrow 9(x+3)^2+16(y-1)^2=144$

$\Rightarrow \frac{(x+3)^2}{16}+\frac{(y-1)^2}{9}=1$

មាន $h=-3;k=1;a=4;b=3;c=\sqrt{7}$

ផ្ចិត $(-3;1)$ កំពូល $(-7;1);(1;1)$

កំណុំ $\left(-3-\sqrt{7};1\right);\left(-3+\sqrt{7};1\right)$ និង $e=\frac{c}{a}=\frac{\sqrt{7}}{4}$ ។




ឃ. $25x^2+4y^2-25x-16y+541=0$

$\Rightarrow 25x^2-25x+\frac{25}{4}+4y^2-16y+16$

$=-541+16+\frac{25}{4}<0$ មិនអាច

ង. $2x^2+3y^2-8x+6y+5=0$

$\Rightarrow 2x^2-8x+8+3y^2+6y+3=6$

$\Rightarrow 2(x-2)^2+3(y+1)^2=6$

$\Rightarrow \frac{(x-2)^2}{3}+\frac{(y+1)^2}{2}=1$

មាន $h=2;k=-1;a=\sqrt{3};b=\sqrt{2};c=1$

ផ្ចិត $(2;-1)$ កំពូល $\left(2-\sqrt{3};-1\right);\left(2+\sqrt{3};-1\right)$

កំណុំ $(1;-1);(3;-1)$ និង $e=\frac{c}{a}=\frac{\sqrt{3}}{3}$




ច. $4x^2 + y^2 + 4y = 0$

$\Rightarrow 4x^2 + y^2 + 4y + 4 = -4 < 0$ មិនអាច ។

**3-** រកសមីការអេលីបដែលមានផ្ចិត $(0;0)$ កំណុំ $(2;0)$ និងកំពូល $(3;0)$

**សំរាយបញ្ជាក់ :**

សមីការអេលីបដែលមានផ្ចិនៅចំគល់ $(0;0)$ អ័ក្សធំជាអ័ក្សអាប់ស៊ីស

យើងបាន $\frac{x^2}{a^2} + \frac{y^2}{b^2} = 1$ និងមាន កំណុំ $(2;0)$ និងកំពូល $(3;0)$

យើងបាន $\begin{cases} c = 2 \\ a = 3 \end{cases} \Rightarrow b = \sqrt{5}$

$\Rightarrow \frac{x^2}{9} + \frac{y^2}{5} = 1$

**4-** រកសមីការនៃអេលីបដែលមានផ្ចិត $(0;0)$ កំណុំ $(2;0)$ និងអ័ក្សតូចមាន ប្រវែង 3 ឯកតា ។

**សំរាយបញ្ជាក់ :**

សមីការអេលីបដែលមានផ្ចិតនៅចំគល់ $(0;0)$ អ័ក្សធំជាអ័ក្សអាប់ស៊ីស :

យើងបាន : $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ និងមាន កំណុំ $(2;0)\Rightarrow a=2$

និងអ័ក្សតូចមានប្រវែង 3 ឯកតា យើងបាន $b=\frac{3}{2}$

$\Rightarrow \frac{x^2}{4}+\frac{y^2}{\frac{9}{4}}=1$

**5-** រកសមីការនៃអេលីបដែលមានកំពូល $(2;0)$ និង $(-2;0)$ ហើយមាន

អ៊ិចសង់ទ្រីស៊ីតេស្មើនឹង $e=\frac{3}{5}$ ។

**សំរាយបញ្ជាក់ :**

រកសមីការនៃអេលីប :

ដោយកំពូលទាំងពីរស្ថិតនៅលើអ័ក្សអាប់ស៊ីស នោះសមីការស្តង់ដានៃអេលីបគឺ: $\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$

ដោយផ្ចិតជាចំណុចកណ្តាលនៃអង្កត់ភ្ជាប់កំពូលទាំងពីរ គេបាន :

$h=0;k=0$ ។ ម្យ៉ាងទៀត $a$ ជាចម្ងាយពីផ្ចិតទៅកំពូល គេបាន $a=5$

ហើយ $e=\frac{c}{a}=\frac{c}{5}=\frac{3}{5}\Rightarrow c=3\Rightarrow b^2=a^2-c^2=25-9=16$

ដូចនេះ សមីការស្តង់ដាគឺ $\frac{x^2}{25}+\frac{y^2}{16}=1$

**7-** រកសមីការនៃអេលីបដែលមានផ្ចិត $(0;0)$ និងអ័ក្សធំជាអ័ក្សដេកហើយ

ចំណុច $(3;1)$ និង $(4;0)$ ស្ថិតនៅលើអេលីប ។

**សំរាយបញ្ជាក់ :**

រកសមីការនៃអេលីប

សមីការស្តង់ដាមានរាង $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ កាត់តាម ចំណុច $(3;1)$ និង $(4;0)$ នោះយើងបាន :

$$\begin{cases}\frac{9}{a^2}+\frac{1}{b^2}=1\\ \frac{16}{a^2}+0=1\end{cases}\Rightarrow\begin{cases}a=4\\ b=\frac{4}{\sqrt{7}}\end{cases}\Rightarrow\frac{x^2}{16}+\frac{y^2}{\frac{16}{7}}=1$$

**8-** រកសមីការនៃអេលីបដែលមានកំណុំ $(0;0)$ និង $(4;0)$ ។ផលបូកចម្ងាយពីកំណុំទាំងពីរទៅចំណុចមួយនៅលើអេលីបស្មើនឹង 10ឯកតា ។

**សំរាយបញ្ជាក់ :**

សមីការស្តង់ដាមានរាង $\frac{(x-h)^2}{a^2}+\frac{y^2}{b^2}=1$



កំណុំឋិតនៅលើអ័ក្សអាប់ស៊ីសនោះ $k=0$

ដោយ $PF_1+PF_2=2a=10\Rightarrow a=5$

កំណុំ $(0;0)$ និង $(4;0)$ យើងបាន :

$$\begin{cases}h-c=0\\h+c=4\end{cases}\Rightarrow h=2;c=2$$

$$\Rightarrow c^2=a^2-b^2\Rightarrow b=\sqrt{21}$$

យើងបាន សមីការស្តង់ដាគឺ $\dfrac{(x-2)^2}{25}+\dfrac{y^2}{21}=1$

**9-** រកសមីការនៃបន្ទាត់ប៉ះទៅនឹងអេលីប $4x^2+y^2=4$ ដែលកាត់តាមចំណុច $(3;0)$ ។

**សំរាយបញ្ជាក់ :**

សមីការបន្ទាត់មានរាង $y=ax+b$ កាត់តាមចំណុច$(3;0)$ យើងបាន :

$$0=3a+b\Rightarrow b=-3a$$

សមីការរវាងបន្ទាត់ប៉ះនឹងអេលីបកំណត់ដោយ :

$$\begin{cases}4x^2+y^2=4\\y=ax-3a\end{cases}\Rightarrow 4x^2+(ax-3a)^2=4$$

$$\Rightarrow x^2\left(4+a^2\right)-6a^2x+9a^2-4=0$$

$$\Delta'=9a^4-\left(4+a^2\right)\left(9a^2-4\right)=-36a^2+16+4a^2$$

$$=-32a^2+16$$

បន្ទាត់នឹងអេលីបប៉ះគ្នាលុះត្រាតែ

$$-32a^2+16=0 \Rightarrow a^2=\frac{1}{2} \Rightarrow a=\pm\frac{\sqrt{2}}{2}$$

ចំពោះ $a=\frac{\sqrt{2}}{2} \Rightarrow b=\frac{3\sqrt{2}}{2}$ បន្ទាត់ប៉ះ $y=\frac{\sqrt{2}}{2}x-\frac{3\sqrt{2}}{2}$

ចំពោះ $a=-\frac{\sqrt{2}}{2} \Rightarrow b=-\frac{3\sqrt{2}}{2}$ បន្ទាត់ប៉ះ $y=-\frac{\sqrt{2}}{2}x+\frac{3\sqrt{2}}{2}$

10. រកសមីការនៃអេលីបដែលមានផ្ចិត $(0;0)$ និងកំពូល $(0;\pm 6)$ ហើយកាត់តាមចំណុច $(3;2)$ ។

**សំរាយបញ្ជាក់ :**

រកសមីការនៃអេលីប :

សមីការស្តង់ដាមានរាង $\frac{x^2}{b^2}+\frac{y^2}{a^2}=1$

ដោយ កំពូល $(0;\pm 6)$ នោះ $a=6$ ហើយកាត់តាមចំណុច$(3;2)$

យើងបាន$\frac{9}{b^2}+\frac{4}{36}=1 \Rightarrow b=\frac{9}{2\sqrt{2}}$

$$\Rightarrow \frac{x^2}{\frac{81}{8}}+\frac{y^2}{36}=1$$

**11-** រកសមីការនៃអេលីបដែលមានផ្ចិត $(0;0)$ ហើយកាត់តាមចំណុច$(2;3)$ និង $(6;1)$ ។

**សំរាយបញ្ជាក់ :**

សមីការមានរាង $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ កាត់តាមចំណុច$(2;3)$និង $(6;1)$

យើងបាន : $\begin{cases}\frac{4}{a^2}+\frac{9}{b^2}=1\\ \frac{36}{a^2}+\frac{1}{b^2}=1\end{cases} \Rightarrow a^2=40;b^2=10$

$\Rightarrow \frac{x^2}{40}+\frac{y^2}{10}=1$

**12-** រកសមីការនៃអេលីបដែលមានផ្ចិត $(0;0)$និងអ័ក្សអាប់ស៊ីសត្រង់ចំណុច $(2;0)$និង $(-2;0)$ហើយកាត់ អ័ក្សអរដោនេត្រង់ចំណុច $\left(0;\frac{1}{3}\right)$និង $\left(0;-\frac{1}{3}\right)$។

**សំរាយបញ្ជាក់ :**

រកសមីការនៃអេលីប :

សមីការស្តង់ដាមានរាង $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ កាត់អ័ក្សអាប់ស៊ីសត្រង់ចំណុច $(2;0)$និង $(-2;0)$ហើយកាត់អ័ក្សអរដោនេត្រង់ចំណុច $\left(0;\frac{1}{3}\right)$និងចំនុច $\left(0;-\frac{1}{3}\right)$ យើងបាន : $a=2;b=\frac{1}{3}$

$\Rightarrow \frac{x^2}{4}+\frac{y^2}{\frac{1}{9}}=1$

**13-** រកសមីការនៃអេលីបដែលមានផ្ចិត $(0;0)$ ហើយអ័ក្សធំជាអ័ក្សដេកមាន ប្រវែង 8 ឯកតា និងអ័ក្សតូចមានប្រវែង 5 ឯកតា ។

**សំរាយបញ្ជាក់ :**

សមីការស្តង់ដាមានរាង $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ ហើយអ័ក្សធំជាអ័ក្សដេក មាន ប្រវែង 8 ឯកតា និងអ័ក្សតូចមានប្រវែង 5 ឯកតា យើងបាន :

$$\begin{cases}2a=8\\2b=5\end{cases}\Rightarrow a=4;b=\frac{5}{2}$$

$$\Rightarrow \frac{x^2}{16}+\frac{y^2}{\frac{25}{4}}=1$$

## មេរៀនទី ៣ អ៊ីពែបូល

### លំហាត់ :

1- សង់អ៊ីពែបូលនិងអាស៊ីមតូតរបស់វា :

ក. $\frac{x^2}{9}-\frac{y^2}{16}=1$ ខ. $\frac{y^2}{9}-\frac{x^2}{16}=1$

គ. $y^2-4x^2=16$ ឃ. $x^2-y^2=1$

ង. $x^2-5y^2=25$ ច. $y^2-x^2=25$

**សំរាយបញ្ជាក់ :**

ក. $\frac{x^2}{9}-\frac{y^2}{16}=1$ មានអ័ក្សទទឹងស្របនឹងអ័ក្ស $(x'ox)$ យើងបាន :

$a=3;b=4;h=0;k=0$

កំពូល $(-a;0)=(-3;0)$

$(a;0)=(3;0)$

អាស៊ីមតូត $y=\frac{b}{a}x=\frac{4}{3}x$ និង $y=-\frac{b}{a}x=-\frac{4}{3}x$

ខ. $\frac{y^2}{9}-\frac{x^2}{16}=1$ មាន $a=3;b=4;h=0;k=0$

កំពូល $(0;3);(0;-3)$

អាស៊ីមតូត $y=\frac{a}{b}x=\frac{3}{4}x;y=-\frac{a}{b}x=-\frac{3}{4}x$

គ. $y^2-4x^2=16\Rightarrow\frac{y^2}{16}-\frac{x^2}{4}=1$

មាន $a=4;b=2;h=0;k=0$ កំពូល $(0;-4);(0;4)$ អាស៊ីមតូត

$y=\frac{a}{b}x=2x;y=-\frac{a}{b}x=-2x$

ឃ. $x^2-y^2=1$ មាន $h=0;k=0;a=1;b=1$

កំពូល $(-1;0);(1;0)$

អាស៊ីមតូត $y=\frac{b}{a}x=x;y=-\frac{b}{a}x=-x$

ង. $x^2-5y^2=25\Rightarrow\frac{x^2}{25}-\frac{y^2}{5}=1$

មាន $h=0;k=0;a=5;b=\sqrt{5}$

កំពូល $(-5;0);(5;0)$

អាស៊ីមតូត $y=\frac{b}{a}x=\frac{\sqrt{5}}{5}x;y=-\frac{b}{a}x=-\frac{\sqrt{5}}{5}x$

ច. $y^2-x^2=25\Rightarrow\frac{y^2}{25}-\frac{x^2}{25}=1$

អាស៊ីមតូត $y=x;y=-x$

2- រកផ្ចិត កំណុំ កំពូល អ៊ិចសង់ទ្រីស៊ីតេនិងអាស៊ីមតូតនៃអ៊ីពែបូល បន្ទាប់មកសង់អ៊ីពែបូលនោះ

ក. $y^2-\frac{x^2}{4}=1$ ខ. $5y^2=4x^2+20$

គ. $\frac{(x-1)^2}{4}-\frac{(y+2)^2}{1}=1$ ឃ. $\frac{(x-2)^2}{4}-\frac{(y+3)^2}{9}=1$

ង. $4(x-2)^2-9(y+3)^2=36$

ច. $9x^2-y^2-36x-6y+18=0$

ឆ. $4x^2-y^2+8x+2y-1=0$ ។

**សំរាយបញ្ជាក់ :**

**ក.** $y^2-\frac{x^2}{4}=1$ អ័ក្សទទឹងស្របនឹងអ័ក្សអរដោនេ :

មាន $h=0;k=0;a=1;b=2;c=\sqrt{5}$

ផ្ចិត $(0;0)$ កំពូល $(0;-1);(0;1)$ កំណុំ $(0,-\sqrt{5});(0,\sqrt{5})$

$e=\frac{c}{a}=\frac{\sqrt{5}}{1}=\sqrt{5}$ អាស៊ីមតូត $y=\pm\frac{1}{2}x$




**ខ.** $5y^2=4x^2+20\Rightarrow\frac{y^2}{4}-\frac{x^2}{5}=1$ អ័ក្សទទឹងស្របនឹងអ័ក្ស

អរដោនេ :

យើងមាន : $h=0; k=0; a=2; b=\sqrt{5}; c=3$

ផ្ចិត $(0;0)$ កំពូល $(0;-2);(0;2)$ កំណុំ $(0;-3);(0;3)$

$e=\frac{c}{a}=\frac{3}{2}$ អាស៊ីមតូត $y=\pm\frac{2}{\sqrt{5}}x$




**គ.** $\frac{(x-1)^2}{4}-\frac{(y+2)^2}{1}=1$ អ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីស

មាន $h=1; k=-2; a=2; b=1; c=\sqrt{5}$

ផ្ចិត $(1;-2)$ កំពូល $(-1;-2);(3;-2)$

កំណុំ $\left(1-\sqrt{5};-2\right);\left(1+\sqrt{5};-2\right)$ ; $e=\frac{c}{a}=\frac{\sqrt{5}}{2}$

អាស៊ីមតូត $y=k+\frac{b}{a}(x-h)=-2+\frac{1}{2}(x-1)=\frac{1}{2}x-\frac{5}{2}$

និង $y=k-\frac{b}{a}(x-h)=-2-\frac{1}{2}(x-1)=-\frac{1}{2}x-\frac{3}{2}$

**ឃ.** $\frac{(x-2)^2}{4}-\frac{(y+3)^2}{9}=1$ អ័ក្សទទឹងស្រេបនឹងអ័ក្សអាប់ស៊ីស

មាន $h=2;k=-3;a=2;b=3;c=\sqrt{13}$

ផ្ចិត $(2;-3)$ កំពូល $(0;-3);(4;-3)$ កំណុំ $(-1;-3);(5;-3)$

អាស៊ីមតូត $y=k+\frac{b}{a}(x-h)=-3+\frac{3}{2}(x-2)=\frac{3}{2}x-6$

និង $y=k-\frac{b}{a}(x-h)=-3-\frac{3}{2}(x-2)=-\frac{3}{2}x;e=\frac{\sqrt{13}}{2}$

**ង.** $4(x-2)^2-9(y+3)^2=36$

$\Rightarrow\frac{(x-2)^2}{9}-\frac{(y+3)^2}{4}=1$ អ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីស

មាន $h=2;k=-3;a=3;b=2;c=\sqrt{13}$

ផ្ចិត $(2;-3)$ កំពូល $(-1;-3);(5;-3)$

កំណុំ $\left(2-\sqrt{13};-3\right);\left(2+\sqrt{13};-3\right)$

អាស៊ីមតូត $y=k+\frac{b}{a}(x-h)=-3+\frac{2}{3}(x-2)=\frac{2}{3}x-\frac{13}{3}$

និង $y=k-\frac{b}{a}(x-h)=-3-\frac{2}{3}(x-2)=-\frac{2}{3}x-\frac{5}{3}$

$e=\frac{\sqrt{13}}{2}$ ។




ច. $9x^2-y^2-36x-6y+18=0$

$\Rightarrow 9x^2-36x+36-y^2-6y-9=9$

$\Rightarrow 9(x-2)^2-(y+3)^2=9$

$\Rightarrow (x-2)^2-\frac{(y+3)^2}{9}=1$ អ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីស

មាន $h=2;k=-3;a=1;b=3;c=\sqrt{10}$

ផ្ចិត $(2;-3)$ កំពូល $(1;-3);(3;-3)$

កំណុំ $\left(2-\sqrt{10};-3\right);\left(2+\sqrt{10};-3\right)$

អាស៊ីមតូត $y=k+\frac{b}{a}(x-h)=-3+\frac{3}{1}(x-2)=3x-9$

$y=k-\frac{b}{a}(x-h)=-3-\frac{3}{1}(x-2)=-3x+3$

$$e=\frac{c}{a}=\frac{\sqrt{10}}{1}=\sqrt{10}$$




ឆ. $4x^2-y^2+8x+2y-1=0$

$4x^2+8x+4-y^2+2y-1=4$

$4(x+1)^2-(y-1)^2=4$

$(x+1)^2-\frac{(y-1)^2}{4}=1$ អ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីស

មាន $h=-1; k=1; a=1; b=2; c=\sqrt{5}$ ផ្ចិត $(-1;1)$

កំពូល $(-2;1);(0;1)$ កំណុំ $\left(-1-\sqrt{5};1\right);\left(-1+\sqrt{5};1\right)$

អាស៊ីមតូត $y=k+\frac{b}{a}(x-h)=1+2(x+1)=2x+3$

$y=k-\frac{b}{a}(x-h)=1-2(x+1)=-2x-1$

$$e=\frac{c}{a}=\sqrt{5}$$




3- រកផ្ចិត កំណុំ កំពូលនិងអាស៊ីមតូតនៃអ៊ីពែបូល បន្ទាត់មកសង់អ៊ីពែបូលនោះ :

ក. $x^2-y^2-2x-2y-1=0$

ខ. $y^2-4x^2-16x-2y-19=0$

គ. $3y^2-x^2+6x-12y=0$

ឃ. $4x^2-5y^2-16x+10y+31=0$

**សំរាយបញ្ជាក់ :**

ក. $x^2-y^2-2x-2y-1=0$

$$x^2-2x+1-y^2-2y-1=1$$

$(x-1)^2-(y+1)^2=1$ អ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីស

មាន $h=1;k=-1;a=1;b=1;c=\sqrt{2}$ ។

ផ្ចិត $(1;-1)$ កំពូល $(0;-1);(2;-1)$

កំណុំ $(1-\sqrt{2};-1);(1+\sqrt{2};-1)$

អាស៊ីមតូត $y=k+\frac{b}{a}(x-h)=-1+(x-1)=x-2$

$y=k-\frac{b}{a}(x-h)=-1-(x-1)=-x$

**ខ.** $y^2-4x^2-16x-2y-19=0$

$\Rightarrow y^2-2y+1-4x^2-16x-16=4$

$\Rightarrow (y-1)^2-4(x-2)^2=4$

$\Rightarrow \frac{(y-1)^2}{4}-(x-2)^2=1$

**គ.** $3y^2-x^2+6x-12y=0$

$\Rightarrow 3y^2-12y+12-x^2+6x-9=3$

$\Rightarrow 3(y-2)^2-(x-3)^2=3$

$\Rightarrow (y-2)^2-\frac{(x-3)^2}{3}=1$

**ឃ.** $4x^2-5y^2-16x+10y+31=0$

$$\Rightarrow 4x^2-16x+16-5y^2+10y-5=-20$$

$$\Rightarrow 4(x-2)^2-5(y-1)^2=-20$$

$$\Rightarrow \frac{(y-1)^2}{4}-\frac{(x-2)^2}{5}=1$$

4- រកសមីការស្តង់ដានៃអ៊ីពែបូលដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដែលឱ្យ:

**ក**. ផ្ចិតមានកូអរដោនេ $(0;0)$ កំពូលមានកូអរដោនេ $(0;2)$ និង កំណុំមានកូអរដោនេ $(0;4)$ ។

**ខ**. ផ្ចិតមានកូអរដោនេ $(0;0)$ កំពូលមានកូអរដោនេ $(3;0)$ និង កំណុំមានអរដោនេ $(5;0)$ ។

**គ**. កំពូលទាំងពីរមានកូអរដោនេ $(\pm 1;0)$ និងអាស៊ីមតូតទាំងពីរ មានសមីការ $y=\pm 3x$ ។

**ឃ**. កំពូលទាំងពីរមានកូអរដោនេ $(0;\pm 3)$ និងអាស៊ីមតូតទាំង ពីរមានសមីការ $y=\pm 3x$ ។

**ង**. កំពូលទាំងពីរមានកូអរដោនេ $(2;\pm 3)$ និងចំណុចមួយនៅលើ ក្រាបមានកូអរដោនេ $(0;5)$ ។

**សំរាយបញ្ជាក់ :**

**ក.** សមីការស្តង់ដាមានរាង $\frac{y^2}{a^2}-\frac{x^2}{b^2}=1$ ព្រោះកំពូលនិងកំណុំស្ថិតនៅលើអ័ក្សអរដោនេ ហេតុនេះ អ័ក្សទទឹងស្របនឹងអ័ក្សអាប់ស៊ីស ។

ដោយ កំពូល $(0;2)$និង កំណុំ$(0;4)$ យើងបាន :

$$\begin{cases}a=2\\c=4\end{cases}\Rightarrow b^2=c^2-a^2=12$$

$$\Rightarrow\frac{y^2}{4}-\frac{x^2}{12}=1$$

**ខ.** សមីការស្តង់ដាមានរាង $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ព្រោះកំពូលនិងកំណុំស្ថិតនៅលើអ័ក្សអាប់ស៊ីសហេតុនេះ អ័ក្សទទឹងស្របនឹងអ័ក្សអរដោនេ ។

ដោយកំពូល$(3;0)$និងកំណុំ $(5;0)$ យើងបាន :

$$\begin{cases}a=3\\c=5\end{cases}\Rightarrow b^2=25-9=16$$

$$\Rightarrow\frac{x^2}{9}-\frac{y^2}{16}=1$$

**គ.** ដោយកំពូលស្ថិតនៅ លើបន្ទាត់ដេកនោះសមីការស្តង់ដាមាន

ទម្រង់ $\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$ ផ្ចិតនៃអ៊ីពែបូលស្ថិតនៅត្រង់

ចំណុចកណ្ដាលនៃអង្កត់ភ្ជាប់កំពូលទាំងពីរ :

យើងបាន : $(h;k)=\left(\frac{1+(-1)}{2};\frac{0+0}{2}\right)=(0;0)$

ដោយអាស៊ីមតូតមានទម្រង់ : $y=k\pm\frac{b}{a}(x-h)=\pm3x$

$\frac{b}{a}=3\Rightarrow b=3a$ តែ $a=1\Rightarrow b=3$

យើងបានសមីការស្ដង់ដាគឺ : $x^2-\frac{y^2}{9}=1$

**ឃ.** $\frac{y^2}{9}-x^2=1$

**ង.** $\frac{y^2}{9}-\frac{(x-2)^2}{\frac{9}{4}}=1$

5-រកសមីការស្ដង់ដានៃអ៊ីពែបូលដែលចំពោះ គ្រប់ចំណុចនៅលើអ៊ីពែបូលមានផលដកចម្ងាយរបស់វាពីចំណុច $(2;2)$ និង $(10;2)$ ស្មើនឹង 6 ។

**សំរាយបញ្ជាក់ :**

រកសមីការស្ដង់ដានៃអ៊ីពែបូល

យើងបាន :

$$d_1 - d_2 = 6$$

$$\Rightarrow \sqrt{(x-2)^2+(y-2)^2} - \sqrt{(x-10)^2+(y-2)^2} = 6$$

$$\Rightarrow \sqrt{(x-2)^2+(y-2)^2} = 6 + \sqrt{(x-10)^2+(y-2)^2}$$

$$\Rightarrow (x-2)^2-(x-10)^2-36 = 12\sqrt{(x-10)^2+(y-2)^2}$$

$$\Rightarrow 16x^2-264x+1089 = 9\left(x^2-20x+100+y^2-4y+4\right)$$

$$\Rightarrow 7(x-6)^2-9(y-2)^2 = 63$$

$$\Rightarrow \frac{(x-6)^2}{9}-\frac{(y-2)^2}{7}=1$$

6- រកសមីការស្តង់ដា នៃអ៊ីពែបូលដែលចំពោះគ្រប់ចំណុចនៅលើអ៊ីពែបូលមានផលដកចម្ងាយរបស់វាពីចំណុច $(-3;0)$ និង $(-3;3)$ ស្មើនឹង 2 ។

**សំរាយបញ្ជាក់ :**

ស្រាយដូចខាងលើដែរ យើងបាន $\left(y-\frac{3}{2}\right)^2-\frac{(x+3)^2}{\frac{5}{4}}=1$

7- បង្ហាញថាបន្ទាត់ប៉ះទៅនឹង $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ត្រង់ចំណុច $(x_o;y_o)$

មាន សមីការ $\frac{x_o x}{a^2}-\frac{y_o y}{b^2}=1$ ។

**សំរាយបញ្ជាក់ :**

បង្ហាញថាបន្ទាត់ប៉ះទៅនឹង $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ត្រង់ចំណុច $(x_o;y_o)$

មាន សមីការ $\frac{x_o x}{a^2}-\frac{y_o y}{b^2}=1$

ដោយ $\frac{x^2}{a^2}-\frac{y^2}{b^2}=1 \Rightarrow \frac{2x}{a^2}-\frac{2yy'}{b^2}=0 \Rightarrow y'=\frac{b^2 x}{a^2 y}$

សមីការបន្ទាត់ប៉ះកំណត់ដោយ :

$$y-y_o=\frac{b^2 x_o}{a^2 y_o}(x-x_o) \Rightarrow a^2 yy_o-b^2 x_o x=a^2 y_o^2-b^2 x_o^2$$

$$\Rightarrow \frac{xx_o}{a^2}-\frac{y_o y}{b^2}=\frac{x_o^2}{a^2}-\frac{y_o^2}{b^2}=1 \Rightarrow \frac{xx_o}{a^2}-\frac{y_o y}{b^2}=1$$

**8-** កំណុំទាំងពីរនៃអ៊ីពែបូលគឺ $F_1(0;3)$ និង $F_2(0;-3)$ ហើយ $P$ ជាចំណុចមួយនៅលើអ៊ីពែបូលដែល មានផលដកចម្ងាយរបស់វាពីចំណុច $F_1$ និង $F_2$ ស្មើនឹង2ឯកតា។ ប្រើនិយមន័យនៃអ៊ីពែបូលទាញរកសមីការស្តង់ដានៃអ៊ីពែបូលនោះ។

**សំរាយបញ្ជាក់ :**

តាង $P(x,y)$ យើងបាន

$$F_1P - F_2P = 2$$

$$\Rightarrow \sqrt{x^2 + (y-3)^2} - \sqrt{x^2 + (y+3)^2} = 2$$

$$\Rightarrow \sqrt{x^2 + (y-3)^2} = 2 + \sqrt{x^2 + (y+3)^2}$$

$$\Rightarrow x^2 + (y-3)^2 = 4 + 4\sqrt{x^2 + (y+3)^2} + x^2 + (y+3)^2$$

$$\Rightarrow (y-3)^2 - (y+3)^2 - 4 = 4\sqrt{x^2 + (y+3)^2}$$

$$\Rightarrow -3y - 1 = \sqrt{x^2 + (y+3)^2}$$

$$\Rightarrow 9y^2 + 6y + 1 = x^2 + y^2 + 6y + 9$$

$$\Rightarrow 8y^2 - x^2 = 8 \Rightarrow y^2 - \frac{x^2}{8} = 1$$

**9-** រកសមីការនៃអ៊ីពែបូលដែលមានកំណុំ$(\pm 4;0)$ហើយតម្លៃនៃផលដកចម្ងាយពីចំណុចមួយនៅលើអ៊ីពែបូលទៅកំណុំទាំងពីរស្មើនឹង 4 ។

**សំរាយបញ្ជាក់ :**

តាង $P(x,y)$ យើងបាន :

$$F_1P - F_2P = 4$$

$$\Rightarrow \sqrt{(x+4)^2 + y^2} - \sqrt{(x-4)^2 + y^2} = 4$$

$$\Rightarrow \frac{x^2}{4} - \frac{y^2}{12} = 1$$

**10-** រកសមីការបន្ទាត់ប៉ះទៅនឹងអ៊ីពែបូល $9x^2 - 4y^2 = 36$

ដែលកាត់តាមចំណុច (1;0) ។

**សំរាយបញ្ជាក់ :**

សមីការបន្ទាត់ប៉ះមានរាង $y = ax + b$ កាត់តាមចំណុច$(1;0)$

យើងបាន $0 = a + b \Rightarrow a = -b \Rightarrow y = ax - a = a(x-1)$

ដោយ

$$\begin{cases} 9x^2 - 4y^2 = 36 \\ y = a(x-1) \end{cases} \Rightarrow 9x^2 - 4a^2(x-1)^2 = 36$$

$$\Rightarrow 9x^2 - 4a^2\left(x^2 - 2x + 1\right) = 36.$$

$$\Rightarrow \left(9 - 4a^2\right)x^2 + 8a^2x - 4a^2 - 36 = 0$$

$$\Delta' = 16a^4 + \left(9 - 4a^2\right)\left(4a^2 + 36\right) = -108a^2 + 324$$

បន្ទាត់ប៉ះនឹងប៉ារ៉ាបូលកាលណា $\Delta' = 0 \Rightarrow a = \pm\sqrt{3}$

យើងបាន សមីការបន្ទាត់ប៉ះ $y = \pm\sqrt{3}(x-1)$




**11-** អ្នករូបវិទ្យាម្នាក់បានរកឃើញថា នៅពេលភាគល្អិតអាល់ហ្វាត្រូវបានបាញ់ចេញឆ្ពោះទៅណៃយ៉ូនៃអាតូមមួយ ដោយវាបានច្រានចេញពីណៃយ៉ូតាមគន្លងអ៊ីពែបូល ។ រូបខាងស្តាំ នេះបង្ហាញពីគន្លងនៃ

ភាគល្អិតដែលចាប់ផ្តើមឆ្ពោះទៅ គល់អ័ក្សអរដោនេតាមបន្ទាត់មួយមានសមីការ $y=\frac{1}{2}x$ ហើយធ្លាក់មក 3 ឯកតាពីណៃយ៉ូ ។ ចូររកសមីការនៃគន្លង ។

**សំរាយបញ្ជាក់ :**

គន្លងជាអ៊ីពែបូលដែលមាន $V(\pm3;0)$ និង $W\left(0;\pm\frac{3}{2}\right)$

សមីការស្តង់ដាគឺ :

$$\frac{x^2}{3}-\frac{y^2}{\left(\frac{3}{2}\right)^2}=1 \Rightarrow x^2-4y^2=9 \Rightarrow x=\pm\sqrt{4y^2+9}$$

បើមានមែកតែម្ខាងនៅខាងស្តាំ

នោះ $x=\sqrt{4y^2+9}$ ជាសមីការគន្លង ។

# លំហាត់ជំពូក៦

1- ចូរបញ្ជាក់ប្រភេទសមីការនីមួយៗនិងគូសក្រាបរបស់វា :

ក. $y^2-12y-8x+20=0$

ខ. $3x^2+2y^2-12x+12y+29=0$

គ. $3x^2-2y^2+24x+12y+24=0$

ឃ. $x^2-6x+2y+9=0$

## សំរាយបញ្ជាក់ :

បញ្ជាក់ប្រភេទសមីការនីមួយៗនិងគូសក្រាបរបស់វា :

ក. $y^2-12y-8x+20=0$

$\Rightarrow y^2-12y+36=8x+16$

$\Rightarrow (y-6)^2=8(x+2)$ ជាសមីការប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះដេក

ខ. $3x^2+2y^2-12x+12y+29=0$

$\Rightarrow 3x^2-12x+12+2y^2+12y+18=1$

$\Rightarrow 3(x-2)^2+2(y+3)^2=1$

$\Rightarrow \dfrac{(x-2)^2}{\frac{1}{3}}+\dfrac{(y+3)^2}{\frac{1}{2}}=1$ សមីការអេលីបដែលមានអ័ក្សធំ

ស្របនឹងអ័ក្សអរដោនេ។

**គ.** $3x^2-2y^2+24x+12y+24=0$

$\Rightarrow 3x^2+24x+48-2y^2+12y-18=6$

$\Rightarrow 3(x+4)^2-2(y-3)^2=6$

$\Rightarrow \dfrac{(x+4)^2}{2}-\dfrac{(y-3)^2}{3}=1$ ជាសមីការអ៊ីពែបូល

**ឃ.** $x^2-6x+2y+9=0$

$\Rightarrow x^2-6x+9=-2y \Rightarrow (x-3)^2=-2y$ ជាសមីការ

ប៉ារ៉ាបូល។

**2-** រកសមីការប៉ារ៉ាបូលដែលកំណត់ដោយលក្ខខណ្ឌដូចខាងក្រោម៖

**ក.** កំណុំ $F(4;0)$ និងកំពូល $V(2;0)$

**ខ.** កំពូល $V(0;2)$ និងបន្ទាត់ប្រាប់ទិសមានសមីការ $x+3=0$

**សំរាយបញ្ជាក់ :**

**ក.** សមីការស្តង់ដាមានរាង :

$(y-k)^2=4p(x-h)$ ព្រោះវាមាន កំណុំ និងកំពូលស្ថិតនៅ

លើអ័ក្សអាប់ស៊ីស :

ដោយ កំពូល $V(2;0) \Rightarrow h = 2; k = 0$

កំណុំ $F(4;0) \Rightarrow h + p = 4 \Rightarrow p = 2$

យើងបាន សមីការស្តង់ដា $y^2 = 8(x-2)$

**ខ.** ដោយបន្ទាត់ប្រាប់ទិសជាបន្ទាត់ឈរ នោះប៉ារ៉ាបូលមានរាង

$(y-k)^2 = 4p(x-h)$

ដោយ កំពូល $V(0;2) \Rightarrow h = 0; k = 2$

បន្ទាត់ប្រាប់ទិស $x = -3 \Rightarrow h - p = -3 \Rightarrow p = 3$

យើងបាន សមីការស្តង់ដា $(y-2)^2 = 12x$

**3-** រកសមីការនៃអេលីបនីមួយៗខាងក្រោម:

**ក.** កំពូលទាំងពីរមានកូអរដោនេ $(0;2)$ និង$(4;2)$ និងមានអ៊ិចសង់ទ្រីស៊ីតេស្មើនឹង $\frac{1}{2}$ ។

**ខ.** កំពូលទាំងពីរមានកូអរដោនេ $(3;1)$ និង$(3;9)$ហើយអ័ក្សតូចមានប្រវែងស្មើនឹង 6ឯកតា ។

**ដំរាយបញ្ជាក់ :**

**ក.** សមីការស្តង់ដាមានរាង $\frac{(x-h)^2}{a^2} - \frac{(y-k)^2}{b^2} = 1$

ដោយ កំពូលទាំងពីរមានកូអរដោនេ $(0;2)$ និង$(4;2)$

យើងបាន :

$$\begin{cases} h-a=0 \\ h+a=4 \end{cases} \Rightarrow h=2; a=2 \text{ និង } e=\frac{c}{a}=\frac{1}{2} \Rightarrow c=1$$

$$c^2=a^2-b^2 \Rightarrow b^2=a^2-c^2=3$$

យើងបាន សមីការស្តង់ដា $\frac{(x-2)^2}{4}+\frac{(y-2)^2}{3}=1$

**ខ.** សមីការស្តង់ដាមានរាង $\frac{(x-h)^2}{b^2}+\frac{(y-k)^2}{a^2}=1$

កំពូលទាំងពីរមានកូអរដោនេ $(3;1)$ និង $(3;9)$ យើងបាន :

$$\begin{cases} h=3 \\ k-a=1 \\ k+a=9 \end{cases} \Rightarrow \begin{cases} h=3 \\ k=5 \\ a=4 \end{cases}$$

និង អ័ក្សតូចមានប្រវែងស្មើនឹង 6ឯកតា យើងបាន :

$$2b=6 \Rightarrow b=3$$

សមីការស្តង់ដាគឺ : $\frac{(x-3)^2}{9}+\frac{(y-5)^2}{16}=1$

**4-** រកសមីការនៃអ៊ីពែបូលនីមួយៗខាងក្រោម:

**ក.** កំណុំទាំងពីរមានកូអរដោនេ$(-4;0)$ និង $(4;0)$ ហើយតម្លៃ

ដាច់ខាតនៃផលដកចម្ងាយពីចំណុច មួយស្ថិតនៅលើអ៊ីពែបូលទៅកំណុំទាំងពីរស្មើនឹង 4 ។

**ខ.** កំណុំទាំងពីរមានកូអរដោនេ $(0;0)$ និង $(8;0)$ ហើយអាស៊ីមតូតទាំងពីរមានសមីការ $y=2(x-4)$ និង $y=-2(x-4)$ ។

**សំរាយបញ្ជាក់ :**

**ក.** ដោយ កំណុំទាំងពីរមានកូអរដោនេ$(-4;0)$ និង $(4;0)$ស្ថិតនៅលើអាប់ស៊ីស យើងបានសមីការមានរាង :

$$\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$$

ផ្ចិតជាចំណុចកណ្ដាលនៃកំណុំទាំងពីរ យើងបាន :

$$h=\frac{4-4}{2}=0;k=0$$

តែ កំណុំ$(-4;0)=(h-c;k)\Rightarrow h-c=-4\Rightarrow c=4$

និង $2a=4\Rightarrow a=2;b^2=c^2-a^2=16-4=12$

សមីការស្តង់ដាគឺ $\frac{x^2}{4}-\frac{y^2}{12}=1$

**ខ.** ដោយ កំណុំទាំងពីរមានកូអរដោនេ$(0;0)$និង $(8;0)$ស្ថិតនៅលើអាប់ស៊ីស យើងបានសមីការមានរាង :

$$\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$$

កំណុំមានកូអរដោនេ(០;0) និង (8;0) យើងបាន :

$$\begin{cases}(h-c;k)=(0;0)\\(h+c;k)=(8;0)\end{cases}\Rightarrow\begin{cases}h=4\\k=0\\c=4\end{cases}$$

និង អាស៊ីមតូតទាំងពីរ $y=2(x-4)$ និង $y=-2(x-4)$

$$\frac{b}{a}=2\Rightarrow b=2a$$

តែ $c^2=a^2+b^2=5a^2\Rightarrow a=\frac{c}{\sqrt{5}}=\frac{4}{\sqrt{5}};b=\frac{8}{\sqrt{5}}$

យើងបាន សមីការស្តង់ដា $\frac{(x-4)^2}{\frac{16}{5}}-\frac{y^2}{\frac{64}{5}}=1$

5- រកសមីការនៃបន្ទាត់ប៉ះទៅនឹងប៉ារ៉ាបូលមានសមីការ :

$y=x^2-2x+2$ ហើយកែងទៅនឹងបន្ទាត់មានសមីការ $y=x-2$

**សំរាយបញ្ជាក់ :**

សមីការបន្ទាត់ប៉ះមានរាង $y=ax+b$ ហើយកែងនឹង បន្ទាត់

$y=x-2\Rightarrow a\times1=-1\Rightarrow a=-1$

$\Rightarrow y=-x+b$

សមីការរវាងបន្ទាត់និងប៉ារ៉ាបូលកំណត់ដោយ :

$$\begin{cases} y = x^2 - 2x + 2 \\ y = -x + b \end{cases} \Rightarrow x^2 - 2x + 2 = -x + b$$

$$\Rightarrow x^2 - x + 2 - b = 0$$

$$\Delta = 1 - 4(2 - b) = -7 + 4b$$

បន្ទាត់ប៉ះនឹងប៉ារ៉ាបូល នោះយើងបាន :

$$\Delta = 0 \Rightarrow -7 + 4b = 0 \Rightarrow b = \frac{4}{7}$$

បន្ទាត់ប៉ះមានរាង $y = -x + \frac{7}{4}$

6- បង្ហាញថា បន្ទាត់ប៉ះទៅនឹងអេលីប $\frac{x^2}{a^2} + \frac{y^2}{b^2} = 1$ ត្រង់ចំណុច $(x_o; y_o)$ មានសមីការ $\frac{x_o}{a^2}x + \frac{y_o}{b^2}y = 1$ ។

**សំរាយបញ្ជាក់ :**

ដោយ $\frac{x^2}{a^2} + \frac{y^2}{b^2} = 1 \Rightarrow \frac{2x}{a^2} + \frac{2yy'}{b^2} = 0 \Rightarrow y' = -\frac{b^2 x}{a^2 y}$

សមីការបន្ទាត់ប៉ះកំណត់ដោយ :

$$y - y_o = -\frac{b^2 x_o}{a^2 y_o}(x - x_o) \Rightarrow a^2 y y_o + b^2 x_o x = a^2 y_o^2 + b^2 x_o^2$$

$$\Rightarrow \frac{x x_o}{a^2} + \frac{y_o y}{b^2} = \frac{x_o^2}{a^2} + \frac{y_o^2}{b^2} = 1 \Rightarrow \frac{x x_o}{a^2} + \frac{y_o y}{b^2} = 1$$

7- រកតម្លៃ $a$ តាម $b$ ដើម្បីឱ្យអ៊ីពែបូល $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ គឺប៉ះទៅនឹងបន្ទាត់នៃសមីការ $2x-y-4=0$ ។ រួចគណនាតម្លៃ $a$ បើ $b=2$

**សំរាយបញ្ជាក់ :**

សមីការអាប់ស៊ីសរវាងអ៊ីពែបូលនិងបន្ទាត់ :

$y=2x-4=2(x-2)$ កំណត់ដោយ

$$\frac{x^2}{a^2}-\frac{4(x-2)^2}{b^2}=1$$

$$\Rightarrow b^2x^2-4a^2(x-2)^2=a^2b^2$$

$$\Rightarrow (b^2-4a^2)x^2+16a^2x-(16a^2+a^2b^2)=0$$

$$\Delta'=64a^4+(b^2-4a^2)(16a^2+a^2b^2)$$

$$=16a^2b^2+a^2b^4-4a^4b^2$$

ដើម្បីឱ្យបន្ទាត់ប៉ះនឹងអ៊ីពែបូលលុះត្រាតែ $\Delta'=0$

$$\Rightarrow 16a^2b^2+a^2b^4-4a^4b^2=0$$

$$\Rightarrow a^2b^2(16+b^2-4a^2)=0$$

$$\Rightarrow 16+b^2-4a^2=0 \Rightarrow a=\pm\sqrt{\frac{b^2+16}{4}}$$

បើ $b=2 \Rightarrow a=\pm\sqrt{5}$

8-រកបរិមាត្រនៃចតុកោណកែង ដែលមានផ្ទៃក្រឡាអតិបរមាអាចចារឹកក្នុងអេលីប $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ ។

**សំរាយបញ្ជាក់ :**

តាង $(x;y)$ ជាកំពូលមួយនៃចតុកោណ

ដែលស្ថិតនៅកាដ្រង់ទី I :




$$\frac{x^2}{a^2}+\frac{y^2}{b^2}=1\Rightarrow\frac{y^2}{b^2}=1-\frac{x^2}{a^2}$$

$$\Rightarrow y^2=\frac{b^2}{a^2}\left(a^2-x^2\right)\Rightarrow y=\pm\frac{b}{a}\sqrt{a^2-x^2}$$

ដោយ បណ្តោយគឺ $2x$ និងទទឹងគឺ $2y=\frac{2b}{a}\sqrt{a^2-x^2}$

យើងបាន ក្រឡាផ្ទៃចតុកោណកែង :

$$A=2x\times\frac{2b}{a}\sqrt{a^2-x^2}$$

$$\Rightarrow\frac{dA}{dx}=\frac{4b}{a}\left[\frac{-x^2}{\sqrt{a^2-x^2}}+\sqrt{a^2-x^2}\right]$$

$$\frac{dA}{dx}=0\Rightarrow x=\frac{a}{\sqrt{2}}$$

| $x$ | | $\frac{a}{\sqrt{2}}$ | |
|---|---|---|---|
| $\frac{dA}{dx}$ | + | | − |
| A | ↗ | អតិបរមា | ↘ |

យើងបាន បណ្តោយគឺ $2x=\frac{2a}{\sqrt{2}}$

ទទឹង $\frac{2b}{a}\sqrt{a^2-x^2}=\frac{2b}{a}\sqrt{a^2-\frac{a^2}{2}}=\sqrt{2}b$

**9-** អាងមួយមានរាងជាអេលីប ។ អ័ក្សធំមានប្រវែង $10m$ និងអ័ក្សតូចមានប្រវែង $6m$ ។

**ក.** សរសេរសមីការនៃអេលីប ។

**ខ.** រកប្រវែងទទឹងអាងនៅ ត្រង់ចំណុចមួយនៅលើអ័ក្សធំដែលមានចម្ងាយ $2m$ ពីផ្ចិត ។

**សំរាយបញ្ជាក់ :**

**ក.** ដោយ អ័ក្សធំមានប្រវែង $10m$ និងអ័ក្សតូចមានប្រវែង $6m$

យើងបាន $\begin{cases}2a=10\\2b=6\end{cases}\Rightarrow\begin{cases}a=5\\b=3\end{cases}$

សមីការស្តង់ដា $\frac{x^2}{a^2}+\frac{y^2}{b^2}=1\Rightarrow\frac{x^2}{25}+\frac{y^2}{9}=1$

**ខ.** ដោយ $x=2\Rightarrow\frac{4}{25}+\frac{y^2}{9}=1$

$\Rightarrow y=\sqrt{\left(1-\frac{4}{25}\right)\times9}=2.75m$

**10-** ធ្នូនៃស្ពានមួយមានរាងពាក់កណ្តាល អេលីបដែល មានអ័ក្សធំជាងអ័ក្សដេក ។ បាតនៃធ្នូកាត់ទទឹងផ្លូវនៅក្រោមស្ពានមានប្រវែង

$9m$ ហើយផ្នែកខ្ពស់បំផុតនៃធ្នូនៅ ចំកណ្ដាលទ្រូងផ្លូវក្រោមស្ពាន មានកម្ពស់ $3m$ ដូចរូបដែលបានបង្ហាញ។ រកប្រវែងកម្ពស់នៃធ្នូដែលមានចម្ងាយ $1.8m$ ពីផ្ចិតនៃបាត។




## សំរាយបញ្ជាក់ :

ចំណោទនេះជាអេលីបមួយដែលមាន $V\left(\pm\frac{9}{2};0\right)$ និង $M(0;\pm3)$

ជំនួស $x=1.8$ ក្នុង $\frac{x^2}{\left(\frac{9}{2}\right)^2}+\frac{y^2}{3^2}=1 \Rightarrow \frac{y^2}{3}=1-\frac{(1.8)^2}{18}\times4$

$$y^2=9\left(1-\frac{(18)^2}{8100}\times4\right)=7.56 \Rightarrow y=\sqrt{7.56}=2.75$$

ដូចនេះ ប្រវែងកម្ពស់នៃធ្នូដែលមានចម្ងាយ $1.8m$ ពីផ្ចិតនៃបាតគឺ $2.75m$ ។

**11-** ភាគល្អិតមួយកំពុងផ្លាស់ទីស្របនឹង ដំណើរទ្រនិចនាឡិកានៅលើគន្លងរាងអេលីបមួយដែលមានសមីការ $\frac{x^2}{10^2}+\frac{y^2}{5^2}=1$ ។ភាគល្អិតនេះបានចេញពីគន្លងនៅត្រង់ចំណុច $(-8;3)$ ហើយផ្លាស់ទីតាមបន្ទាត់មួយប៉ះទៅនឹងអេលីប ។ តើភាគល្អិតនេះនឹងកាត់អ័ក្សអរដោនេត្រង់ចំណុចណា?

## សំរាយបញ្ជាក់ :

តើភាគល្អិតនេះនឹងកាត់អ័ក្សអរដោនេត្រង់ចំណុចណា?

ដើម្បីរកមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះ

ត្រង់ $(-8,3)$ យើងបាន :

$$\frac{x^2}{100}+\frac{y^2}{25}=1$$

$$\Rightarrow \frac{x}{50}+\frac{2yy'}{25}=1$$

$$\Rightarrow y'=-\frac{x}{4y}$$



ដូចនេះ មេគុណប្រាប់ទិសត្រង់ $(-8;3)$ គឺ :$m=\dfrac{-(-8)}{4\times3}=\dfrac{2}{3}$

សមីការនៃបន្ទាត់ប៉ះគឺ $y-3=\dfrac{2}{3}(x+8)\Rightarrow 3y=2x+25$

បើ $x=0\Rightarrow y=\dfrac{25}{3}$

ដូចនេះ ភាគល្អិតនេះនឹងកាត់អ័ក្សអរដោនេត្រង់ចំណុច $\left(0;\dfrac{25}{3}\right)$ ។